# កំពង់ចាម




# និម្មិតរូបនៃឥស្សរភាព

រៀបរៀងនិងចងក្រងដោយ

**ឆុច ថាត**

អតីតអភិបាលក្រុងកំពង់ចាម

# អារម្ភកថា

កម្រងនៃអត្ថបទដែលពាក់ពន្ធ័នឹងខេត្តកំពង់ចាមនេះ ខ្ញុំបានព្យាយាមស្រាវជ្រាវចេញពីឯកសារប្រវត្តិសាស្ត្រ ដែលចងក្រងដោយប្រវត្តិវិទូបារាំងនិងខ្មែរ ព្រមទាំងឯកសារផ្សេងទៀត ដែលមាននៅសេសសល់ពីការបំផ្លិចបំផ្លាញរបស់របបប្រល័យពូជសាសន៍ ព្រមទាំងឯកសារដែលបាន បោះផ្សាយថ្មីៗ ដោយ បានធ្វើការផ្ទៀងផ្ទាត់ជាមួយព័ត៌មានដែលផ្តល់ដោយមហាជន គ្រប់ស្រទាប់ដែលបានចងចាំ និងបានរស់នៅជាមួយនឹងអតីត កាលនៃខេត្តកំពង់ចាម ។ វាជាការពិត វណ្ណកម្មនេះពុំអាចមាន លក្ខណៈត្រឹមត្រូវគ្រប់ជ្រុងជ្រោយនៅឡើយទេ វាគ្រាន់តែជាសមិទ្ធិនៃការប្រមែរប្រមូលចងក្រងរបស់ខ្ញុំក្នុងពេលជាង១៤ឆ្នាំ ដែលបានបម្រើការងារក្នុងឋានៈជាអភិបាលក្រុងកំពង់ចាម តែប៉ុណ្ណោះ និងជាឯកសារដំបូង របស់ខេត្តកំពង់ចាម សម្រាប់រួម ចំណែកកំណត់នូវអត្តសញ្ញាណឲ្យបានច្បាស់លាស់របស់ខេត្តនេះ។ ខ្ញុំមានជំនឿថាកម្រងនៃការស្រាវជ្រាវនេះ គឺជាព័ត៌មាន មួយផ្នែកសម្រាប់មនុស្សស្រករក្រោយ ជាពិសេសយុវជន និង យុវនារីនៃខេត្តកំពង់ចាមយើងឲ្យបានដឹងពីដំណើរការវិវត្តន៍ របស់ទឹកដីកំណើតរបស់ខ្លួននៅគ្រប់កាលសម័យ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជាតិកម្ពុជាយើង និងឲ្យកាន់តែមានស្មារតី ស្នេហាជាតិ ស្រឡាញ់ស្រុកកំណើត ដោយរួមគ្នាកសាង ការពារជាតិ និង ស្រុកកំណើតរបស់ខ្លួនឲ្យកាន់តែរីកចម្រើន និងគង់វង្សស្ថិតស្ថេរបើរកាលជានិច្ចនិរន្តរ៍ ។

កំពង់ចាម ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៤

# អត្ថសញ្ញាណនៃពាក្យកំពង់ចាម

មានមតិជាច្រើនបានយល់ថាពាក្យ "*កំពង់ចាម*" មានប្រភពចេញពីពាក្យ "**កំពង់រង់ចាំ**" ។ អ្នកទាំងនេះបានអះអាងថាជាកំពង់រង់ចាំទូកចម្លងទៅត្រើយម្ខាង គឺពីខេត្តកំពង់សៀមទៅខេត្តត្បូងឃ្មុំ ក្នុងសម័យបុរាណ ។ ខ្ញុំមិនបដិសេធនូវការអះអាងនេះទេ តែខ្ញុំយល់ឃើញថា ពាក្យកំពង់រង់ចាំទូកដ ហាក់ដូចជាពុំមានន័យគ្របដណ្តប់ស្របតាមស្ថានភាពសេដ្ឋកិច្ចក្នុងសម័យបុរាណនៅឡើយ ពីព្រោះក្នុងសម័យនោះប្រហែលជាពុំទាន់មានទូកចម្លងធ្វើអាជីវកម្មដូចសព្វថ្ងៃនេះទេ ដោយជាទូទៅប្រជាពលរដ្ឋនៅតាមដងទន្លេមេគង្គមានទូកសម្រាប់ធ្វើជាមធ្យោបាយធ្វើដំណើរ និងប្រកបមុខរបររកស៊ីចិញ្ចឹមជីវិត និងមានអធ្យាស្រ័យល្អរវាងគ្នានិងគ្នាដោយពុំសូវគិតពីអត្ថប្រយោជន៍ចំពោះមុខទេ ។ មតិខ្លះថា កំពង់រង់ចាំទទួលអ្នកមានបុណ្យ ដូចពាក្យ "**ជីហែរ**" ដែលក្លាយមកពីពាក្យ **ចាំហែរ** ជាដើម ។ តែយើងអាចចោទសួរថាកំពង់រង់ចាំអ្នកណា? ឬ ចាំហែរអ្នកណា? អ្នកនោះជាព្រហ្មកិល(ពញាក្រែក) ឬបក្សីចាំ ក្រុង ? ។ តាមពិតអ្នកមានបុណ្យទាំងពីរពុំមានសកម្មភាពទាក់ទង ដោយផ្ទាល់លើភូមិសាស្ត្រទីប្រជុំជនកំពង់ចាមឡើយ ហើយនៅក្នុងប្រវត្តិសាស្ត្រក៏ដូចជាក្នុងរឿងព្រេងនានា ក៏ពុំបានចែងពីការរង់ចាំទទួលអ្នកមានបុណ្យ និងរាជាអង្គណាមួយឡើយ ។ មានមតិមួយទៀតបានលើកឡើងថា " ពាក្យ **កំពង់ចាម** " ប្រែក្លាយមកពីពាក្យថា " **កំពង់សៀម** " ដោយជនជាតិចិននិយាយមិនច្បាស់ថា (កំពង់សាម) រួចហៅថា "កំពង់ចាម" រត់មាត់ទល់សព្វថ្ងៃ ។ ចំពោះទស្សនៈខ្ញុំវិញសូមឯកភាពនិងមតិមួយចំនួន ដែលបានយល់ថា ជា "កំពង់ជនជាតិចាម" ដែលបានប្រមូលផ្តុំតាំងទីលំនៅតាមដង ទន្លេមេគង្គ ដោយបង្កើតបានជាភូមិមួយដែលជាទីប្រជុំជនរបស់

ខេត្តកំពង់សៀមក្នុងសម័យបុរាណ ។ តាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ***ជួន ណាត*** ពាក្យ "*កំពង់*" មានន័យថា ជាទីកន្លែងនៅមាត់ទឹកដែលជនានុជនចុះឡើង ឬចតទូកជាដើម រីឯភាសាម៉ាឡេស៊ីវិញ Kumpung (កំពង់) ប្រែមកថាភូមិ ។ ហេតុនេះពាក្យ "**កំពង់ចាម**" ជាកំពង់ទូក ឬកំពង់ទឹក របស់ជនជាតិចាម ឬជាភូមិចាម ។ វាមិនមែនជារឿងចំឡែកពេកទេនឹងទទួលយកនូវទស្សនៈនេះ ពីព្រោះនៅមានឈ្មោះទីកន្លែងមួយចំនួននៅជិតៗនេះក៏បានរំលេចឈ្មោះជាតិសាសន៍ដទៃដែរ ដូចជា កំពង់សៀម កំពង់លាវ ស្រែសៀម ក្រោលលាវ ...។ល។ តាមការអះអាងពី ព្រះគ្រូ **មាសភន** ចៅអធិការវត្តបទុមរតនៈដីដុះ ជនជាតិចាមបានរស់នៅប្រមូលផ្តុំជាភូមិមួយនៅម្តុំរោងចក្រទឹកកក **សុកហេង** តាំងពីយូរយារមកហើយ រហូតដល់គ.ស ១៩៣៣-៣៥ ទើបរេស៊ីដង់បារាំងបានឲ្យរើទីតាំងមករស់នៅក្នុងភូមិរកាវិញ ដើម្បីកែរលំអរបរិស្ថានតាមមាត់ទឹក និងរៀបចំក្រុងឲ្យមានរបៀបរៀបរយតាមគំនូសប្លង់គោលដែលបានសិក្សាចាប់តាំងពីឆ្នាំ១៩២០ មក ។ ភូមិកំពង់ចាម ពិតជាមានយូរយាណាស់មកហើយ និងអាចជាទីប្រជុំ ជនរបស់ខេត្តបាជយ័ ឬកំពង់សៀម ដែលបានរំលេចក្នុងប្រវត្តិសាស្ត្រនៅគ្រប់កាលសម័យ ។ នៅក្នុងសេចក្តីរាយការណ៍របស់ លោក **លី ធាមតេង** នៅពុទ្ធសាសនបណ្ឌិតស្ដីពីរឿងតាព្រហ្ម នៅវត្តនគរបាជយ័បានបញ្ជាក់ថា អ្នកស្រុកកំពង់ចាម ក្នុងសម័យនោះប្រកបមុខរបរចិញ្ចឹមជីវិតដោយការនេសាទ ដោយធ្វើឆ្នោះ ព្រួល សម្រះ ចាប់ត្រីក្នុងព្រែក។ ការអះអាងនេះពិតជាបានឆ្លុះបញ្ចាំងនូវស្ថានភាពភូមិសាស្ត្រ និងសង្គមសាស្ត្ររបស់កំពង់ចាម ក្នុងសម័យបុរាណ ក្នុងនោះពិតជាមិនអាចកាត់ផ្តាច់ចោលបាននូវជន

ជាតិចាមដែលមានជំនាញខាងនេសាទ និងភាគច្រើនបានប្រមូលគ្នារស់នៅតាមដងទន្លេ។

# អំពីការវិវត្តន៍នៃស្ថានភាពប្រវត្តសាស្រ្តខ្លះៗដែលពាក់ព័ន្ធនឹងខេត្តកំពង់ចាម

ទឹកដីខេត្តកំពង់ចាមបច្ចុប្បន្នបានត្រូវស្នើបង្កើតឡើងដោយលោក **ឌុយកូស** Antoine Etienne Alexandre Ducos ជា ទេសាភិបាលជាន់ខ្ពស់បារាំងប្រចាំប្រទេសកម្ពុជា នៅថ្ងៃពុធ ១៣រោច ខែពិសាខ ឆ្នាំរការ នព្វស័ក ព.ស ២៤៤០ ត្រូវនឹងថ្ងៃទី ១៩ ខែ ឧសភា គ.ស ១៨៩៧ ក្នុងរជ្ជកាលព្រះ**នរោត្តម** ដោយរួមបញ្ចូល ខេត្តត្បូងឃ្មុំ កំពង់សៀម ជើងព្រៃ កងមាស កោះសូទិន មួយ ភាគនៃស្វាយរមៀត ( ប្រហែលជាស្រុកស្រីសន្ធរបច្ចុប្បន្ន ) និង ក្រោយមកទៀតមានខេត្តស្ទឹងត្រង់ ដែលត្រូវកាត់ចេញពីការគ្រប់គ្រងរបស់ទេសាភិបាលបារាំងខេត្តក្រចេះ ។

ក្នុងសម័យបុរាណ ការគ្រប់គ្រងដែនដីនៃប្រទេសកម្ពុជា មានការវិវត្តន៍ប្រែប្រួលតាមសម័យកាលនិមួយៗ ក្នុងនោះ ខេត្ត ត្បូងឃ្មុំ មានវិសាលភាពធំទូលាយ ដែលដឹកនាំដោយក្សត្រាដ៏ មានឥទ្ធិពល ដែលជាព្រះញាតិរបស់ព្រះមហាក្សត្រ។ ក្នុងសម័យ បឋមវង្ស *ត្បូងឃ្មុំ* ជាទឹកដីកសាមន្តរាជដែលគ្រប់គ្រងដោយព្រះ បរមិន្ទវរ្ម័ន ជាបុត្រាព្រះអស្សចយ័រាជដែលចាញ់សង្គ្រាមព្រះកុមេ រុរាជ (ព្រះថោង) ។ ក្នុងរជ្ជកាលព្រះកេតុមាលា ព្រះអង្គបានតែង តាំងព្រះរាជបុត្រាព្រះនាម

**ពញាអរ** ជាស្ដេចត្រាញ់ខេត្តត្បូងឃ្មុំ ដែលមានគោរម្យងារជាសម្ដេចចៅពញា **អរជូន** ហើយបន្ដការគ្រប់គ្រងទឹកដីនេះអស់ ៨ ដំណរ។ ក្នុងសម័យព្រះ**ធម្មា សោករាជ** ព្រះអង្គបានតែងតាំងព្រះ**រាជនត្តា** ( ចៅ ) របស់ព្រះអង្គ ព្រះនាមព្រះអង្គ**កែម** ជាស្ដេចត្រាញ់ខេត្តត្បូងឃ្មុំ ដោយមានងារជាសម្ដេចចៅពញា**អរជូន** ព្រះអង្គ**កែម** ដែលក្នុងសមយ័នោះហើយមានការកសាងវត្តព្រះធាតុព្រះស្រី ក្នុងស្រុកអូរាំងឪ បច្ចុប្បន្ន។ ក្នុងប្រវត្តិសាស្ត្រកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ណាស់ថា ទឹកដីខេត្តកំពង់ ចាម ជាមូលដ្ឋាននៃការកសាងកម្លាំងដើម្បីរំដោះជាតិមាតុភូមិពី ការគ្រប់គ្រងរបស់ពួកឈ្លានពានបរទេស និងពីរបបប្រល័យពូជ សាសន៍ ។ ក្នុងសម័យដែលអាណាចក្រ **ចេនឡា** ត្រូវបានបែក បាក់ ប្រទេស***ជ្វា*** ក្នុងរាជវង្ស**សៃលេន្ទ្រ** បានដាក់ការត្រួតត្រា លើ ប្រទេសកម្ពុជា ព្រះបាទ**ជយ័វរ័ន្មទី២** បានលបភៀសព្រះកាយ មកគង់នៅ**ឥន្ទ្របុរះ** ( អាចនៅក្នុងភូមិសាស្ត្របន្ទាយព្រៃនគរ ក្នុង ស្រុកពញាក្រែក ) ដែលនៅទីនោះព្រះអង្គបានទទួលព្រាហ្មណ៍ ឈ្មោះ **សិវកៃវល្យ** ជាព្រះរាជបរោហិតដែលបានជួយគាំពារព្រះ អង្គ ក្នុងការរំដោះជាតិចេញពីនឹមត្រួតត្រារបស់ជ្វាបានទាំងស្រុង ក្នុង គ.ស ៨០២ និងបានកសាងនូវលទ្ធិទេវរាជ ដែលជាគ្រឹះដ៏រឹងមាំនៃអាណាចក្រអង្គរ ។ ក្នុងរជ្ជកាលព្រះបាទ **លំពង្សរាជា** ពួកឈ្លានពានសៀមក៏បានវាយលុកចូលក្រុងអង្គរ និងតាំងព្រះចៅ **បាសាត** ព្រះចៅ**បាអាត** ព្រះចៅ**កំបង់ពិស** ដែលជាបុត្រាស្ដេចសៀមរាមាធិបតីឲ្យសោយរាជ្យនៅកម្ពុជា ជាបន្តបន្ទាប់ ពី គ.ស ១៣៥៣ ដល់ ១៣៥៩ ។ ព្រះ**សុរិយោវង្ស** ដែលជាឧបរាជបាន

ភៀសព្រះកាយមកកសាងកម្លាំងនៅទួលបាសាន ស្រុកស្រីសន្ធរ និងបានវាយកំទេចបច្ចាមិត្ររលំរលាយទាំងស្រុងនៅ ឆ្នាំ ១៣៥៩ ទឹកដីទាំងមូលទទួលបាននូវឥស្សរភាព ។ សៀមនៅតែបន្តធ្វើការឈ្លានពានពង្រីកទឹកដីទៀតក្នុងសម័យស្តេច**នរេសូរ** ដោយធ្វើការឡោមព័ទ្ធទីក្រុងអង្គរអស់រយៈពេល៧ខែ និងបានប្រើប្រាស់នូវឧបាយកលទុច្ចរិតក្នុងការវាយលុកចូលទីក្រុងក្នុង គ.ស ១៣៩៣ និងចាត់តាំងព្រះ**ឥន្ទរាជា** ជាបុត្រាឲ្យគ្រប់គ្រងកម្ពុជា។ ព្រះចៅ**ពញាយ៉ាត** បានជ្រើសរើសទួលបាសាន ស្រុកស្រីសន្ធរធ្វើជាមូលដ្ឋាននៃការរៀបចំកម្លាំងដើម្បីរំដោះជាតិទាំងស្រុងក្នុងរយៈពេលដ៏ ខ្លីបំផុត ។

***កំពង់ចាម*** ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងភូមិសាស្ត្រនយោបាយ និងយោធារបស់ប្រទេសកម្ពុជា នៅគ្រប់កាលសម័យដែលបានចរឹកក្នុងប្រវត្តិសាស្ត្រ និងជាទឹកដីនៃការបដិវត្តន៍វប្បធម៌ដោយលើកតម្កើងនូវតួនាទីរបស់ស្ត្រី តាមរយៈប្រវត្តិភ្នំស្រីភ្នំប្រុស និងការប្រឆាំងទ្រឹស្តី*នំមិនធំជាងនាឡី* របស់វីរភាពគូរស្នេហ៍ដ៏ល្បី រន្ធឺ ***ទុំនិងទាវ*** នៅក្នុងសម័យលង្វែក។ ទន្ទឹមនឹងនេះ ទឹកដីខេត្ត កំពង់ចាម ត្រូវបានជ្រើសរើសជាទីតាំងរាជធានីប្រទេសកម្ពុជា
ក្នុងសម័យក្រោយអង្គរ មានទួលបាសាន ស្រុកស្រីសន្ធរ ចំនួន ៧ រជ្ជកាល និង ស្រឡប់ពិជយ័ព្រៃនគរ ក្នុងរជ្ជកាលព្រះស្រី **ជេដ្ឋា ធិរាជ** (ហ្លួងព្រះស្តេចកន) ។ ក្នុងចំណោមអាណាខេត្តក្នុងសម័យ បុរាណដែលប្រមូលផ្តុំជាទឹកដីខេត្តកំពង់ចាម នាសម័យអាណានិគមនិយមបារាំង ខេត្តត្បូងឃ្មុំ ស្រីសឈរ(ទួលបាសាន) កំពង់សៀម និងជើងព្រៃ បានរំលេចបាននូវសកម្មភាពជាប្រវត្តិសាស្ត្រ

គួរឲ្យកត់សំគាល់ជាច្រើនក្នុងអតីតកាល។ ក្នុងសង្គ្រាមឈ្លានពានដ៏រ៉ាំរ៉ៃរបស់សៀម នៅបន្ទាយលង្វែក សម្តេចរាមាធិបតី **អុង** ដែលជាព្រះវង្សដ៏មានឥទ្ធិពល គង់នៅខេត្តជើងព្រៃ បានទទួលនូវដាវអាជ្ញាសឹកពីព្រះ**សត្ថាទី១** ដើម្បីកេណ្ឌពលតាមបណ្តាខេត្តទៅជួយទម្លាយការឡោមពទ្ធ័ពីសត្រូវ តែអាស្រ័យដោយការសប្បាយភ្លើតភ្លើនហួសហេតុ នាំឲ្យភារកិច្ចដ៏សំខាន់នេះ បានអូសបន្លាយរហូតដល់បន្ទាយលង្វែក ត្រូវសៀមវាយលុកចូលបំផ្លិចបំផ្លាញបានទាំងស្រុងនៅគ.ស ១៥៩៣ ទម្រាំដល់ឆ្នាំ១៥៩៤ ទើបព្រះអង្គបានប្រមូលទ័ពដេញកំចាត់សត្រូវ រួចឡើងគ្រងរាជ្យនៅទួលបាសានដោយដាក់ព្រះនាមថា **រាមាជើងព្រៃ** ។ ស្តេចអង្គនេះ ត្រូវបានពួកទាហាន**អេស្បាញ** ដឹកនាំដោយ**វេឡូសូ** ( Véloso ) ធ្វើគត់ ដែលជាផលវិបាកនៃជម្លោះពាណិជ្ជកម្មចិន និងអេស្បាញ នៅថ្ងៃទី ១២ មេសា ១៥៩៦ ។ ខេត្តកំពង់ចាម ធ្លាប់រងនូវសង្គ្រាមក្នុងស្រុកជា ច្រើនលើកក្នុងនោះមានសង្គ្រាមដណ្តើមរាជ្យ ( ១៤៧៥-១៤៨៥ ) រវាងព្រះ**ស្រីរាជា** ព្រះ**ស្រីសុរិយោទយ៍** និងព្រះ**ស្រីធម្មោរាជា** ដែលបំបែកប្រទេសជាបីតំបន់ត្រួតត្រា និងចម្បាំងរវាងព្រះ**ស្រីសុគន្ធបទ**និង**ស្តេចកន** (១៥០៩-១៥១២) រវាង **ស្តេចកន** និង**ព្រះចន្ទ រាជា** (១៥១៦-១៥២៥)។ ក្នុងសម័យប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង ខេត្តកំពង់សៀម និងខេត្តត្បូងឃ្មុំ គឺជាមជ្ឈមណ្ឌលរដ្ឋបាលយ៉ាងសំខាន់នៅត្រើយខាងកើត និងខាងលិចទន្លេមេគង្គ ។ ខេត្តកំពង់សៀម មានទីតាំងរដ្ឋបាលនៅក្នុងមន្ទីរផែនការបច្ចុប្បន្ន រីឯខេត្តត្បូងឃ្មុំ មានទីតាំងរដ្ឋបាលនៅក្រុងសួង ។ នៅមុនសម័យអាណាព្យាបាលបារាំង ក្នុងរជ្ជកាល ព្រះ

**ឥស្សរាធិបតីអង្គដួង** ក្នុងអំឡុងគ.ស ១៨៤៨ ព្រះអង្គបានរៀបចំរដ្ឋបាលដែនដីជា ៥៤ខេត្ត និងរៀបចំមន្ត្រីសេនាបតីទទួលកំណាន់ខេត្ត ក្នុងនោះខេត្តជើងព្រៃ កំពង់សៀម និងស្ទឹងត្រង់ត្រូវឡើងត្រង់ទៅឧកញ៉ា**ជហ្វាទឡ្ហៈ** ខេត្តត្បូងឃ្មុំ ត្រូវឡើងត្រង់ទៅឧកញ៉ា**វាំង** ខេត្តស្រីសឈរឆ្វេង ត្រូវឡើងត្រង់ទៅឧកញ៉ាស្រី**ធម្មាធិរាជ** ។ ក្នុងសម័យនោះ ខេត្ត*ត្បូងឃ្មុំ*ជាទឹកដីដែលរងនូវអសន្តិសុខខ្លាំងជាងគេ តាមរយៈការប៉ុនប៉ងស្វែងរកស្វ័យភាពរបស់ពួកចាម ជ្វា និងការបះបោរបស់ព្រះអង្គ**ស៊ីវុត្ថា** អាចារ្យលាក់ កំហែងយោធា...។ ក្នុងសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជារបស់លោក**អេដេម៉ាឡឺក្លែរ** (Edhémard Leclere) បានអះអាងថា ពួក ចាមជ្វានៅត្បូងឃ្មុំ បានរើបម្រាស់ក្នុងការបង្កើតរដ្ឋស្វ័យយ័ត ចំនួន ២លើក គឺនៅគ.ស ១៥៩៩ម្តង និង គ.ស ១៦៦០ ម្តង។ ពួកនេះគេគោរពតែមេដឹកនាំរបស់គេតែប៉ុណ្ណោះ ដោយព្រងើយកន្តើយនឹងទទួលយកការដឹកនាំរបស់មន្ត្រីខ្មែរ ។ នៅដើមត្រីមាស ទី៤ គ.ស ១៨៥៨ បងប្អូនបង្កើត ៤នាក់ ដែលជា ចាម ជ្វា ដ៏មានឥទ្ធិពល មានសម្តេច **បូទេសលី** ឧកញ៉ា **បវរអន្សាហ៊ឹម** ឧកញ៉ា **សេនាចក្រពត្រ័សូរ** និង**ទួនស្អិត** បានបំបះបំបោរពួកចាម ជ្វា នៅភូមិសេះសំបូរ និងភូមិរកាប្រាំបី ករជាទ័ពដេញកំចាត់ ឧកញ៉ា **ពិភក្តិឥស្សរាភោគ** ជាព្រះរាជអាជ្ញាហ្លួង ឈរនៅខេត្ត ត្បូងឃ្មុំ ដែលញ៉ាំងឲ្យព្រះ **ឥស្សរាធិបតី អង្គដួង** លើកទព័ដោយអង្គឯងមកបោះនៅពាមជីលាំង កំចាត់ពួកបះបោរឲ្យវិនាសខ្ទាត់ខ្ទាយទៅជ្រកនៅក្នុង ខេត្តចូវដុក ដោយបង្កើតបានជាភូមិចាម ៥ នៅទីនោះ។ ព្រះមហាក្សត្របានប្តូរឈ្មោះពាមជីលាំង ឲ្យហៅថា

"**ពាមមង្គល**" ពីពេលនោះមក ។ ក្នុងរជ្ជកាលព្រះនរោត្តម នៅក្នុង គ.ស ១៨៦១ **ស្នងសូរ** និង**មនោកែវ** ដែលស្និទ្ធនឹងព្រះ**ស៊ីវត្ថា** បាននាំអ្នកស្ម័គ្រស្មោះរបស់ខ្លួនចំនួន ២៤ នាក់ ចូលក្នុងភូមិសាស្ត្រខេត្តកំពង់សៀម ត្រង់ចំណុច ភូមិកំពង់ចាម រួចឆ្លងទៅសំណាក់នៅភូមិទន្លេបិទ ខេត្តត្បូងឃ្មុំ ហើយបង្ហួសដំណើរទៅកែនទព័នៅស្រុកកំណើតខ្លួន នៅខេត្តបាភ្នំ ដើម្បីដណ្ដើមរាជ្យសម្បត្តិពីព្រះ **នរោត្តម** យកទៅថ្វាយព្រះ**ស៊ីវុត្ថា** ។ ចលនាបះបោរនេះ បានបង្ក ការរីករវជាខ្លាំង ដែលនាំឲ្យព្រះមហាក្សត្រសម្រេចព្រះទ័យយាង ទៅគង់នៅឯខេត្តបាត់ដំបង ដែលកាលណោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម ។ ក្នុងកាលៈទេសៈដ៏តានតឹងនេះ បងប្អូន ចាម ជ្វា ទាំង៤នាក់ ដែលគេចខ្លួនទៅខេត្តចូវដុក បានប្រមូលគ្នីគ្នាទៅខេត្តបាត់ដំបងដើម្បីសុំចុះចូលបម្រើព្រះមហាក្សត្រដោយព្រះអង្គរក្សានូវគោរម្យងារពីមុនដដែល ហើយថែមទាំងតែងតាំងឧកញ៉ា**សូរ** ជាឧកញ៉ា**អរជូន**ចៅហ្វាយខេត្តត្បូងឃ្មុំថែមទៀតផង។ នៅ គ.ស ១៨៦៦ ជនក្បត់ឈ្មោះ**លាក់** តាំងខ្លួនជាអ្នកកាន់សីល ( អាចារ្យលាក់) បានបញ្ចុះបញ្ចូលពួកកួយ ស្ទៀង និងខ្មែរលើ បង្កជាកម្លាំងទ័ពវាយបន្ទាយបារាំងនៅខេត្តរោងដំរី រួចក៏បានបង្វែរសកម្មភាពចូលខេត្តត្បូងឃ្មុំ ដោយជួបប្រយុទ្ធបំបែកការទប់ស្កាត់របស់ទព័ឧកញ៉ា**អរជូនសូរ** ។ ដោយត្រូវរបួស លោកឧកញ៉ា **សូរ** បានត្រូវពលទាហានគ្រារត់ឆ្លងទូក កាត់ទន្លេមកសម្រាកព្យាបាលនៅខេត្តកំពង់សៀម រួចគាត់វិលទៅដឹកនាំការប្រយុទ្ធម្តងទៀត ហើយបានស្លាប់ក្នុងសមរភូមិ។ ក្រោយពីបានទទួលដំណឹងមរណភាពរបស់លោកឧកញ៉ា**អរជូនសូរ** ព្រះបាទ**នរោត្តម** បានតែងតាំង

លោកឧកញ៉ា **ពិភក្តិទិព្វរាជរស់** ឲ្យឡើងយសជាឧកញ៉ាអរជូន ឈររក្សានៅខេត្តត្បូងឃ្មុំ។ ចលនាបះបោររបស់អាចារ្យលាក់ បានបង្កនូវអស្ថេរភាពនៅស្ទើរតែគ្រប់ខេត្តប៉ែកខាងកើត ដែលទាក់ទាញឲ្យមានអន្តរាគមន៍របស់បារាំង និងការយាងចាកចេញពីក្រុងព្រៃនគរ របស់ព្រះ **កែវហ្វាស៊ីសុវត្ថិ** មកដឹកនាំកងទព័ដោយអង្គ ឯងផ្ទាល់ដោយវាយបំបាក់ពួកបះបោរឲ្យខ្ចាត់ខ្ចាយចេញពីខេត្ត រំដួល ស្វាយទាប បាភ្នំ និងព្រៃវែង រួចព្រះអង្គបានបោះទ័ពនៅ ពាមមង្គល ក្នុងខេត្តត្បូងឃ្មុំ ។ នៅថ្ងៃច័ន្ទ ៥កើត ខែស្រាពណ៍ ឆ្នាំថោះ នព្វស័ក គ.ស១៨៧៥ នៅវេលាម៉ោង ៧ព្រឹក ព្រះបាទ **នរោត្តម** ព្រះមហាក្សត្រនៃប្រទេសកម្ពុជាអមដោយមេទ័ពបារាំង ឈ្មោះ **ប៉ូទីយេ**. Potier បានយាងតាមនាវាមកសាកសួរសុខទុក្ខ ព្រះអនុជដល់ពាមមង្គល។ នៅគ.ស ១៨៧៦ ព្រះករុណាព្រះបាទ **នរោត្តម** ទ្រង់បានតែងតាំងលោកឧកញ៉ា**ឫទ្ធីក្រៃស៊ីរ** មកគ្រប់គ្រងខេត្តកំពង់សៀម យើងមិនបានដឹងថាឥស្សរជនណាជាអ្នកបន្តវេនពីលោកទេ គ្រាន់តែកំណត់បានថា នៅក្រោយឆ្នាំ ១៩០២ លោក ឧកញ៉ា



**នូ កន** បានមកទទួលដំណែងជាចៅហ្វាយ ខេត្ត កំពង់ សៀម ក្រោយពេលដែលរូបគាត់បានបញ្ចប់កម្មសិក្សានៅប្រទេស បារាំង ។

លោកឧកញ៉ា ***នូ កន*** មានកំណើតនៅ ឆ្នាំ ១៨៧៤ នៅអង្គតាសោម ស្រុកត្រាំកក់ ខេត្ត តាកែវ គាត់បានចូលរៀននៅសាលាវត្តត្នោត នៅឆ្នាំ ១៨៨៣ និងបានបួសជាសាមណេរនៅ ឆ្នាំ១៨៨៨ បានមួយវស្សា

និងបានចូលបម្រើជា ស្មៀនចៅហ្វាយខេត្តទ្រាំង ក្នុងអាយុ ១៧ ឆ្នាំ ។ នៅក្នុងឆ្នាំ១៨៩១ លោកបានចូលបម្រើការងារនៅព្រះបរមរាជវាំងបាន ៤ឆ្នាំ រួចបាន ផ្លាស់មកបម្រើការនៅក្រសួងសុរិយោដី និងក្រសួងរតនាគារ ។ នៅឆ្នាំ១៩០២ គាត់ប្រឡងជាប់លេខ១ ខាងអក្សរសាស្ត្រ ត្រូវបាន រដ្ឋបាលបារាំងបញ្ជូនទៅសិក្សាផ្នែកច្បាប់នៅប្រទេសបារាំង និង ត្រូវបានតែងតាំងជាចៅហ្វាយខេត្តកំពង់សៀម នៅពេលត្រឡប់ មកវិញ។ យើងមិនបានដឹងថាគាត់ជាប្រមុខខេត្តកំពង់សៀម យូរ ប៉ុណ្ណានោះទេ តែយើងបានដឹងថា ក្រោយពីគាត់បានចេញពីមុខ ដំណែង គាត់បានទៅបម្រើការងារជាចាងហ្វាងសាលាដំបូង រួច ជា ចាងហ្វាងសាលាឧទ្ធរណ៍ និងជារដ្ឋលេខាធិការនៅក្រសួង កសិកម្ម ។ នៅឆ្នាំ ១៩៤៥ លោកបានជាប់ឆ្នោតជាតំណាងរាស្ត្រ មណ្ឌលកោះសូទិន និងបានចូលមរណភាពនៅឆ្នាំ ១៩៤៧ នៅ គេហដ្ឋានលោកក្នុងក្រុងកំពង់ចាម ។ លោកគឺជាកវីនិពន្ធដ៏ឆ្នើម ដែលបានបន្សល់ទុកនូវវណ្ណកម្មជាច្រើន ក្នុងនោះមានរឿង**ទាវឯក** រឿង**តុងឈិន** រឿង**សាមកុក** (បកប្រែពីភាសាថៃ) រឿង**ឥណាវ ពិម្ពាពិលាភ**...។ តាមប្រភពព័ត៌មានខ្លះបានអះអាងថា លោក ឧកញ៉ា ***នូ កន*** បានព្យាយាមមិនបានសម្រេចក្នុងការកសាងវត្ត ធម្មយុត្តិមួយនៅភ្នំប្រុស ហើយបានផ្តួចផ្តើមការកសាងវត្តសុទស្ស នារាមជ្រោយថ្ម នៅឆ្នាំ១៩១៥ ដោយមានការចូលរួមយ៉ាងសកម្ម ពីលោក **គង់ ឃួន** លោក **នុត ពេញ** និងលោក **តេង ហាយប៉ា** ។ តាមសេចក្តីសន្និដ្ឋានរបស់ខ្ញុំ លោកឧកញ៉ា**នូ កន** ពិតជាបានកាន់ មុខដំណែងជាអភិបាលខេត្តកំពង់សៀមជាច្រើនឆ្នាំ ក្នុងអាណាត្តិ ទេសាភិបាលបារាំងជាច្រើននាក់ ដែលឈរជើងនៅប៉ុស្តិ៍កំពង់ ចាម

ក្នុងនោះមានលោក **ហ្វ្រាំងសវ័ បូដូវាំង** (Francois Marius Baudoin ) ផងដែរ ។



លោក**បូដូវាំង** បានមកកាន់មុខដំណែងជាទេសាភិបាលនៅប៉ុស្តិ៍កំពង់ចាម នៅចន្លោះ ឆ្នាំ (១៩០៥- ១៩០៧ ) គឺក្នុងរយៈពេលនេះ ដោយមានជំនួយពីលោកវេជ្ជបណ្ឌិត **បែរណា មឺណូត៍** ( Brenard Menaut ) ប៉ុស្តិ៍រដ្ឋបាលកំពង់ចាមទទួលបាននូវស្ថានភាពល្អប្រសើរចំពោះវិសយ័សុខាភិ បាល តាមរយៈការបន្សុីគ្នារវាងឱសថខ្មែរ និងបារាំង និងការទាក់ ទាញប្រជាពលរដ្ឋឲ្យមកទទួលនូវសេវាសុខាភិបាល ។ លោក **បូដូវាំង** បានកាន់មុខដំណែងជាអគ្គទេសាភិបាលប្រចាំប្រទេសកម្ពុជានៅឆ្នាំ ១៩១១ រួចបានទទួលមុខដំណែងជាអគ្គទេសាភិបាលស្តីទីប្រចាំឥណ្ឌូចិននៅឆ្នាំ ១៩២២ ។ ក្នុងអាណត្តិដ៏យូរជាទេសាភិបាលជាន់ខ្ពស់ប្រចាំប្រទេសកម្ពុជា លោក **បូដូវាំង** មានអធ្យាស្រ័យល្អ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបាទ **ស៊ី សុវត្ថិ** ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដោយសម្រេចបាននូវកំណែទម្រង់រដ្ឋបាល និងតុលាការ ព្រមទាំងការអភិរក្សសិល្បៈវប្បធម៌ជាតិ ។ ដោយមានការជួយជ្រោមជ្រែងពីលោក **ហ្សក័ ហ្គ្រោលីយេ**(GeorgeGroslier) សារមន្ទីរជាតិបានចាប់ផ្តើមកសាងនៅថ្ងៃទី១៧ សីហា ១៩១៧ និងត្រូវសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃចូលឆ្នាំទី១ គឺថ្ងៃទី ១៣ មេសា ១៩២០ ។ លោកថែមទាំងបានបង្កើតសាលាក្រមការ សម្រាប់បណ្តុះបណ្តាលមន្ត្រីតាម ខេត្ត និងបានកំណត់មុខងារសំរាប់ចៅហ្វាយខេត្តនៅឆ្នាំ១៩១៥។

ក្នុងសម័យនោះ ប្រទេសកម្ពុជាមាន៥១ខេត្ត ដែលរដ្ឋបាលខេត្តនិមួយៗដឹកនាំដោយចៅហ្វាយខេត្តចំនួន ១រូប មានបាឡាត់ យោក្បត្រ៍ ស្នងនិងក្រឡាពាសជាជំនួយការ ។ សាលាដំបូងបានត្រូវបង្កើតនៅគ្រប់ខេត្តទាំង ៥១ ក្នុងរជ្ជកាលព្រះ**ស៊ីសុវត្ថិ** ។ ក្នុងសមយ័នោះ ទេសាភិបាលបារាំងមានអំណាចយ៉ាងទូលំទូលាយក្នុងការត្រួតត្រានូវរាល់សកម្មភាពរដ្ឋបាល តុលាការ និងសេដ្ឋកិច្ចក្នុងដែនប៉ុស្តិ៍រដ្ឋបាលរបស់ខ្លួន តាមរយៈការដាក់ឲ្យមន្ត្រីបារាំងនៅអមត្រួតពិនិត្យតាមវិសយ័នានាយ៉ាងម៉ត់ចត់បំផុត។ ប៉ុស្តិ៍រដ្ឋបាលកំពង់ចាម បានទាក់ទាញនូវចំណាប់អារម្មណ៍ជាខ្លាំងពីសំណាក់ បារាំងតាមរយៈសក្តានុពលរបស់ដីក្រហម ដែលអំណោយផលដល់ដំណាំកៅស៊ូ ។ នៅឆ្នាំ ១៨៩៧ ដើមកៅស៊ូត្រូវបានឱសថការីបារាំងឈ្មោះ **រ៉ាអ៊ូល** នាំមកពីប្រទេសម៉ាឡេស៊ី មកដាំនៅ ព្រៃនគរ និងបានចាប់ផ្តើមរីកសាយភាយនៅជប់ពីឆ្នាំ ១៩២១មកក្នុងនោះកម្មករបច្ចេកទេសភាគច្រើនជាជនជាតិវៀតណាម។ ការរីកចម្រើនក្នុងដំណាំកៅស៊ូ បានជម្រុញដល់ការកែរលំអររចនាសម្ពន័រដ្ឋបាល និងប្រព័ន្ធហេដ្ឋារចនាសម្ពន្ធ័នៅក្នុងប៉ុស្តិ៍រដ្ឋបាលកំពង់ចាម។ ក្នុងរជ្ជកាលព្រះ**ស៊ីសុវត្ថិ** និងក្នុងអាណត្តិជាអភិបាលខេត្តរបស់លោកឧកញ៉ា **នូ កន** ជាចៅហ្វាយខេត្តកំពង់សៀម និងលោកឧកញ៉ា **ញឹក** ( ឪពុកសម្តេចចក្រី **ញឹក ជូឡុង** ) ជាចៅហ្វាយខេត្តជើងព្រៃ ផ្លូវជាតិលេខ៦ និងលេខ៧ ត្រូវបានកសាងតាមរយៈកំណែនប្រជាពលរដ្ឋដ៏តឹងរ៉ឹងបំផុត ។ ក្នុងសមយ័នោះ ប្រជាពលរដ្ឋត្រូវជាប់កាតព្វកិច្ចដ៏ធ្ងន់ធ្ងរពីរ គឺ កំណែនក្នុងការ ស្ថាបនាផ្លូវ និង កំណែនយោធា ដែលបារាំងកេណ្ឌទៅចូលរួម

ប្រយុទ្ធនៅសមរភូមិអឺរ៉ុប ក្នុងសង្គ្រាមលោកទី១ ។ ភូមិមេម៉ាយនៅក្នុងសង្កាត់បឹងកុកបច្ចុប្បន្ន គឺជានិម្មិតរូបនៃផលវិបាករបស់កំណែនទាំងពីរនេះ ដែលបុរសៗជាប្ដីត្រូវបានរងនូវកំណែនស្ទើរតែទាំងអស់ បន្សល់ទុកនូវស្ត្រីនៅចាំផ្ទះ ដែលភាគច្រើនជាស្រីមេម៉ាយដោយប្ដីជាទីស្រឡាញ់របស់ខ្លួនបានបាត់បង់ជីវិតដោយជម្ងឺ និងបាក់កម្លាំងនៅការដ្ឋាន និងត្រូវស្លាប់ក្នុងសមរភូមិក្នុងជួរកងទ័ពបារាំងក្នុងសង្គ្រាមលោកលើកទី១ ។ បន្ទុកដ៏ធ្ងន់ធ្ងរទាំងពីរគួបផ្សំនឹងការតម្លើងពន្ធដារ ដើម្បីប្រមូលលុយទៅចំណាយក្នុង សង្គ្រាមបានញ៉ាំងឲ្យប្រជាកសិករខ្មែររងនូវការលំបាកជាខ្លាំង ដែលធ្វើឲ្យផ្ទុះនូវការតវ៉ាជាទូទៅចំពោះមុខព្រះមហាក្សត្រនាចុងឆ្នាំ១៩១៥ រហូតដល់ដើមឆ្នាំ ១៩១៦ និងបានស្ងប់ស្ងាត់ឡើងវិញក្រោយពេលដែលព្រះបាទ **ស៊ីសុវត្ថិ** បានសម្រេចព្រះទ័យលប់ចោលនូវកំណែនទាំងនេះ ។ តាមការអះអាងអំពីមហាជនដែលមានវ័យចំណាស់ ធ្លាប់ទទួលព័ត៌មានពីសំណាក់បុព្វការីជនរបស់ ខ្លួនយើងអាចសន្និដ្ឋានបានថា **ទីក្រុងកំពង់ចាម** ត្រូវបានក្លាយជាមជ្ឈមណ្ឌលរដ្ឋបាលយ៉ាងសំខាន់ចាប់តាំងពីឆ្នាំ១៩២០ មកដោយបារាំងបានចាប់ផ្ដើមធ្វើការសិក្សា ***ឋានលេខា*** ( Topographie ) រហូតដល់ឆ្នាំ១៩៣០ ទើបបានចប់ជាស្ថាពរដោយកំណត់បាននៅលើផែនទីនូវបណ្ដាញផ្លូវ បណ្ដាញលូបង្ហូរទឹក តំបន់រដ្ឋបាល តំបន់ពាណិជ្ជកម្ម តំបន់លំនៅដ្ឋាន..។ល។ គឺក្នុងពេលនោះហើយដែលបណ្ដាខេត្តទាំងអស់ក្នុងប៉ុស្ដិ៍រដ្ឋបាលបារាំង ត្រូវបានប្រមូលផ្ដុំបង្កើតបានជាខេត្តកំពង់ចាម។ នៅក្នុងអត្ថបទឯកសារមួយក្នុងសៀវភៅកម្ពុជាសុរិយាបានសរសេរថា នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩២៧

តំណាងអ្នកខេត្តកំពង់ចាម បានធ្វើដំណើរតាមកប៉ាល់ ៤ និងទូកសណ្តោងជាច្រើន បានហែរគម្ពីចំនួន ២៣៣មុខ ព្រះពុទ្ធរូបមាសចំនួន ២០ ព្រះពុទ្ធរូបប្រាក់២១ និងវត្ថុដ៏មានតម្លៃជាច្រើនមុខទៅតំកល់ទុកក្នុងរាជបណ្ណាល័យ ដែលត្រូវទទួលដោយសម្តេចក្រុមព្រះ**កែវហ៊្វាមុនីវង្ស** ។ យោងតាមសេចក្តីរាយការណ៍របស់ លោក **លី ធាមតេង** នៅពុទ្ធសាសនបណ្ឌិតបានឲ្យដឹងថា រវាង ពុទ្ធសករាជ ២៤៧០ ប្លាយ (ប្រហែលជាក្នុងឆ្នាំ១៩២៧?) មានពួកអ្នកជំនួញនៅក្នុងក្រុងកំពង់ចាម បាននាំគ្នាបង្វិលរូបថ្មតាព្រហ្មឲ្យបែរមុខទៅខាងត្បូងឲ្យត្រូវតាមទំនងផ្លូវចូល បណ្តាលឲ្យអ្នកស្រុកមានជម្ងឺនិងស្លាប់ជាច្រើន ។ កាលណោះខ្មោចតាព្រហ្ម បានចូលរូបយាយដាម នៅក្នុងភូមិសណ្តាន់ ឃុំអំពិល ស្រុកកំពង់សៀមខេត្តកំពង់ចាម ស្រែកប្រាប់អ្នកស្រុកថា កុំបំបែរមុខរូបអញទៅ ឯណាត្រូវតែបែរមុខទៅទិសខាងលិចសំពះឆ្ពោះទៅចេតីយខ្មោច ម្តាយអញវិញ ។ ក្រោយមកអ្នកស្រុកបាននាំគ្នាបំបែររូបតាព្រហ្មដូចដើមវិញមកទល់សព្វថ្ងៃ។ ចំណែកឯយាយដាមវិញ ដោយទឹកទន្លេមេគង្គចេះតែជន់លិចភូមិរៀងរាល់ឆ្នាំ គាត់បានរើផ្ទះមករស់លើដីទួលមួយកន្លែងក្នុងភូមិបឹងកុក ឃុំរអាង ស្រុកកំពង់សៀម ហើយទីនោះ គេនាំគ្នាហៅថាទួលយាយដាមរហូតដល់សព្វថ្ងៃ ។ ការរៀបរាប់ខាងលើនេះ គ្រាន់តែចង់បញ្ជាក់ឲ្យកាន់តែច្បាស់ថាចាប់តាំងពីឆ្នាំ ១៩២០មក កំពង់សៀមក្តី ត្បូងឃ្មុំក្តី ....លែងមានឈ្មោះជាខេត្តតទៅទៀតហើយ គឺគ្រាន់តែជាស្រុកក្នុងប្រព័ន្ធរដ្ឋបាលថ្មីរបស់បារាំង ដែលមានទីក្រុងកំពង់ចាម ជាមជ្ឈមណ្ឌលនិងជាឈ្មោះរបស់ខេត្ត និងមានទេសាភិបាលបារាំងជាអ្នកគ្រប់ គ្រង ។

ចំពោះចៅហ្វាយខេត្តខ្មែរវិញ យើងមានបញ្ជីឈ្មោះតាមអណត្តិចាប់តាំងពីឆ្នាំ១៩៣៥មក ដែលខ្ញុំនឹងជូនជាប្រវត្តិរបស់សាមីខ្លួនខ្លះៗ ដោយយោងតាមឯកសារមួយចំនួនដែលខ្ញុំខិតខំព្យាយាមស្រាវជ្រាវឃើញ និងសង្ឃឹមថា អស់លោកអ្នកអាចនឹង បំពេញ និងអាចកែរតម្រូវឲ្យកាន់តែត្រឹមត្រូវថែមទៀតដើម្បីទុកជា
ឯកសារសម្រាប់អ្នកស្រែករក្រោយរបស់យើង។

## ថ្នាក់ដឹកនាំខេត្តកំពង់ចាម ពីសម័យ
## អាណានិគមនិយមបារាំងមកទល់បច្ចុប្បន្ន

### ១- ថ៉ា គមម៉ុល ( ១៩៣៥-១៩៣៦)

យើងមិនបានដឹងពីប្រវត្តិរបស់គាត់ច្បាស់ទេ តែអាចស្មាន បានថា គាត់ជាមន្ត្រីដ៏សំខាន់ដែលទទួលនូវការបណ្តុះបណ្តាលពី រដ្ឋបាលបារាំង ។ ឈ្មោះរបស់គាត់ត្រឹមត្រូវអាច **វ៉ា កាមែល** ដែលជារដ្ឋមន្ត្រីក្រសួងធម្មការពុទ្ធិកសិក្សា និងវិចិត្រសិល្បៈក្នុងរដ្ឋាភិបាលលោក **អ៊ុំង អ៊ី** មុនឆ្នាំ១៩៤៥ រហូតដល់ ថ្ងៃ ១៧ ខែ តុលា ឆ្នាំ ១៩៤៥ ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុក្នុងរដ្ឋាភិបាល **ស៊ីសុវត្ថិ មុនីរ៉េត** ។

## ២- ញឹក ជូឡុង( ១៩៣៧- ១៩៣៨ )

គាត់កើតនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ ១៩០៨ ឪពុករបស់គាត់ឈ្មោះ ឧកញ៉ា **ញឹក** ធ្លាប់ទទួលមុខងារជាចៅហ្វាយខេត្តជើងព្រៃ ។ គាត់បានទទួលការសិក្សានៅ អនុវិទ្យាល័យព្រះស៊ីសុវត្ថិ រួចបន្តការសិក្សានៅវិទ្យាល័យ សាស់ សឺលូឡូបា (Chasseloup Laubat ) នាក្រុងព្រៃនគរ រួចចាប់ផ្តើម អាជីពរដ្ឋបាលតាំងពីឆ្នាំ១៩៣២មក ដោយទទួលតំណែងជាអភិ បាលខេត្តជាច្រើន ក្នុងនោះ ៖ ជាអភិបាលខេត្តកំពង់ចាមចាប់ពីឆ្នាំ ១៩៣៧ ដល់ឆ្នាំ ១៩៣៨។ នៅឆ្នាំ ១៩៤៥ លោកបានទទួលមុខ តំណែងជាអភិបាលក្រុងភ្នំពេញ និងជាឥស្សរជនក្នុងរដ្ឋាភិបាល ជាច្រើនជំនាន់ ព្រមទាំងជានាយទាហានថ្នាក់ឧត្តមសេនីយដំបូង គេបំផុតនៅឆ្នាំ១៩៥៤



។ នៅឆ្នាំ ១៩៦៩ គាត់ត្រូវបានសម្តេចព្រះ នរោត្តម **សីហនុ** ព្រះប្រមុខរដ្ឋប្រទានគោរម្យងារជាសម្តេច **ចក្រី កុញ្ជរាធិបតី** ។ ក្នុងសម័យរាជាណាចក្រទី២ គាត់បានត្រូវទទួល មុខងារជាទីប្រឹក្សាព្រះមហាក្សត្រនិងបានចូលមរណភាពនៅថ្ងៃទី ៩ មិថុនា ១៩៩៦ ក្នុងជន្មាយុ ៨២ឆ្នាំ នៅមន្ទីរពេទ្យក្រុងហុងកុង ។

## ៣- មៀច គន់ (១៩៣៩-១៩៤៤ )

នៅក្នុងកំណត់ត្រារបស់សាលាខេត្តកំពង់ចាម បានសរសេរ ថា **មេ គន់** ដែលពុំធ្លាប់មានក្នុងចំណោមឥស្សរជនសម័យនោះ មានតែឈ្មោះ **មៀច គន់** ដែលជាមន្ត្រីនៅបរមរាជវាំង និងធ្លាប់

ទទួលមុខដំណែងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នៅក្នុងរដ្ឋាភិបាល លោក **ប៉ែន នុត** ( ១៩៤៨- ១៩៤៩ ) ។

## ៤-ចៅ សែនក្មុសល(ឈុំ) (១៩៤៤- ១៩៤៦ )

គាត់ប្រសូតនៅថ្ងៃទី១ កញ្ញា ១៩០៥ នៅឃុំ ទ្រីតុង ខេត្តចូវដុក ( ខេត្តមាត់ជ្រូក ) ក្នុងទឹកដី កម្ពុជាក្រោម ឪពុករបស់លោកឈ្មោះ **យុន គីម** ធ្លាប់កាន់ដំណែងជាអភិបាលខេត្តកណ្តាល ។ គាត់ធ្លាប់បានចូលរៀននៅអនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ និងបន្តការសិក្សានៅវិទ្យាលយ័ Chasseloup Laubat នាក្រុងព្រៃនគរ និងជាជនកម្ពុជាទី១ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យនៃផ្នែកភាសាបារាំង និងទស្សនវិជ្ជា។ នៅឆ្នាំ១៩២៩គាត់បានទៅរៀននៅមហាវិទ្យាលយ័វេជ្ជសាស្រ្តនៅទីក្រុងហាណូយ ។ គាត់ធ្លាប់ទទួលមុខដំណែងជាអភិបាលស្រុកត្បូងឃ្មុំ នៅឆ្នាំ ១៩៣៥ រួចក្លាយជាអភិបាលខេត្តស្វាយរៀង និងមកទទួលមុខតំណែងជាអភិបាល



ខេត្តកំពង់ចាម នៅឆ្នាំ១៩៤៤ ។ សមយ័នោះ គាត់ជាមនុស្សដែល មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយ **សឺន ង៉ុកថាន់។** នៅថ្ងៃ១៦ តុលា ១៩៤៥ កងទ័ពបារាំងបានល្បួងចាប់លោក **សឺន ង៉ុកថាន់** ដែលកាលនោះជានាយករដ្ឋមន្ត្រី លោក **ចៅ សែនកុសល** បានភៀសខ្លួនទៅកម្ពុជាក្រោមជាមួយលោក**ប៉ាច ឈឺន** និងលោកស្រី **ឡាំ ធីអ៊ុក** ដែលជាភរិយាលោក **សឺន ង៉ុកថាន់** ។ ក្រោយមកគាត់បានសុំចុះចូលជាមួយបារាំងនៅខេត្តកំពត ។ គាត់ធ្លាប់បានជាប់ឆ្នោតជាតំណាងរាស្រ្តនៅមណ្ឌលកំពង់ចាម និងបានទទួលមុខ

ដំណែងជាប្រធានរដ្ឋសភាចំនួន ២នីតិកាល និងដកខ្លួនចេញពីឆាកនយោបាយនៅឆ្នាំ១៩៦៩ ។ ក្នុងរបបព្រះរាជាណាចក្រទី ២ គាត់ត្រូវបានទទួលគោរម្យងារជាសម្តេច និងជាព្រឹទ្ធបុរសនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ គាត់បានចូលមរណភាពយ៉ាងស្ងៀមស្ងាត់ក្នុងគេហដ្ឋានគាត់នៅទីក្រុងភ្នំពេញនៅថ្ងៃទី ២២ មករា ២០០៨ ក្នុង ជន្មាយុ ១០៣ ឆ្នាំ ។

## ៥-ផូ ព្រឿង ( ១៩៤៦- ១៩៤៨ )

លោកកើតនៅថ្ងៃទី១២ សីហា ១៩០៣ នៅទីក្រុងភ្នំពេញដែលមានឪពុកឈ្មោះ**ផូ** ធ្លាប់ធ្វើ ជាចៅហ្វាយស្រុក។ ក្រោយពីបានបញ្ចប់ការ សិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ នាឆ្នាំ ១៩២២ លោកបានត្រូវតែងតាំងធ្វើជាលេខាទេសាភិបាលបារាំងនៅខេត្តកំពត រួចទទួលតំណែងជាបន្តបន្ទាប់ ជាចៅហ្វាយស្រុកគៀនស្វាយ ជាចៅហ្វាយស្រុកកោះធំ ជាចៅហ្វាយខេត្តពោធិ៍សាត់ ព្រៃវែង កំពត និង កំពង់ចាម នៅឆ្នាំ១៩៤៦ និងក្លាយជារដ្ឋលេខាធិការក្រសួងការពារជាតិនាឆ្នាំ១៩៤៩ ក្នុងរដ្ឋាភិបាលលោក **យ៉ែមសំបូរ** ។ ក្រោយពេលដែលភរិយាទី១របស់លោកស្លាប់ទៅ លោកបានរៀបការជាមួយស្ត្រីដែលមានដើមកំណើតនៅខេត្តកំពង់ចាម ឈ្មោះ **ជា ម្លិះ**



នៅខែកញ្ញា ១៩៤៨។ លោកបានទទួលមុខដំណែងជាសមាជិករដ្ឋាភិបាលញឹកញាប់ រហូតទទួលបានតួនាទីជានាយករដ្ឋមន្ត្រីនៅថ្ងៃទី១៩មេសា ១៩៦០។

ក្នុងសម័យរបបសាធារណរដ្ឋខ្មែរ លោក ត្រូវបានទទួលមុខតំណែងជាទីប្រឹក្សាប្រធានាធិបតី **លន់ នល់** និងបានចូលមរណភាព នៅឆ្នាំ១៩៧៥ ក្នុងជន្មាយុ ៦៣ ឆ្នាំ ។

**៦- សូ កាំខូយ** ( **១៩៤៨-១៩៥២** )

គាត់ជានាយទាហានជើងក្របាមរបស់បារាំង ក្នុងពេលមកកាន់តំណែងជាចៅហ្វាយខេត្តកំពង់ចាម គាត់មានគេហដ្ឋាននៅម្តុំទីបញ្ជាការកងរាជ អាវុធហត្ថបច្ចុប្បន្ន ។ គាត់ជានាយទាហានដែល ប្រកាន់វិន័យយ៉ាងតឹងរ៉ឹង ក្នុងអគ្គសេនាធិការដ្ឋានកងយុទ្ធពល ខេមរភូមិន្ទ និងទទួលមុខតំណែងប្រធានព្រឹទ្ធសភាក្នុងរបបសា ធារណរដ្ឋខ្មែរ និងក្លាយខ្លួនជាប្រមុខរដ្ឋស្តីទីនៅថ្ងៃទី១ ខែ មេសា ១៩៧៥ និងរត់ភៀសខ្លួនចេញជាមួយអគ្គរដ្ឋទូតអាមេរិក នៅថ្ងៃទី ១២ មេសា ១៩៧៥ មុនការដួលរលំនៃរបបនេះ។






*(លោកឧត្តមសេនីយ **សូ កាំខូយ** បំពាក់ទង់ជ្វាលាដល់កងយុទ្ធពលខេ*

## ៧- **ឃឹម ទិត** ( **១៩៥២-១៩៥៣** )

លោកកើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៨៩៦ នៅទីក្រុងភ្នំពេញ ចាប់ផ្តើមការសិក្សានៅសា លាហ្វ្រង់ស៊ីហ្គារនីញេ (Francis Garnier) នៅ ប្រទេសបារាំង ។ ក្រោយពេលមាតុភូមិនិវត្តន៍ បានប្រឡងជាប់លេខ១ នៅសាលារដ្ឋបាលកម្ពុជា នាឆ្នាំ១៩២៤ រួចចេញមកកាន់ដំណែងរដ្ឋបាលនៅក្នុងស្រុកកំពង់សៀម ក្នុងឆ្នាំ ១៩២៥ និងទទួលមុខដំណែងជាបន្តបន្ទាប់ ជាចៅហ្វាយស្រុក ក្រចេះ ចៅហ្វាយខេត្តក្រចេះ កំពង់ស្ពឺ សៀមរាប កំពត ។ ថ្ងៃ១៨ សីហា ១៩៤៥ ជារដ្ឋមន្ត្រីក្រសួងការពារជាតិ សាធារណៈការ និងសុខាភិបាល ក្នុងរដ្ឋាភិបាល **សឺន ង៉ុកថាន់** ។ នៅពេលកងទ័ព ជប៉ុន បានសុំចុះចាញ់ទ័ពសម្ព័ន្ធមិត្តក្នុងសង្គ្រាមលោកលើកទី២ លោក **ឃឹម ទិត** បានផ្តល់ព័ត៌មានដល់ទ័ពបារាំង ក្រោមការដឹក



នាំរបស់លោកឧត្តមសេនីយ **ឡឺក្លែរ៍** Leclerc ឲ្យមកចាប់លោក **សឺន ង៉ុកថាន់** នៅថ្ងៃទី១៦ តុលា ១៩៤៥។ គាត់ត្រូវបានកាន់ តំណែងដដែលក្នុងរដ្ឋាភិបាល **ស៊ីសុវត្ថិ មុនីរ៉េត** រួចកាន់មុខ ដំណែងជាចៅហ្វាយខេត្តកណ្តាល មុននឹងមកកាន់ដំណែងជា ប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកំពង់ចាម នាឆ្នាំ១៩៥២ ។ ក្នុងឆ្នាំ ១៩៥៤ គាត់ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារលើផ្ទៃប្រទេស និងក្លាយជានាយករដ្ឋមន្ត្រីនៅថ្ងៃទី៣ មេសា ១៩៥៦ និងសុំលា ឈប់នៅថ្ងៃទី ១៤ កក្កដា ១៩៥៦ ។ គាត់ធ្លាប់បានបំពេញមុខងារ ជាឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស **ឆេកូស្លូវ៉ាគី**នៅចុងទសវត្ស ១៩៥០

និងត្រូវបាត់ឈ្មោះចេញពីឥស្សរជនក្នុងរដ្ឋាភិបាល ពីដើម ទសវត្ស ១៩៦០មក ។ គាត់ប្រហែលជាត្រូវស្លាប់ក្នុងមន្ទីរឃុំឃាំង របស់ខ្មែរក្រហមនៅតំបន់២២ ។

## ៨- **សាន យុន** ( **១៩៥៣- ១៩៥៥** )

ជាអភិបាលខេត្តកំពង់ចាម ក្នុងកាលៈទេសៈ ដែលប្រទេសកម្ពុជា បានទទួលឯករាជ្យយ៉ាង ពេញលេញពីអាណានិគមនិយមបារាំង។ គាត់ កើតនៅឆ្នាំ១៩០៥ ក្នុងត្រកូលអភិជន នៅខេត្ត ពោធិ៍សាត់ ។ គាត់បានចាប់ផ្តើមអាជីពរដ្ឋបាលជាបន្តបន្ទាប់នៅ និវេសនដ្ឋានកម្ពុជា រួចជាអគ្គលេខាធិការសាលាខេត្តកំពង់ចាម ។ នៅថ្ងៃទី ៩ មិនា ១៩៤៥ ជាលេខាធិការក្រសួងហិរញ្ញវត្ថុ រួចជា លេខាធិការព្រះបរមរាជវាំង ។ ក្រោយពីមានស្នាដៃក្នុងការបង្ក្រាបពួកខ្មែរឥស្សរៈក្នុងឆ្នាំ១៩៤៩ គាត់ត្រូវទទួលមុខតំណែង ជាអភិបាលក្រុងភ្នំពេញ រហូតដល់ឆ្នាំ ១៩៥៣ ទើបមកកាន់មុខ តំណែងជាអភិបាលខេត្តកំពង់ចាម រហូតដល់ថ្ងៃទី ៣០ កញ្ញា ១៩៥៥ ។ គាត់ក្លាយខ្លួនជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារលើ ផ្ទៃប្រទេសនៅក្នុងរដ្ឋាភិបាលទី១ របស់សង្គមរាស្ត្រនិយមរបស់ សម្តេច **នរោត្តមសីហនុ** និងជានាយករដ្ឋមន្ត្រីនៅថ្ងៃ ២៥ តុលា ឆ្នាំ១៩៥៦ ។



លោកធ្លាប់មានតួនាទីជាសមាជិករដ្ឋាភិបាលជាបន្ត បន្ទាប់ ក្នុងព្រះបរមរាជវាំង និងក្នុងចលនាសង្គមរាស្ត្រនិយម។ លោកពុំមានតួនាទីអ្វីទេក្នុងរបបសាធារណរដ្ឋខ្មែរ ដោយចូល និវត្តន៍ក្នុងឆាកនយោបាយ ។ លោកចូលមរណភាពនៅចុងឆ្នាំ ១៩៧៤ ក្នុងជន្មាយុ ៦៩ ឆ្នាំ នៅទីក្រុងភ្នំពេញ។

## ៩- ឱប គឹមអាង (១៩៥៥-១៩៦១ )

ពុំមានឯកសារស្តីពីសកម្មភាពរបស់គាត់មុន ពេលមកកាន់មុខតំណែងនៅខេត្តកំពង់ចាមទេ តាមការអះអាងរបស់លោក **អ៊ុក រ៉ុង** នៅចន្លោះ ឆ្នាំ ១៩៥៦-១៩៥៧ ខ្លួនគាត់រៀននៅថ្នាក់ទី៦ នៅវិទ្យាល័យព្រះសីហនុ ក្នុងគ្រានោះគាត់នៅចាំបានថា លោក **ទឹម ង្វួន** ជាប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកំពង់ចាម មុនលោក **ឱក គឹមអាង** ដោយកាលណោះមានបាតុកម្មរបស់សិស្ស ។ ខ្ញុំគ្រាន់តែដាក់នូវការអះអាងនេះក្នុងវណ្ណកម្មស្រាវជ្រាវនេះ ដើម្បីរកឯកសារជាសក្ខីកម្មមកបំពេញជាបន្តទៀត។ លោក **ទឹម ង្វួន** ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារលើផ្ទៃប្រទេស នៅក្នុងរដ្ឋាភិ បាល **ស៊ឹម វ៉ា** ក្នុងឆ្នាំ១៩៥៨ ។ នៅក្នុងអណត្តិរបស់លោក **ឱប គឹមអាង** ជាអភិបាលខេត្តកំពង់ចាម បានរំលេចនូវកិត្យានុភាពផង និងរឿងអាស្រូវផង ។ ការងាររៀបចំក្រុង បានត្រូវជម្រុញយ៉ាង ខ្លាំង ។ ដោយមានលោក **នួន ឌួង** ជាអភិបាលរង ជាជំនួយការ ផ្សារធំកំពង់ចាម ដែលបានកសាងក្នុងសម័យអាណានិគម ត្រូវ



បានកែរលំអរឡើងវិញដោយផ្លាស់កញ្ចក់ លាបសំអាត និង ចាក់ ក្រាលកម្រាលក្រោម ទន្ទឹមនឹងនេះ ហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងត្រូវ បានកសាង និងជួសជុល សំដៅលើកកម្ពស់សោភ័ណភាពក្រុង។ នៅថ្ងៃទី២៧ ឧសភា ១៩៦០ រោងចក្រតម្បាញដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ត្រូវបានសម្ភោធដាក់ឲ្យចាប់ដំណើរការជាផ្លូវការ ស្ថិតក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់របស់

សម្តេចព្រះប្រមុខរដ្ឋ **នរោត្តម សីហនុ** និងលោក **ជូ អេនឡាយ** នាយករដ្ឋមន្រ្តីនៃសាធារណរដ្ឋប្រជាមានិតចិន។ ចំណែកឯរឿងអាស្រូវវិញ នៅក្នុងឆ្នាំ១៩៦១ ធនាគារិកជនជាតិបារាំងម្នាក់ឈ្មោះ **ប៊ែរណា ឡាបាត់** Bernard Labatte បានរត់គេចខ្លួនជាមួយនឹងការបាត់បង់ប្រាក់ក្នុងធនាគារចំនួន ៨០លានរៀល ដែលនាំឲ្យ លោក **ឱប គឹមអាង** ត្រូវបានដកចេញពីមុខតំណែង និង រដ្ឋាភិ បាលលោក **ផូ ព្រឿង** ត្រូវដួលរលំ។ នៅថ្ងៃទី ៦ សីហា ១៩៦២ លោកក៏បានទទួលមុខដំណែងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក្នុងរដ្ឋាភិបាលលោក **ចៅ សែនកុសលឈុំ** នៅថ្ងៃទី២៥ តុលា ១៩៦៦ ជារដ្ឋមន្រ្តីក្រសួងការពារជាតិក្នុងរដ្ឋាភិបាលលោក **លន់ នល់** នៅថ្ងៃទី១៤ សីហា ១៩៦៩ ជាឧបនាយករដ្ឋមន្រ្តីទី៣ ទទួល បន្ទុកហិរញ្ញវត្ថុ ផែនការ និងសម្របសម្រួលកិច្ចការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងរដ្ឋាភិបាលស្រោចស្រង់ជាតិរបស់លោក**លន់ នល់**។ ក្នុងសម័យរបបសាធារណរដ្ឋខ្មែរ លោកមានតួនាទីយ៉ាងសំខាន់ក្នុងរដ្ឋាភិបាល និងជាសមាជិកគណៈកម្មាធិការកំពូល ដែលមានសមាសភាពតែ ៧នាក់ប៉ុណ្ណោះ ដែលជាអង្គការជាន់ខ្ពស់បំផុត និងចុងក្រោយបំផុតនៃរបបនេះ។

**១០- អ៊ុំ ទុយ** ( **១៩៦១- ១៩៦៧** )

ពុំមានការអះអាង ពីប្រវត្តិសកម្មភាពរបស់លោកបានច្បាស់លាស់ទេ គ្រាន់តែដឹងថា ក្រោយមានព្រឹត្តិការណ៍ស្តីពីការឈ្លានពានរបស់កងទ័ពវៀតណាមខាងត្បូងចូលជ្រៅប្រមាណ ១៥ គីឡូ ម៉ែត្រ ក្នុងខេត្តស្ទឹងត្រែង នាថ្ងៃទី៨ទៅទី២៥ ខែមិថុនា១៩៥៨ មានការកែសម្រួលសមាសភាពគណៈរដ្ឋមន្រ្តីរបស់លោក **ស៊ឹម វ៉ា**

ក្នុងនោះមានឈ្មោះលោក **អ៊ី ទុយ** ជាអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងការពារលើផ្ទៃប្រទេស ។ លោកមកកាន់មុខតំណែងជាអភិបាលខេត្តកំពង់ចាម នៅឆ្នាំ១៩៦១។ ក្រោយពីបានបញ្ចប់អាណត្តិ លោក **អ៊ី ទុយ** ទៅកាន់មុខដំណែងជាអភិបាលក្រុងភ្នំពេញ ក្នុងឋានៈជាប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញជំនួសលោក **ទេព ផន** ។ គាត់គឺជាមនុស្សដែលមានស្វាមីភក្តិចំពោះសម្ដេច**នរោត្តម សីហនុ** និងមានស្នាដៃល្អក្នុងការប្រកួតប្រជែងយកតួនាទីដ៏សំខាន់នៅទីក្រុងភ្នំពេញ និងបាត់ឈ្មោះបោះសម្លេងក្នុងរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ **លន់ នល់** ។ គួរឲ្យកត់សម្គាល់ផងដែរ នៅឆ្នាំ ១៩៦៥ សកលវិទ្យាល័យភូមិន្ទកំពង់ចាម ដែលមានលោក **គាត ឈន់** ជាសកលវិទ្យាធិការ បានចាប់ផ្ដើមដំណើរការដែលមានមហាវិទ្យាល័យ ៣គឺ ៖ មហាវិទ្យាល័យមេកានិក មហាវិទ្យាលយ័កសិកម្មប្រទេសក្ដៅ និងមហាវិទ្យាល័យវិទ្យាសាស្ត្ររូបនិយមគណិតសាស្ត្រ។

## **១១- ញៀន ឆៀង** ( **១៩៦៧-១៩៧០**)

មុនពេលមកកាន់មុខដំណែងជាអភិបាលខេត្តកំពង់ចាម គាត់ជាអភិបាលខេត្តកំពត ដែលនៅទីនោះគាត់ខិតខំប្រឹងប្រែង ដោយបញ្ចេញអស់នូវទេពកោសល្យក្នុងការរៀបចំក្រុង ជាពិសេសនៅតំបន់ឆ្នេរកែប ដើម្បីប្រណាំងប្រជែងយកតួនាទីជាប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ តែគាត់បានបាត់បង់ឱកាសដោយប្រើអំពើហឹង្សាទះកំភ្លៀងនាយទាហានម្នាក់ដែលស្និទ្ធនឹងរាជវង្សដែលមិនក្រោកឈរគោរពគាត់ក្នុងភោជនីយដ្ឋានមួយ តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់បានមកកាន់ដំណែងជាអភិបាលខេត្តកំពង់ ចាមដែរ

នៅឆ្នាំ១៩៦៧ ។ អាស្រ័យដោយរូបគាត់មានការស្មោះត្រង់យ៉ាងប្តូរផ្តាច់ជាមួយអង្គសម្តេចឪ គាត់ត្រូវបាត់តួនាទីទាំងស្រុងក្រោយសម័យរដ្ឋប្រហារ ១៨ មិនា ឆ្នាំ១៩៧០ ។ គាត់ជាចៅហ្វាយខេត្តដែលកាចជាងគេនៅក្នុងសម័យនោះ (នរណាមិន ស្គាល់ **ញៀន ធៀង ?** ) ជាពាក្យចំអកមួយរបស់មហាជន ។

**១២- ចាន់ គមឆាំង**? (**១៩៧០**)

មានរយៈពេល ៧ ថ្ងៃ ។ យើងពុំបានដឹងអំពីអតីតភាពរបស់ គាត់ទេ តាមទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ គាត់ជាមន្ត្រីដែលស្និទ្ធនឹង លោក **អ៊ិន តាំ** ដែលជាអ្នកផ្តើមគំនិតដ៏សំខាន់ម្នាក់ក្នុងរដ្ឋប្រហារ ១៨ មិនា ១៩៧០ ។ ឈ្មោះគាត់ពិតប្រាកដគឺ **ចាន់ គមជាង** ជាអគ្គលេខាធិការគណបក្សប្រជាធិបតេយ្យរបស់លោក **អ៊ិន តាំ** ដែលខ្ញុំមានឱកាសជួបប្រាស្រ័យទាក់ទងផ្ទាល់នៅក្នុងឆ្នាំ ១៩៧៣ ក្នុងឋានៈខ្ញុំជាប្រធានសមាគមសិស្សមធ្យមសិក្សា នៃសាធារណ រដ្ឋខ្មែរ ។ សូមបញ្ជាក់ថា រដ្ឋប្រហារទម្លាក់សម្តេច **នរោត្តមសីហនុ** ចេញពីមុខដំណែងជាព្រះប្រមុខរដ្ឋ បណ្តាលឲ្យប្រជាជនកម្ពុជា ពិសេសកសិករ មានកំហឹងយ៉ាងពុះពោរសន្ធោសន្ធៅក្រៃលែង ក្នុងនោះខេត្តកំពង់ចាម មានការរំជើបរំជួលខ្លាំងជាងគេ។ តាមពាក្យជ័យឃោសន៍ ( ***ជយោ ! សម្តេចឪ អាណាមិនទៅកាប់ចោល*** ) បាតុករជាច្រើនពាន់នាក់ បានប្រមូលផ្តុំសកម្មភាពតាមរថយន្តជាច្រើនគ្រឿង ឆ្ពោះមកកាន់ក្រុងកំពង់ចាម និងឈានឆ្ពោះទៅកាន់ក្រុងភ្នំពេញ ។ មហាបាតុកម្មដែលមិនអាចទប់ស្កាត់បាននេះ បានឈានទៅបង្កនូវអំពើហឹង្សាដោយបាតុករដៃដល់មួយចំនួន បានចាប់លោក **ហ៊ិន និល** ជាប្អូនប្រុសបង្កើតរបស់លោក **លន់ នល់** (

គាត់យកឈ្មោះឪពុកជានាមត្រកូល) និងជាស្នងការប៉ូលីសនៅ ជប់ព្រមទាំងតំណាងរាស្ត្រ ២ នាក់ទៀត គឺលោក **សុស សាអ៊ុន** និងលោក **គឹម ផុន** ដោយវះពោះយកថ្លើមមកឆាស៊ីត្រង់ចំណុចកំពង់សាឡាង។ក្រុមបាតុករថែមទាំងចូលអុកឡុកដុតសំភារៈ និងឯកសារក្នុងសាលាខេត្តសាលាដំបូង និងទីចាត់ការនានាឲ្យវិនាសខ្ទេចខ្ទីគ្មានសល់ ។ បាតុកម្មទាំងនេះ បានរងនូវការបង្ក្រាបយ៉ាងកម្រោលនៅកៀកក្រុងភ្នំពេញ និងត្រូវជំនួសដោយសង្គ្រាមស៊ីវិលសុខសន្តិភាពត្រូវបាត់បង់។ អណើះតទៅ ខេត្តកំពង់ចាមត្រូវដឹកនាំដោយអភិបាលខេត្តជានាយទាហានជាន់ខ្ពស់ រហូតដល់ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ នាថ្ងៃទី ១៧ មេសា ១៩៧៥ ។

**១៣- អ៊ិន តាំ ( ១៩៧០-១៩៧១ )**



លោកកើតនៅថ្ងៃទី២២ កញ្ញា ១៩១៦ នៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ គាត់បានរៀននៅសាលាវត្តស្ទឹងត្រង់ រួចទៅបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងចូលរៀននៅសាលារដ្ឋបាលក្នុងឆ្នាំ១៩៤២ ។ គាត់បានរៀបការជាមួយប្អូនជីដូនមួយគាត់ឈ្មោះ **អ៊ិន តាត** នៅ ឆ្នាំ១៩៤៣ ដែលជាឆ្នាំគាត់ចាប់ផ្តើមអាជីពរដ្ឋបាលក្នុងឋានៈជាមន្ត្រីថ្នាក់មធ្យមនៅខេត្តព្រៃវែង សៀមរាប កំពង់ចាម និងតំបន់ ខ្លង់រាប ។ ពីឆ្នាំ ១៩៥៦ ដល់ឆ្នាំ ១៩៥៨ គាត់ជាមេប៉ូលីសនៅខេត្ត កំពង់ឆ្នាំង។ ចាប់ពីឆ្នាំ១៩៥៨ ដល់ ១៩៦៤ គាត់ជាអភិបាលខេត្ត តាកែវ

និងកាន់តំណែងបន្ថែមក្នុងអគ្គបញ្ជាការក្រសួងសន្តិសុខ ជាតិ និងជានាយករាជបណ្ឌិតសភានគរបាលជាតិ គឺក្នុងអណត្តិជាអភិបាលខេត្តតាកែវនេះហើយ ដែលនៅថ្ងៃ ១៩ វិច្ឆិកា ១៩៦៣ គាត់បានល្បួងនាំខ្លួនខ្មែរសេរី ២នាក់ មានឈ្មោះ **ព្រាប អ៊ិន** និង **សាំង សន** និងនាំខ្លួនមកក្រុងភ្នំពេញ ក្នុងនោះ **ព្រាប អ៊ិន** រក្សា នូវចរឹតរឹងរុះ ត្រូវបានកាត់ទោសប្រហារជីវិតនៅត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ នាខែមករា១៩៦៤។ នៅថ្ងៃ ២៦ ធ្នូ ១៩៦៤ គាត់បានក្លាយខ្លួនជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាសនា ក្នុងរដ្ឋាភិបាល **នរោត្តម កន្តុល** ។ ឆ្នាំ១៩៦៦ គាត់ជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ មណ្ឌលក្រូចឆ្មារ តែដោយមានការចាំបាច់នៅក្នុងការរៀបចំខេត្ត បាត់ដំបងឡើងវិញ ក្រោយកុប្បកម្មនៅសំឡូត គាត់ត្រូវបានចាត់តាំងជាអភិបាលខេត្តបាត់ដំបង នៅឆ្នាំ១៩៦៧ និងនៅថ្ងៃទី១ កុម្ភៈ ១៩៦៨ គាត់មកកាន់ដំណែងជារដ្ឋមន្ត្រីក្រសួងកសិកម្ម ក្នុងរដ្ឋាភិ បាល **ប៉ែន នុត** ។ នៅឆ្នាំ ១៩៦៩ គាត់បានជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រមណ្ឌលជ្រៃវៀន ជំនួសលោក **ហ៊ូ នឹម** ដែលបាត់ ខ្លួន។ នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៧០ គាត់ក្លាយជាប្រធានស្តីទី នៃរដ្ឋសភា ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលសម្លេង អ្នកតំណាងរាស្ត្រក្នុងការបោះឆ្នោតទម្លាក់សម្តេច **នរោត្តមសីហនុ** ពីព្រះប្រមុខរដ្ឋ ។ គាត់គឺជាឥស្សរជនទី៣នៃរដ្ឋប្រហា ១៨ មិនា ១៩៧០ បន្ទាប់ពីលោក **លន់ នល់** និង ព្រះអង្គម្ចាស់**ស៊ីសុវត្ថិ សិរិមតៈ** ពេលនោះគាត់ត្រូវបានបំពាក់ឋានន្តរសក្តិជាឧត្តមសេនីយត្រីនៃកងយុទ្ធពលខេមរជាតិ ។ អាស្រ័យដោយស្ថានការណ៍

សឹកនៅខេត្តកំពង់ចាមធ្លាក់ក្នុងភាពដុនដាប គាត់ត្រូវបានទទួលភារកិច្ចធ្វើជាអភិបាលខេត្ត ក្នុងបំណងស្តារនូវសភាពការណ៍ឲ្យបានប្រសើរឡើងវិញ ដោយព្យាយាមប្រមូលកម្លាំងបើកប្រតិបត្តិការសឹកនៅតាមកំណាត់ផ្លូវលេខជាតិលេខ៦ និងលេខ៧ គួបផ្សំនឹងការចុះឃោសនាអប់រំប្រជាពលរដ្ឋតាមសមរភូមិនិមួយៗ តែគាត់ពុំអាចសម្រេចបាននូវលទ្ធផលតាមការរំពឹងទុកឡើយ ដោយតំបន់ត្រួតត្រារបស់គាត់បានរួញតូចមកនៅក្រុងកំពង់ចាម និង មួយភាគតូចនៃស្រុកកំពង់សៀម និងត្បូងឃ្មុំតែប៉ុណ្ណោះ។ នៅខែ ឧសភា ១៩៧០ កំម្មង់ដូរនិស្សិតនៅសកលវិទ្យាល័យកំពង់ចាម ៥នាក់ ត្រូវស្លាប់ និងជាច្រើននាក់ត្រូវរបួសក្នុងការប្រយុទ្ធការពារ
គ្រឹះស្ថានសិក្សារបស់ខ្លួន។ គាត់ចាប់ផ្តើមខ្វែងគំនិតជាមួយលោកសេនាប្រមុខ**លន់ នល់** ហើយចេញទៅបង្កើតគណបក្សប្រជាធិបតេយ្យជាមួយលោក **ចៅ សៅ** និងក្លាយខ្លួនជាបេក្ខជនប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរនៅថ្ងៃទី៤ មិថុនា ១៩៧២ ដែលជាលទ្ធ ផលគាត់ទទួលសម្លេងគាំទ្រ២៤% ចាញ់លោក **លន់ នល់** ដែល បាន៥៥%។ តាមការចាំបាច់ គាត់ត្រូវបានទទួលភារកិច្ចជានាយក រដ្ឋមន្ត្រីនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៣ និងសុំលាឈប់នៅខែធ្នូ ឆ្នាំ១៩៧៣ ដោយដកខ្លួននៅក្រៅឆាកនយោបាយ ទៅធ្វើស្រែ នៅប៉ោយប៉ែត និងភៀសខ្លួនទៅរស់នៅប្រទេសបារាំង រួចចេញ ទៅសហរដ្ឋអាមេរិក ក្រោយពេលដែលរបបសាធារណរដ្ឋខ្មែរត្រូវ ដួលរលំនាថ្ងៃ១៧ មេសា ១៩៧៥ ។ នៅឆ្នាំ ១៩៨១ គាត់បានវិលមកចូលរួមក្នុងឆាកនយោបាយឡើងវិញ ក្នុងឋានៈជាអនុប្រធាន ទី២

របស់**ហ៊ុនស៊ិនប៊ិច** តែគាត់បានសុំលាឈប់នៅឆ្នាំ ១៩៨៣ ដោយវិលទៅសហរដ្ឋអាមេរិកវិញ ដើម្បីបង្កើតសមាគមមនុស្សធម៌មួយឈ្មោះ **ខ្មែរអមតៈ** គឺតាមរយៈសមាគមនេះ គាត់ត្រូវបានមកកាន់ក្រុងភ្នំពេញនៅខែមករា ឆ្នាំ ១៩៨៩ និងក្លាយទៅជាទីប្រឹក្សារបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជា ។ ក្នុងសម័យបោះឆ្នោតដែលរៀបចំដោយ **អ៊ុនតាក់** (UNTAG) គាត់បានបង្កើតគណបក្ស ប្រជាធិបតេយ្យឡើងវិញ តែពុំបានទទួលអសនៈក្នុងសភាទេ គាត់បានវិលទៅសហរដ្ឋអាមេរិកវិញ និងទទួលមរណភាពនៅទីនោះ នៅ ថ្ងៃទី ១ មេសា ២០០៦ ក្នុងជន្មាយុ ៨៦ ឆ្នាំ។



*( លោក **អ៊ិន តាំ** ជួបប្រាស្រ័យ*
*ជាមួយប្រជាជននៅមុខសាលាខេត្តកំពង់ចាម ឆ្នាំ ១៩៧០ )*

## ១៤-ឈីតែស្ងួន អែមមេ ( ១៩៧២.....? )

លោកជានាយទាហានជាន់ខ្ពស់ នៃកងយុទ្ធពលខេមរជាតិរបស់របប **លន់ នល់** មានឋានន្តរសក្តិឧត្តមសេនីយត្រី មានបង

ប្អូនបង្កើតម្នាក់ថ្នាក់ឧត្តមសេនីយដែរ ឈ្មោះ**ប៉ូល លីតែសួន** ។ ពុំសូវមានព័ត៌មានគួឲ្យកត់សម្គាល់ទេនៅក្នុងអាណត្តិដ៏ខ្លីរបស់គាត់ ក្រៅពីការខិតខំការពារដីមួយក្រវិចតូច នៅកំពង់ចាមតែប៉ុណ្ណោះ គាត់អាចត្រូវផ្លាស់ចេញក្នុងឆ្នាំដដែល។

**១៥-មូល ខ្លូន** ( **១៩៧២- ១៩៧៣** )

គាត់មានឋានៈជាឧត្តមសេនីយត្រី ដែលជាបញ្ជាការកងពល មួយមានពលទាហានឯកសណ្ឋានឈុតខ្មៅទាំងអស់។ នៅពេលគាត់មកកាន់ដំណែងជាអភិបាលខេត្តកំពង់ចាម គាត់បានយកបងប្អូនគាត់ឈ្មោះ**ម៉ា ឡៅពី** ដែលជាអ្នកធ្វើបថកថាដ៏ឆ្នើមក្នុងសម័យសង្គមរាស្ត្រនិយមមកធ្វើជាអភិបាលស្រុកកំពង់សៀម ដោយបានបន្សល់ទុកនូវវណ្ណកម្មបទចម្រៀងជាច្រើនបទ ដែលគាត់និពន្ធ ជំនាន់នោះមានបទ ឆ្មេរខ្សាច់កោះប៉ែន កំពង់ចាមកំពង់ចិត្ត....។ គាត់មកកាន់មុខតំណែងនៅកំពង់ចាម បានយូរជាងលោកឧត្តមសេនីយត្រី **លីតែសួន អែមមេ** បន្តិច។

**១៦-ស្រី យ៉ា** (**ក្នុងឆ្នាំ១៩៧៣**)

នៅក្នុងកំណត់ត្រារបស់សាលាខេត្ត ដាក់លោកឧត្តមសេនីយ **ស ហោ** ជាអភិបាលខេត្ត មុនលោក **ស្រី យ៉ា** តែតាមការពិត លោក **ស ហោ** ជាអ្នកឡើងមកកាន់តំណែងបន្តពីលោក **ស្រី យ៉ា** វិញ ដោយខ្ញុំជាអ្នកដែលនៅជាប់នឹងព្រឹត្តិការណ៍នេះ ក្នុងឋានៈខ្ញុំជាប្រធានសមាគមសិស្ស និងបានធ្វើដំណើរតាមឧទ្ធម្ភាគចក្រមកសាកសួរសុខទុក្ខកម្មង់ដូរសិស្សនៅកំពង់ចាម នាចុងខែកញ្ញា ឆ្នាំ ១៩៧៣។ លោកឧត្តមសេនីយត្រី **ស្រី យ៉ា** ជាមេបញ្ជាការកងទ័ពឆ័ត្រយោងដ៏ឆ្នើមក្នុងរបប **លន់ នល់** ។ គាត់មកកាន់មុខដំណែង

ជាអភិបាលខេត្តបន្តពីលោក **មូល ខ្លេង** ប្រហែលជាក្នុងត្រីមាស ទី១ ឆ្នាំ១៩៧៣។ គាត់ជានាយទាហានដ៏ល្បីល្បាញម្នាក់ក្នុងរបប **លន់ នល់** និងមានឆន្ទៈទទួលខុសត្រូវខ្ពស់ ។ ក្នុងតួនាទីរបស់លោកជាអភិបាលខេត្ត និងជាមេបញ្ជាការកងទ័ព លោកបានចាប់កាណូត និងទូកសណ្ដោងជាច្រើន របស់ក្រុមហ៊ុនចំការកៅស៊ូ បារាំង ដែលដឹកសម្ភារៈឲ្យភាគីបដិបក្ខ។ គាត់ត្រូវបានប្រធានក្រុម ហ៊ុនព្រមាននឹងធ្វើអន្តរាគមន៍ឲ្យដករូបលោកចេញពីមុខដំណែង ប្រសិនជាលោកមិនព្រមសម្រុះសម្រួលដោះលែង ។ ទីបំផុតគាត់ត្រូវបានដកចេញពីមុខដំណែងមែន។ ក្នុងសម័យនោះ ចំការកៅស៊ូទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែររំដោះ ដើម្បីទាញយកផលប្រយោជន៍ពីអាជីវកម្ម ក្រុមហ៊ុនបារាំងមានភារកិច្ចផ្គត់ផ្គង់នូវសម្ភារៈបរិក្ខាឲ្យកម្លាំងខ្មែររំដោះផងនិងសូកប៉ាន់មន្ត្រីយោធានៅអគ្គសេនាធិការផង។ ក្នុងគ្រានោះ កងកម្លាំងខ្មែររំដោះបានបើកការវាយប្រហារចូលទីក្រុងកំពង់ចាម តាមទ្រង់ទ្រាយធំនៅពាក់កណ្ដាលខែកញ្ញា ១៩៧៣ ដោយកាន់កាប់ស្ទើរតែទាំងស្រុងនៅទីក្រុងកំពង់ចាម ។

## ១៧-**ស ហោ**(ពីពាក់កណ្ដាលខែកញ្ញា១៩៧៣ដល់ឆ្នាំ១៩៧៤)

លោកមានឋានៈជាឧត្ដមសេនីយទោត្រូវទទួលបេសកកម្មមកវាយដណ្ដើមយកក្រុងកំពង់ចាម ដែលមានដង្ហើមផ្ដឹកៗឈានទៅ ដួលរលំ ។ គាត់ទទួលបាននូវការគាំទ្រពីអគ្គសេនាធិការ ដោយផ្ដល់ពីកិច្ចអន្តរាគមន៍របស់កងពលធំលេខ១ (1erBIC) ក្នុងប្រតិបត្តិការវាយឡើងគោក ដែលបានគាំទ្រយ៉ាងពេញទំហឹងពីសំណាក់កងនាវាចរណ៍និងកងទ័ពជើងអាកាស ។ ដោយរដូវនោះជារដូវ ទឹកជំនន់

ចំពេលបុណ្យកាន់បិណ្ឌ កងកម្លាំងថ្មើជើងសម្រេចបាន ជោគជ័យក្នុងការទំលាយទ្វាទឹកទំនប់បឹងកុក ធ្វើឲ្យកម្លាំងទ័ពខ្មែរ រំដោះបាត់ប្រៀបលើសមរភូមិ ក្រុងកំពង់ចាម ត្រូវបានកងកម្លាំង ទ័ពសាធារណរដ្ឋខ្មែរកាន់កាប់ឡើងវិញ ។ ខ្ញុំជាមួយនិងសហការី ២ រូប មាន **លី ហេង** ជាអនុប្រធានសមាគមសិស្ស និង **អ៊ុង ទី** ជាអគ្គលេខាធិការសមាគម បាននាំស្បៀងអាហារ និងសម្ភារៈប្រើ ប្រាស់មួយចំនួនផ្ទុកក្នុងឧទ្ធម្ភាគចក្រ ២គ្រឿង ចូលមកកាន់ទីក្រុង កំពង់ចាម នៅថ្ងៃទី២០ កញ្ញា ១៩៧៣ ដោយចុះចតនៅលើសួន ផ្លូវភ្លោះចំមុខផ្ទះឯកឧត្តម **ហ៊ុន ណោង** បច្ចុប្បន្ន ក្នុងពេលដែល យន្តហោះទី១ ដែលចុះចតមុនត្រូវរងនូវឥទ្ធិពលគ្រាប់ផ្លោងរបស់ ខ្មែរបដិបក្ខ បណ្តាលឲ្យលោក **កៅ លន់** ជាអនុរដ្ឋលេខាធិការ ក្រសួងអប់រំជាតិរងរបួសស្រាលត្រង់ស្មា។ ខ្ញុំនិងសហការីត្រូវជាប់ ផុងនៅក្រុងកំពង់ចាមអស់២យប់៣ថ្ងៃ ដោយកងទ័ពជើងអាកាស កំពុងរវល់មមារញឹកក្នុងការប្រមូលលុយពីការដឹកអ្នកមានៗ ដែល ដណ្តើមគ្នាប្រញ៉ាយរត់ទៅភ្នំពេញ រហូតដល់ថ្ងៃទី២២ ខែ កញ្ញា ទើបមានលទ្ធភាពវិលមកភ្នំពេញវិញជាមួយឧទ្ធម្ភាគចក្រពិសេសរបស់ លោក **វីល្លីយ៉ាំ ប៉ាល់មែរ** William Palmer ជាសេនានុព័ន្ធ ប្រចាំស្ថានទូតអាមេរិក។ ក្នុងពេលស្នាក់អាស្រ័យនៅកំពង់ចាម ខ្ញុំ បានសម្រាកនៅភូមិគ្រឺះ **សេង ចុង** ជាមួយលោក **អ៊ឹម រុន** ជា តំណាងរាស្ត្រមណ្ឌលកោះមិត្ត និងលោកវរសេនីយទោ **មាន ជិនហេង** និងមានការសាកសួរសុខទុក្ខមិនដាច់ពីលោកវរសេនីយ ឯក **អ៊ូ វ៉ា** ។ ពេលនោះលោក **ស ហោ** ពុំបាននៅប្រចាំការទេ ដោយប្រគល់ភារកិច្ចជូនលោកវរសេនីយឯក **អ៊ុក សូរ** ជាអ្នក

ទទួលខុសត្រូវបញ្ជាលើសមរភូមិ ។ វិទ្យាល័យព្រះសីហនុ ស្វាត់ ជ្រងំ មានគ្រាប់ផ្លោងគ្រប់ធុនដោតនឹងដីដូចសន្ទូង កម្មង់ដូសិស្ស មួយក្រុមដឹកនាំដោយ **ស៊ីវ ម៉េងសាយ** នៅប្រចាំការក្នុងអាគាររដ្ឋបាលមួយនៅជ្រុងខាងជើងឈៀងខាងកើតសាលាខេត្ត ការផ្គត់ផ្គង់គ្រាប់រំសេវ និងស្បៀងអាហារ ត្រូវទម្លាក់ដោយឆ័ត្រយោងពី យន្តហោះ ប្រជាពលរដ្ឋត្រូវរងនូវការលំបាកជាខ្លាំង ដោយបង្ខំចិត្តទ្រាំរស់នៅលើដីមួយក្រវិចតូច ដែលស្រោចដោយគ្រាប់រំសេវគ្រប់ ធុន។ មិនយូរប៉ុន្មាន លោកឧត្តមសេនីយទោ **ស ហោ** ត្រូវដកទៅទទួលមុខដំណែងជាអភិបាលខេត្តបាត់ដំបង ជំនួសលោកឧត្តមសេនីយត្រី **សេក សំអៀត** ដែលរងនូវការចោទប្រកាន់ពីអគ្គរដ្ឋទូតអាមេរិកពីអំពើពុករលួយ។ គាត់ទៅកាន់មុខដំណែងនៅទីនោះក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ មានផ្ទុះព្រឹត្តិការណ៍បាតុកម្មប្រឆាំងនិងទំនិញឡើងថ្លៃ ដោយបាតុករនាំគ្នាចូលអុកឡុកនៅក្នុងផ្សារបាត់ ដំបង ដោយគាត់មិនធ្វើអន្តរាគមន៍អ្វីសោះតាមសំណូមពររបស់ពពួកឈ្មួញទុច្ចរិត ដែលនាំគ្នាស្តុកទំនិញទុកលក់ តម្លើងថ្លៃ គាត់ត្រូវបាន **លន់ នល់** ដកចេញពីមុខដំណែងមកកាន់ក្រុងភ្នំពេញ លោក **សេក សំអៀត** ត្រូវវិលទៅកាន់ជាអភិបាលខេត្តបាត់ដំបង វិញ ។

**១៨- ឆ ឌូ** ( **១៩៧៤-១៩៧៥** )

គាត់គឺជាឧត្តមសេនីយម្នាក់ក្នុងកងយុទ្ធពលខេមរជាតិ ធ្លាប់ទទួលមុខដំណែងជាមេបញ្ជាការយុទ្ធភូមិភាគពិសេស ( R.M.S ) ដែលជាតំបន់យុទ្ធសាស្ត្រនៅជុំវិញក្រុងភ្នំពេញ ។ គាត់ជាអ្នកមានដើមកំណើតនៅខេត្តកំពង់ចាម ត្រូវជាបងជីដូនមួយនឹងមហាឧបា សិកា **ឌី ប៉ុក** ដែលត្រូវជាមាតាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។

គាត់បានព្យាយាមប៉ុនប៉ងមិនបានសម្រេចក្នុងការ ទាក់ទាញលោក **ហ៊ុន សែន** ដែលកាលនោះជាមេបញ្ជាការកង ឯកភាពមួយរបស់កម្លាំងខ្មែររំដោះ ដែលបានធ្វើសកម្មភាពយ៉ាង សកម្មខ្លាំងក្លានៅត្រើយខាងកើតទន្លេមេគង្គ ។ គាត់ជាអភិបាល ខេត្តកំពង់ចាមចុងក្រោយបំផុត នៃរបបសាធារណរដ្ឋខ្មែររបស់ លោកសេនាប្រមុខ **លន់-នល់** ។

## **១៩- កែ ពក** ( **១៩៧៥ ដល់ ៦ មករា ១៩៧៩** )

ក្រោយការដួលរលំនៃរបបសាធារណរដ្ឋខ្មែរនាថ្ងៃ ១៧ មេសា ១៩៧៥ស្ថានការណ៍នៅកម្ពុជាត្រូវក្រឡាប់ចាក់ធ្លាក់យ៉ាងជ្រៅក្នុង របបប្រល័យពូជសាសន៍ ដែលដឹកនាំដោយ **ប៉ុល ពត** ។ ប្រព័ន្ធ គ្រប់គ្រងរដ្ឋបាលត្រូវបានរុះរើនិងកែប្រែទាំងស្រុង ក្នុងនោះខេត្ត កំពង់ចាម ត្រូវហែកច្រៀកជាពីរ គឺ ៖ ភូមិភាគបូព៌ានៅត្រើយខាង កើតទន្លេមេគង្គ ដែលមានវិសាលភាពយ៉ាងទូលំទូលាយដោយរួម បញ្ចូលមួយភាគនៃខេត្តក្រចេះ(ស្រុកឆ្លូង) ខេត្តព្រៃវែង និងខេត្ត ស្វាយរៀង ដោយចែកចេញជា៥តំបន់ មានតំបន់២០, ២១, ២២, ២៣,និងតំបន់២៤ ដែលគ្រប់គ្រងដោយ **សោ ភឹម** ។ ភូមិភាគ កណ្តាល ដែលពីមុនជាភូមិភាគឧត្តរ រួមមានខេត្តកំពង់ធំ និង ត្រើយខាងលិចនៃខេត្តកំពង់ចាម ដោយចែកចេញជា ៣ តំបន់គឺ៖ តំបន់៤១ , ៤២ និងតំបន់៤៣ ដែលគ្រប់គ្រងដោយ **កែ ពក** ជា លេខាភូមិភាគ ។ **កែ ពក** គឺជាមេដឹកនាំភូមិភាគកណ្តាល (ភូមិ ភាគ ៣០៣) ជាមនុស្សដែលស្មោះត្រង់បំផុតចំពោះអង្គការ (***ប៉ុល ពត***) បានដាក់ការគ្រប់គ្រងយ៉ាងតឹងរ៉ឹង និងយ៉ាងកម្រោលលើ ប្រជាជន បង្កនូវហាយនភាពយ៉ាងធំធេងបំផុតដល់មនុស្សនិងទឹក

ដីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងបានចូលរួមជាមួយភូមិភាគនីរតី ក្នុងកិច្ចអន្តរាគមន៍បោសសំអាតយ៉ាងឃោរឃៅព្រៃផ្សៃ ក្នុងភូមិភាគបូព៌ានៅឆ្នាំ ១៩៧៨ ថែមទៀតផង។ អាស្រ័យដោយមានការជួយឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹង និងប្រកបដោយប្រសិទ្ធិភាពអំពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលដឹកនាំដោយសម្តេចអគ្គមហា ទាំងបីបានវាយរំដោះយកក្រុងកំពង់ចាម ឲ្យរួចផុតពីចង្កូមមច្ចុរាជនៃរបបប្រល័យពូជសាសន៍ នាព្រឹកថ្ងៃទី ៦ មករា ១៩៧៩ ។

## **២០- ម៉ម សារ៉ុន** ( **១៩៧៩**.....)

គាត់គឺជាលេខាស្រុកត្បូងឃ្មុំក្នុងរបបកម្ពុជាប្រជាធិតេយ្យ និងបានគេចខ្លួនចូលក្នុងចលនាតស៊ូ នៅពេលដែលភូមិភាគបូព៌ារងនូវការបោសសំអាតជាទូទៅពីសំណាក់**ប៉ុល ពត** នាឆ្នាំ១៩៧៨ ។ នៅពេលដែលប្រទេសជាតិបានរំដោះនាថ្ងៃ ៧មករា ១៩៧៩ គាត់ត្រូវបានចាត់តាំងជាប្រធានគណៈកម្មាធិការប្រជាជន ខេត្តកំពង់ ចាម ជាលើកដំបូងបំផុត។ គាត់បានបំពេញការងារបានប្រហែល ជា ៣ខែ ត្រូវផ្លាស់ចេញទៅកាន់ក្រុងភ្នំពេញ ក្នុងឋានៈជាថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច ។

## **២១- គឹម យិន** ( **១៩៧៩-១៩៨០**)

គាត់គឺជាកម្មាភិបាលខ្មែរ ដែលទទួលការបណ្តុះបណ្តាលនៅវៀតណាមខាងជើង ក្រោយសន្និសិទ្ធហ្សឺណែវឆ្នាំ១៩៥៤ ។ គាត់បានមកកាន់តំណែងជាលេខាបក្សខេត្តកំពង់ចាមបន្តពីលោក **ម៉ម**



**សាប៊ុន**

ក្នុងខណៈដែលការរៀបចំរដ្ឋអំណាចនៅថ្នាក់ស្រុក និង ឃុំមានភាពច្របូកច្របល់នៅឡើយ ។ នៅក្នុងឆ្នាំ១៩៨០ គាត់ត្រូវផ្លាស់ទៅទទួលមុខតំណែងជាប្រធានខេត្តកំពង់ធំ រួចមកកាន់មុខ តំណែងជាអគ្គនាយកវិទ្យុជាតិដែលគាត់ត្រូវបញ្ចប់អាជីពរដ្ឋបាលនៅទីនោះ។

**២២- ស៊ឹម កា** (**១៩៨០- ១៩៨១** )



ក្នុងអាណត្តិនៃការដឹកនាំរបស់គាត់នៅខេត្តកំពង់ចាម គឺជារយៈពេលដ៏មមារញឹកក្នុងការកសាងក្បាលម៉ាស៊ីនរដ្ឋអំណាច នៅគ្រប់ថ្នាក់ ពីខេត្តដល់មូលដ្ឋាន និងការត្រៀមលក្ខណៈដើម្បីបោះឆ្នោតជាសកលក្នុងការជ្រើសតាំងគណៈកម្មាធិការប្រជាជនបដិវត្តឃុំ និងសមាជិករដ្ឋសភា ។ ក្នុងឆ្នាំ ១៩៨១ គាត់ក៏ត្រូវបានផ្ទេរភារកិច្ចទៅកាន់មុខដំណែង ជារដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ រួចមកកាន់មុខដំណែងជាលេខាបក្សនៅរដ្ឋធានីភ្នំពេញ បច្ចុប្បន្នគាត់ជាសមាជិកព្រឹទ្ធសភា ។

**២៣- ព្រាប ពិជយ៍** ( **១៩៨១-១៩៨៤** )

គាត់មានដើមកំណើតនៅឃុំជាំក្រវៀន ស្រុក មេមត់ ធ្លាប់បានបួសរៀនមានចំណេះដឹងយ៉ាង ជ្រាលជ្រៅ និងជាអ្នកកាសែតនៅក្នុងសម័យ សង្គមរាស្ត្រនិយម ។ ឈ្មោះដើមរបស់គាត់គឺ **ព្រាប សាឯម** គាត់ជាកម្មាភិបាលដឹកនាំការងារឃោសនាអប់រំ នៅស្រុកមេមត់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានគេចខ្លួន ចូលរួមក្នុងចលនាតស៊ូ នៅក្នុងពេលដែលមានព្រឹត្តិការណ៍បោស សំអាតភូមិភាគបូព៌ា ។ ក្នុងឋានៈជាលេខាបក្សខេត្ត និងជាប្រធាន គណៈកម្មាធិការប្រជាជនបដិវត្តខេត្តកំពង់ចាម គាត់បានព្យាយាម ធ្វើបថកថាដ៏ប៉ិនប្រសប់ ក្នុងការបណ្តុះបណ្តាលកម្មាភិបាលគ្រប់ ថ្នាក់នៅសាលានយោបាយខេត្ត ដែលមានទីតាំងស្ថិតនៅអនុវិទ្យា ល័យបឹងកុកបច្ចុប្បន្ន។ ភារកិច្ចពង្រឹងភូមិឃុំរឹងមាំ បានត្រូវជម្រុញ ឲ្យមានសកម្មភាពជាទូទៅតាមរយៈក្រុមប្រតិបត្តិការប្រដាប់អាវុធ សំដៅទប់ស្កាត់នូវការវិលត្រឡប់មកវិញ នៃរបបប្រល័យពូជ សាសន៍ ។ ក្នុងសម័យនោះដែរ គាត់បានប្រមូលជាងមកពីស្រុក ស្រីសន្ធរ មកកសាងនូវវិមានជ័យជំនះមួយ ដែលមានលំនាំដូច ប្រាសាទបន្ទាយស្រី នៅរង្វង់មូលផ្លូវភ្លោះ និងផ្លូវមុខសាលាខេត្ត។ ទន្ទឹមនឹងនោះដែរ ព្រឹត្តិការណ៍ដ៏គួរឲ្យកត់សម្គាល់ គឺនៅក្នុងឆ្នាំ ១៩៨៣ មានការឈ្លបវាយប្រហាររបស់កងកម្លាំងខ្មែរក្រហម នៅ ស្រុកចំការលើ បណ្តាលឲ្យលោក **ញ៉ែម ហេង** អនុរដ្ឋមន្ត្រីក្រសួង កសិកម្ម និងអ្នកបច្ចេកទេសសូវៀតខាងដំណាំកប្បាស ០៩ នាក់ បានស្លាប់ និងធ្វើយុទ្ធនាការកាប់ឆ្ការព្រៃបំផ្លាញសំបុកលាក់ខ្លួន របស់ខ្មាំងនៅខ្ទួយ ក្នុងស្រុកស្ទឹងត្រង់ និងត្រពាំងកន្សែងនៅស្រុក ពញាក្រែក ។

នៅក្នុងឆ្នាំ១៩៨៤ គាត់ត្រូវបានផ្លាស់ចេញពីខេត្ត កំពង់ចាម ទៅកាន់មុខដំណែងជាអគ្គនាយកទេសចរណ៍ និងបាន បញ្ចប់ជីវិតរដ្ឋបាលនៅទីនោះ។

## ២៤- ហ៊ុន ណេង ( ១៩៨៤-១៩៩៩ )

គាត់កើតនៅថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ១៩៥០ នៅ ភូមិពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនទី២ក្នុងចំណោមបុត្តធីតា ៦នាក់ របស់មហាឧបាសក **ហ៊ុន នាង** និង មហាឧបាសិកា **ឌី ប៉ុក** និងត្រូវជាបងប្រុសរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។ គាត់មានតួនាទីសំខាន់បំផុតក្នុង គ្រួសារ នៅពេលដែលលោក **ហ៊ុន សែន** បានចូលរួមក្នុងចលនាតស៊ូរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលដឹកនាំដោយសម្តេច **នរោត្តម សីហនុ** ប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារក្រោយព្រឹត្តិការណ៍រដ្ឋប្រហារ ១៨ មិនា ១៩៧០ និងថែមទាំងទទួលរងនូវការធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង អំពីសំណាក់ពួកបនប្រល័យពូជសាសន៍នៅក្រោយព្រឹត្តិការណ៍បោសសំអាតភូមិភាគបូព៌ា នាឆ្នាំ ១៩៧៨ គ្រាដែលលោក **ហ៊ុន សែន** ចូលរួមដឹកនាំក្នុងចលនាតស៊ូ រំដោះជាតិស្ថិតក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។



ក្រោយពេលមាតុភូមិកម្ពុជាបានរំដោះនាថ្ងៃ ៧មករា ១៩៧៩ គាត់បានសិក្សាផ្នែកសេដ្ឋកិច្ចនៅទីក្រុងភ្នំពេញ និងទទួលមុខដំណែងជាប្រធានមន្ទីរផែនការខេត្តកំពង់ចាម នៅក្នុងឆ្នាំ

១៩៨១ ជាលេខា បក្ស និងជាប្រធានគណៈកម្មាធិការប្រជាជនស្រុកក្រូចឆ្មា ពីឆ្នាំ ១៩៨២ ដល់ ១៩៨៤ ដែលក្នុងរយៈពេលនេះ គាត់បានទៅបំពេញកម្មសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយនៅទីក្រុងហាណូយ ក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម និងត្រូវបានតែងតាំងជាលេខាបក្សខេត្ត និងជាប្រធានគណៈកម្មាធិការប្រជាជនខេត្តកំពង់ ចាម ក្នុងឆ្នាំ១៩៨៤។ គាត់ជាប្រមុខដឹកនាំខេត្តដ៏សកម្មនិងខ្លាំងក្លាបំផុតក្នុងបរិបទនៃការស្វ័យរ៉ាប់រងលើគ្រប់ភារកិច្ច នៅពេលដែលអ្នកជំនាញការ និងកងទ័ពស្ម័គ្រវៀតណាម ត្រូវបានធ្វើមាតុភូមិនិវត្តន៍ជាបន្តបន្ទាប់និងទាំងស្រុងនៅឆ្នាំ១៩៨៩។ គាត់បានបំពេញនូវតួនាទីបានល្អប្រសើរក្នុងពេលដែលប្រទេសជាតិ ស្ថិតនៅក្នុងដំណាក់កាលវាយផង ចរចាផង ដោយបានទប់ស្កាត់ប្រកបដោយជោគជ័យ នូវរាល់ការប៉ុនប៉ងវិលត្រឡប់មកវិញរបស់បនប្រល័យពូជសាសន៍ ដែលប្រើយុទ្ធសាស្ត្រច្រេះស៊ីដែក ដោយប្រើប្រាស់ កម្លាំងខ្មួត ៣យ៉ាងតាមភូមិឃុំ ។ គាត់បានបញ្ចៀសនូវរាល់ហានិ ភ័យក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំដោយ **អ៊ុនតាក់** និងរួមចំណែកក្នុងការអនុវត្តន៍នយោបាយឈ្នះឈ្នះ របស់សម្តេចនាយករដ្ឋមន្ត្រី ដែលនាំមកនូវឯកភាពជាតិ និងសុខសន្តិភាពយ៉ាងពេញលេញក្នុងខេត្ត និងក្នុងទូទាំងប្រទេស ។ គាត់ក៏ជាអ្នកកសាងជួរមន្ត្រី ដោយយកចិត្តទុកដាក់ចំពោះការបណ្តុះបណ្តាលអប់រំតម្រង់ទិស ការពារ និងលើកទឹកចិត្តក្នុងការបំពេញការងារ និងចេះជួយគ្នាទៅវិញទៅមក បង្កបាននូវបរិយាកាសសាមគ្គីភាពភាតរភាពយ៉ាងទូលំទូលាយជាមួយប្រជាពលរដ្ឋទូទៅដោយគ្មានការរើស

អើង ។ គាត់ផ្តល់នូវការស្រឡាញ់យ៉ាងជ្រាលជ្រៅចំពោះ មនុស្ស និងទឹកដីកំពង់ចាម និងទទួលបាននូវការគោរពជឿទុក ចិត្តពីមន្ត្រីកងកម្លាំងប្រដាប់អាវុធ និងប្រជាជនគ្រប់ស្រទាប់នៅ ក្នុងខេត្ត ។ គាត់មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការអភិវឌ្ឍខេត្ត ជាពិសេសក្រុងកំពង់ចាម ក្នុងនោះស្នាដៃដ៏លេចធ្លោរបស់គាត់គឺ



ការកសាងនូវផ្លូវជាតិលេខ ៧ ថ្មី និងស្ពានគីហ្សុយណា ដែលជាសម្បត្តិមហាសាលរបស់ខេត្ត ដែលជាជំនួយរបស់ប្រទេសជប៉ុន ក្នុងនោះឯកឧត្តម **ហ៊ុន ណេង** បានដោះស្រាយប្រកបដោយជោគជ័យនូវរាល់ផលប៉ះពាល់របស់ប្រជាជន។ជាការគួរឲ្យសោកស្តាយជាពន់ពេកនៅខែ មិនា ១៩៩៩ គាត់ត្រូវបានផ្លាស់ទៅកាន់មុខដំណែងជាអភិបាលខេត្តស្វាយរៀង ដែលនៅទីនោះគាត់បានធ្វើឲ្យមានការផ្លាស់ប្តូរមុខមាត់ដ៏ថ្មីស្រឡាងយ៉ាងឆាប់រហ័ស។

## ២៥-ជៀប អំ ( មិនា១៩៩៩-កុម្ភៈ២០០៥ )

គាត់មានដើមកំណើតនៅខេត្តស្វាយរៀងគឺជានាយទាហានជាន់ខ្ពស់ក្នុងអគ្គស្នងការ នយោបាយនៃកងទ័ពប្រជាជនកម្ពុជា ក្រោយ ថ្ងៃរំដោះ ៧មករា ១៩៧៩ រួចទៅកាន់មុខ ដំណែងជាលេខាបក្សខេត្ត និងជាប្រធានគណៈកម្មាធិការប្រជាជនខេត្តកំពង់ធំ ក្រោយពេលដែលកងទ័ពស្ម័គ្រចិត្តវៀតណាមធ្វើមាតុភូមិនិវត្តន៍ ។ គាត់មកកាន់មុខដំណែងជាអភិបាលខេត្តកំពង់ចាម ក្នុងខែមិនា ១៩៩៩ ដែលមានលោក **ម៉ៅ ភិរុណ** ជាអភិបាលរង និងអភិបាលរងចំនួន ២រូបទៀត មកពី គណបក្ស

**ហ៊ុន សុិនប៊ុច** គឺលោក **ចាវ គឹមឡុង** និង លោក **សៀក ជីវឡេង** ។ គឺក្នុងឆ្នាំនោះដែរ ដែលខ្ញុំត្រូវផ្លាស់ប្តូរមុខដំណែងពី ស្រុកស្រីសន្ធរ មកជាអភិបាលស្រុកកំពង់ចាម ។ ក្នុងអាណត្តិដឹក នាំរបស់គាត់ បានឆ្លុះបញ្ចាំងនូវភាពមិនសូវស៊ីសង្វាក់គ្នារវាងរូប គាត់ និងលោក **ម៉ៅ ភិរុណ** តែទោះជាមានករណីអវិជ្ជមាននេះ ក៏ដោយ ក៏លទ្ធផលការងារសំខាន់ៗមួយចំនួនធំ ត្រូវបានធ្វើឲ្យ សម្រេច ក្នុងនោះមាន ៖ ការស្នើសុំសេចក្តីសម្រេចចិត្តដ៏ខ្ពង់ខ្ពស់ ពីសម្តេចនាយករដ្ឋមន្ត្រីក្នុងការកាត់ដីចេញពីទ្រព្យរបស់រដ្ឋ នៅម្តុំ សាលាជាតិកសិកម្ម សាលាគរុកោសល្យខេត្ត និងភូមិភាគ ជូន ប្រជាជនរាប់រយគ្រួសារ ដែលបានតាំងទីលំនៅមិនស្របច្បាប់នៅ ទីនោះ។ ហេដ្ឋារចនាសម្ព័ន្ធក្នុងទីប្រជុំជន និងតាមបណ្តាស្រុក ត្រូវបានកសាង និងកែលំអរ ជាមួយនិងអាគារសិក្សា ព្រមទាំងវត្ត អារាមជាច្រើនដែលជាអំណោយរបស់ប្រមុខរាជរដ្ឋាភិបាល និង



សប្បុរសជនក្នុង និងក្រៅប្រទេស ។ នៅថ្ងៃទី២២ កុម្ភៈឆ្នាំ ២០០៥ គាត់ក៏ត្រូវបានផ្លាស់ចេញទៅទទួលមុខដំណែងជាអភិ បាលខេត្ត ស្វាយរៀងរហូតដល់សព្វថ្ងៃ រីឯលោក **ម៉ៅ ភិរុណ** បានទៅកាន់ ដំណែងជាអភិបាលរងខេត្តកណ្តាល រួចជាប្រធានក្រុមប្រឹក្សាខេត្ត និងក្លាយជាអភិបាលខេត្តនៅដើមឆ្នាំ ២០១៥ ។

**២៦- ហ៊ុន ណេង (ថ្ងៃទី ២២ កុម្ភៈ ២០០៥ ដល់ ថ្ងៃ ១៣ ឧសភា ២០១៣** )

ឯកឧត្តម **ហ៊ុន ណេង** បានវិលត្រឡប់មកកាន់ដំណែងជាអភិបាលខេត្តកំពង់ចាម សាជាថ្មី ឡើងវិញជាមួយនិងការនាំមកនូវឯកភាព សាម គ្គីភាព និងការប្តេជ្ញាចិត្តខ្ពស់ក្នុងជួរមន្ត្រីរាជការគ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រជាពលរដ្ឋទូទាំងខេត្ត ក្នុងការអភិវឌ្ឍទឹកដី និងជីវភាពរស់នៅឲ្យកាន់តែប្រសើរថែមទៀត ។ អាគារសាលាខេត្ត ត្រូវបានកែរ លំអរ និងសាងសង់បន្ថែមនូវអាគារ ២ទៀត នៅអមសងខាង និង សាលសន្និសិទ្ធដ៏ស្រស់ត្រកាលមួយនៅពីក្រោយ ព្រមទាំងអាគារសម្រាប់កីឡាវាយសី និងរោងសម្រាប់កីឡាប៉េតង់។ មន្ទីរអង្គភាពមួយចំនួនត្រូវបានកសាងជាថ្មី និងបានកែរលំអរ ក្នុងនោះមាន សាខាធនាគារជាតិ អាគារមន្ទីរពេទ្យ មន្ទីរផែនការ មន្ទីរសុខា ភិបាល មន្ទីរការងារ មន្ទីរព័ត៌មាន គណៈកម្មការបោះឆ្នោតខេត្ត... ការផ្លាស់ប្តូរនូវពន្ធនាគារចេញពីក្រុង ទៅកសាងថ្មីនៅទួលវិហារ សាលាសង្កាត់បឹងកុក កំពង់ចាម និងវាលវង់ ព្រមទាំងសាលាស្រុកចំការលើ កោះសូទិន និងត្បូងឃ្មុំ ។ គាត់បានធ្វើការដឹកនាំកសាងអាគារដ៏ធំស្កឹមស្កៃ នៃពុទ្ធិកៈសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នៅវត្តសុទស្សនារាមជ្រោយថ្ម និង សមិទ្ធិដំកល់សម្រាប់ព្រះពុទ្ធសាសនាជាច្រើនកន្លែងនៅក្នុង ខេត្ត។ លើវិស័យអប់រំ គាត់បានជម្រុញការកសាងអាគារសិក្សាជា ច្រើនកន្លែង ក្នុងនោះនៅក្រុងកំពង់ចាម វិទ្យាល័យសំបួរមាស វិទ្យាល័យដីដុះ និងអនុវិទ្យាល័យទួលថ្ម ត្រូវបានបង្កើតជាមួយនឹងការកសាងអាគារសិក្សាជាច្រើនខ្នង ។ សោភ័ណភាពក្រុង ត្រូវបានមមារញឹកក្នុងការកែរលំអរ ដោយប្រើប្រាស់នូវថវិកាខេត្ត

និងជាពិសេស ថវិកាដែលឯកឧត្តមបានចលនាមកពីសប្បុរសជននានានាំឲ្យសម្រេចបានការពង្រាយបណ្តាញភ្លើងបំភ្លឺសាធារណៈនៅស្ទើរតែគ្រប់ផ្លូវនៅក្នុងក្រុង ផ្លូវក្រាលដីដារត្រូវប្រែក្លាយជាផ្លូវ ក្រាលកៅស៊ូ ផ្លូវក្រាលកៅស៊ូត្រូវកែរលំអរដោយចាក់បេទីមរំលេច ដោយប័រឡៀរនិងការ៉ូការ៉ូឡា ព្រមទាំងដើមលឿងរាជ ក្របៃកព្រៃ នៅតាមចិញ្ចើមផ្លូវ បណ្តាញលូបង្ហូរទឹកជាច្រើនខ្សែរ ច្រាំងទន្លេមេគង្គចាប់ពីចំណុចរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ដល់វត្តដីដុះ ត្រូវបានរៀបចំជារបាំងការពារទឹកជំនន់ផង ជាសួនច្បារ និងជាទីលំហែរដ៏ស្រស់ត្រកាលផង...។ សមិទ្ធិតាមបណ្តាស្រុកក្នុងខេត្តត្រូវបានធ្វើឲ្យសំរេចជាច្រើនក្នុងអណត្តិនៃការដឹកនាំរបស់គាត់ ។ ចំពោះការងារវិនិយោគ គាត់បានទាក់ទាញនូវវិនិយោគិនជាច្រើននាក់មកបណ្តាក់ទុនរកស៊ីក្នុងខេត្ត ដោយបង្កបាននូវបរិយាកាសងាយស្រួលដល់អ្នកទាំងនោះ ព្រមទាំងអាជីវករទូទៅ ក្នុងនោះ អ្នកលក់ដូរនៅផ្សារធំកំពង់ចាម និងបឹងកុក ត្រូវបានពន្យាអាណត្តិជួលតូបក្នុងផ្សារពី ៥ឆ្នាំ ដល់១០ឆ្នាំ ។ ខេត្តកំពង់ចាមត្រូវបានធនាគារអភិវឌ្ឍអាស៊ី ( ADB ) វាយតម្លៃជាខេត្តដឹកមុខគេក្នុងការសម្រួលបរិយាកាសដល់សហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តំបន់ឆ្នេរខ្សាច់ដែលលាតសន្ធឹងចាប់ពីស្ពានីយឧតុនិយមជ្រោយថ្ម មកសណ្ឋាគារមេគង្គ ត្រូវបានប្រែក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលបានបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ បឹងស្នាយត្រូវបានបូមខ្សាច់ចាក់បំពេញដោយក្រុមហ៊ុន**ថាវីពាណិជ្ជ** ដោយត្រូវបែងចែកផ្ទៃដី ៦០% សម្រាប់អ្នកវិនិយោគ និង៤០%សម្រាប់រដ្ឋ ។ គឺក្នុងចំណែកដីសម្រាប់រដ្ឋនេះ ហើយ

ដែលឯកឧត្តម **ហ៊ុន ណេង** បានសម្រេចប្រគល់ឲ្យជន ក្រីក្រ ១៣០គ្រួសារ ដែលតាំងទីលំនៅមិនស្របច្បាប់តាមចិញ្ចើម ផ្លូវក្រោយមន្ទីរពេទ្យ ផ្លូវតាមមាត់ទន្លេដែលជាប់ព្រំប្រទល់សង្កាត់ កំពង់ចាម និងបឹងកុក និងម៉ុំអតីតឃ្លាំងកសិកម្មនៅជិតសណ្ឋាគារ មេគង្គ ដោយក្នុងមួយគ្រួសារទទួលបានដី ៤មx១០ម មានផ្លូវថ្នល់ មានភ្លើងអគ្គីសនី បណ្តាញទឹកស្អាត និងសម្ភារៈសម្រាប់បង្គន់ អនាម័យ ព្រមទាំងមានជំនួយកាកបាទក្រហមមួយចំនួនសម្រាប់ ទ្រទ្រង់ជីវភាព ។ ពិធីប្រគល់និងទទួលនេះ បានប្រព្រឹត្តិទៅនៅ ថ្ងៃទី ៩ មិថុនា ២០១០ និងជាបន្តបន្ទាប់មកទៀត ក្នុងឆ្នាំ២០១៣ គាត់បានប្រគល់ដីទំហំ ៤មx២០ម សម្រាប់មួយគ្រួសារដល់មន្ត្រី រាជការ និងមន្ត្រីនគរបាលជាច្រើននាក់ ដែលរស់នៅតាមមន្ទីរ អង្គភាព និងថែមទាំងកសាងនូវអាគារសិក្សាមួយខ្នង មាន៥បន្ទប់ នៅទីនោះ ដែលប្រែក្លាយជា **ភូមិតាណេង** ដែលជាភូមិទី១០ នៃសង្កាត់សំបួរមាស។គាត់តែងតែផ្តល់ដំបូន្មានដល់ខ្ញុំថា នៅតាម ស្រុកគេត្រូវរកដីធ្លីឲ្យប្រជាជនធ្វើស្រែចំការ ឯនៅទីក្រុងយើងត្រូវ តែរកន្លែងលក់ដូរជូនពួកគាត់ គឺអាស្រ័យដោយហេតុនេះហើយ បានជាគាត់បង្កើតផ្សារបឹងកុកក្នុងរាជរដ្ឋាភិបាលអណត្តិទី១ ផ្សារ ៧មករា ក្នុងឆ្នាំ២០១០ និងផ្សារចុងថ្នល់ក្នុងឆ្នាំ២០១៣ ។ នេះគឺជា ក្តីមោទនភាពណាស់ដែលខេត្តកំពង់ចាម បានងើបចេញអំពីការ វិនាសហិនហោចខ្លោចផ្សារ ដោយសង្គ្រាមវិនាសកម្មចំនួនប្រាំឆ្នាំ មួយខែ និងការបំផ្លិចបំផ្លាញដល់ឫសគល់ក្នុងសម័យរបបប្រល័យ ពូជសាសន៍បីឆ្នាំមួយខែប្រាំពីរថ្ងៃបានរស់ឡើងវិញ និងរីកចម្រើន ដូចសព្វថ្ងៃ បីដូចជាសត្វហ្វេនិច( PHENIX ) ដែលរស់ឡើងវិញពី

គំនរផេះផង់របស់ខ្លួនដែរ។ ឯកឧត្តម **ហ៊ុន ណេង** ត្រូវបានចូល និវត្តន៍ និងបានផ្ទេរមុខដំណែងជូនឯកឧត្តម **លន់ លឹមថៃ** នៅថ្ងៃ ទី១៣ ឧសភា ២០១៣។ ក្រោយការបោះឆ្នោតសកលឆ្នាំ ២០១៣ គាត់បានជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម ព្រមទាំងទទួលការទុកចិត្តពីសភាក្នុងដំណែងជាប្រធានគណៈកម្មការទី៤ និងជាសមាជិកគណៈអចិន្ត្រៃយ៍នៃរដ្ឋសភានីតិកាលទី ៥ ។



**២៧- លន់ លឹមថៃ** ( **ពីថ្ងៃទី ១៣ ឧសភា ២០១៣ មក**...... )

គាត់កើតនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៥៧ នៅភូមិកោះកុក ឃុំកោះទន្ទឹម ស្រុកកំពង់ សៀម ខេត្តកំពង់ចាម។ គាត់ជាកូនប្រុសពៅ ក្នុងចំណោមបុត្រធីតារៀមច្បង ០៥នាក់ និងបុត្រ ០២នាក់ របស់ ឧបាសក **លន់ ស៊ឹម** និង ឧបាសិកា **ទួន ង៉ោ** មានមុខរបរជា កសិករ។ កុមារភាព និងយុវវ័យរបស់លោកបានរីកចម្រើនធំធាត់ ដោយផ្សារភ្ជាប់ជីវភាពជាក្មេងវត្តនៅវត្តគគរ ឃុំគគរ ស្រុកកំពង់ សៀម ក្នុងការសិក្សាផ្នែកបឋមសិក្សានៅវត្តជ្រោយថ្ម ក្នុងសង្កាត់ កំពង់ចាម ក្នុងការសិក្សានៅវិទ្យាល័យព្រះសីហនុ ។ នៅក្នុងឆ្នាំ ១៩៧៣ ក្រោយព្រឹត្តិការវាយលុករបស់កងកម្លាំងខ្មែររំដោះ ក្នុងទីប្រជុំជនកំពង់ចាម គាត់បានរត់ភៀសខ្លួនទៅបន្តការសិក្សានៅវិទ្យាល័យ**ប្រ៊ូវីជង់** ដោយស្នាក់នៅវត្តបទុមវតី ។ នៅក្នុងសម័យរបបប្រលយ័ពូជសាសន៍ គាត់បានរួចរស់ជីវិតយ៉ាងប្រផិតប្រផើយ ក្នុងជីវិតជាយុវជនកងចល័តនៅស្រុកកំណើត ដោយត្រូវឃ្លាតពី

គ្រួសារទៅធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរនៅការដ្ឋាននានា នៅក្នុងឃុំស្រែកល្ពាក... ។ ក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ គាត់បានចំណាយពេលទៅប្រកបមុខរបររកស៊ី ដើម្បីទ្រទ្រង់ជីវភាពគ្រួសារមួយរយៈ ទើបមកចូលបម្រើការងារធ្វើជាគ្រូបង្គោលប្រចាំឃុំកោះ ទន្ទឹម ។ អាស្រ័យដោយគាត់មានទេពកោសល្យក្នុងកីឡាបាល់ទះ និងឈ្លាសវៃក្នុងការងាររដ្ឋបាល គាត់ត្រូវបានដកមកបំពេញការងារនៅមន្ទីរអប់រំខេត្ត ហើយទទួលបានមុខដំណែងជាមន្ត្រីទទួលការងារបូកសរុបរបស់សាលាខេត្ត ជាអនុប្រធាន និងជាប្រធានមន្ទីរខេត្តនៅឆ្នាំ១៩៩៩។ នៅចុងខែ ឧសភា ២០០៩ គាត់ត្រូវបានតែងតាំងជាអភិបាលរងខេត្តកំពង់ចាម ដែលធ្វើជាជំនួយការដ៏សំខាន់របស់ឯកឧត្តម **ហ៊ុន ណេង** ក្នុងកិច្ចការរដ្ឋបាល និងការអភិវឌ្ឍមុខមាត់របស់ខេត្ត។ គាត់បានចូលកាន់មុខដំណែងជាអភិបាលខេត្តកំពង់ចាម នៅថ្ងៃទី ១៣ ឧសភា ដោយចាប់ផ្ដើមទទួលកិត្តិយសជាស្ដេចមាឃ និងភរិយាគាត់ជាមេហួ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទនរោត្តម **សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យជ្រើសរើសយកខេត្តកំពង់ចាមជាខេត្តទី១ ដើម្បីប្រារព្ធនូវព្រះរាជពិធីនេះនៅថ្ងៃទី ២៨ ខែ ឧសភា ២០១៣ នៅទីលានបាល់ទាត់ក្រុងកំពង់ចាម។ នៅថ្ងៃទី ២ មិថុនា ឆ្នាំ ២០១៤ ខេត្តត្បូងឃ្មុំត្រូវបានប្រកាសជាផ្លូវការ ដោយបំបែកខ្លួនចេញពីខេត្តកំពង់ចាម ដែលរួមមានស្រុកក្រុងចំនួន ៧ ប្រកបដោយសក្តានុពលសេដ្ឋកិច្ចនៅប៉ែកខាងកើតទន្លេ ក្នុងនោះ មាន៖ ស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ក្រុងសួង ស្រុកអូររាំងឪ ស្រុកពញាក្រែក

ស្រុកតំបែរ និងស្រុកមេមត់ជាចំណុះ ។ ទឹកដី ខេត្តកំពង់ចាមត្រូវរួមតូច ដោយបន្សល់ទុកស្រុកក្រុងចំនួន ១០ មានក្រុងកំពង់ចាម ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម ស្រុក ចំការលើ ស្រុកព្រៃឈរ ស្រុកកងមាស ស្រុកជើងព្រៃ ស្រុក បាធាយ ស្រុកស្រីសន្ធរ និងស្រុកកោះសូទិន ដែលជាតំបន់ស្រែ ចំការ និងភាគច្រើនតែងតែទទួលរងនូវឥទ្ធិពលពីទឹកជំនន់ទន្លេ មេគង្គ ។ ឯកឧត្តម **លន់ លឹមថៃ** បានសម្រួចនូវឆន្ទៈនយោបាយខ្ពស់ក្នុងការបន្តនិរន្តរភាពការដឹកនាំខេត្តបន្ទាប់ពីឯកឧត្តម **ហ៊ុន ណេង** ដោយបានដាក់ភ្លើងបញ្ជាចរាចរណ៍ក្នុងក្រុងជាលើកដំបូង ចំនួន ៤កន្លែង នៅចុងឆ្នាំ២០១៣ កសាងនូវផ្លូវភ្លោះលើកំណាត់ ផ្លូវជាតិលេខ៧ថ្មី កសាងរូបសំណាកចំនួន ៤ក្នុងក្រុង នៅមាត់ ទន្លេចំពីមុខសាលាខេត្ត នៅរង្វង់មូលតំបន់ប្រតិបត្តិសឹករងខេត្ត នៅផ្លូវបំបែករវាងផ្លូវជាតិលេខ៧ចាស់ និងផ្លូវជាតិលេខ៧ថ្មី និង រូបនាងគង្ហីងនៅព្រំប្រទល់សង្កាត់វាលវង់ និងសង្កាត់សំបួរមាស ព្រមទាំងរូបសំណាកដ៏ធំស្ពឹមស្ពៃ ជានិមិត្តរូបរបស់ខេត្តនៅត្រើង ចំព្រំប្រទល់រវាងស្រុកកំពង់សៀម ចំការលើ និងព្រៃឈរ និងរូប សំណាកនៅផ្លូវបំបែកស្គន់ក្នុងស្រុកជើងព្រៃ ។ ឯកឧត្តមបានបន្ត ការខិតខំប្រឹងប្រែងស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុង និង តាមបណ្តាស្រុក ក្នុងនោះមានជាអាទិ៍ ការពង្រីកការផ្គត់ផ្គង់ទឹក ស្អាត ដោយយកទឹកទន្លេមេគង្គជាប្រភព ក្រោមជំនួយឧបត្ថម្ភ របស់ទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិជប៉ុន (JAICA) ការជួសជុល កែរលំអរច្រាំងទន្លេ និងការទាក់ទាញវិនិយោគិនមកបណ្តាក់ទុន រកស៊ីក្នុងខេត្ត សំដៅបង្កើតការងារជូនប្រជាពលរដ្ឋ ក្នុងកាលើក

កម្ពស់ជីវភាពរស់នៅឲ្យកាន់តែប្រសើរថែមទៀត ដើម្បីកាត់បន្ថយនូវភាពក្រីក្រតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី របស់រាជរដ្ឋាភិបាល។

## អំពីទិដ្ឋភាពភូមិសាស្ត្រនិងសង្គមខ្លះៗរបស់ខេត្តកំពង់ចាម

កំពង់ចាម គឺជាខេត្តប្រកបដោយសក្តានុពលមួយនៅប៉ែកឥសានរាជធានីភ្នំពេញ មានផ្ទៃក្រឡា ៩.៧៩៨,៦០ គម$^{២}$ ។ ខេត្ត

កំពង់ចាម មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តតែនិញ និងខេត្ត ប៊ិញភឿកនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមាន ប្រវែង ១៨៣ គ.ម ខាងលិចទល់នឹងខេត្តកំពង់ធំ ខាងជើងទល់ នឹងខេត្តក្រចេះ ខាងត្បូងទល់នឹងខេត្តកណ្ដាល ។ ស្ថានភាពភូមិសាស្ត្ររបស់ខេត្តចែកចេញជាពីរតំបន់គឺ តំបន់វាលទំនាបនៃទន្លេ មេគង្គ និងតំបន់ខ្ពង់រាប ។ តំបន់វាលទំនាបនៃទន្លេមេគង្គ ដែល រួមមាន ៖ ក្រុងកំពង់ចាម ស្រុកក្រូចឆ្មា ស្រុកកំពង់សៀម ស្រុក កងមាស ស្រុកកោះសូទិន ស្រុកស្រីសន្ធរ និងមួយភាគនៃស្រុក ព្រៃឈរ ជើងព្រៃ បាធាយ និងស្ទឹងត្រង់ ដែលជាតំបន់ងាយរងគ្រោះដោយទឹកជំនន់ទន្លេមេគង្គ តែជាតំបន់ដែលមានផ្ទៃដីប្រកប ដោយជីវជាតិសម្រាប់ដំណាំចំការគ្រប់មុខ និងស្រូវទាំងរដូវប្រាំង និងរដូវវស្សា។ តំបន់ខ្ពង់រាបមាន ៖ ស្រុកអូរាំងឪ ស្រុកត្បូងឃ្មុំ ក្រុងសួង ស្រុកពញាក្រែក ស្រុកមេមត់ ស្រុកតំបែរ ស្រុកចំការ លើ និងមួយភាគនៃស្រុកស្ទឹងត្រង់ និងក្រូចឆ្មា ដែលភាគច្រើន ជាដីក្រហមសម្រាប់ដំណាំកៅស៊ូ ព្រមទាំងដំណាំគ្រប់មុខ និង ក្រៅពីនោះ ជាដីសម្រាប់ស្រែវស្សា ។ តាមតួរលេខជំរឿនថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៦២ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ៨២១.០៣០ នាក់ ក្នុងពេលដែលប្រជាពលរដ្ឋទូទាំងប្រទេសមាន ចំនួន ៥.៧២៨.៧៧១ នាក់ ជាខេត្តដែលមានប្រជាពលរដ្ឋច្រើន ជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ។ តាមទិន្នន័យភូមិ ឃុំ សង្កាត់ ឆ្នាំ២០១២ ខេត្តកំពង់ចាម មានប្រជាជនសរុប ១.៨៧១.៨៧១នាក់ មានដង់ស៊ីតេ ១៨៧នាក់ / ១គម² មាន ១៥ស្រុក ២ ក្រុង ចែកជា ១៦៧ ឃុំ ៦ សង្កាត់មានភូមិសរុប ១.៧៥៩ ។ ក្នុងសៀវភៅដែល

ខ្ញុំចងក្រងនេះ ពុំបានពិពណ៌នាអំពីស្ថានភាពលំអិតពីភូមិសាស្ត្រ ប្រជាសាស្ត្រ និងសង្គមសាស្ត្រនៅក្នុងវិសាលភាពដ៏ធំធេងរបស់ខេត្តកំពង់ចាមទេ ខ្ញុំគ្រាន់តែធ្វើការបរិយាយពីក្រុងកំពង់ចាមដែលជាមជ្ឈមណ្ឌលរដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខេត្តតែប៉ុណ្ណោះ ។

ក្នុងសម័យអង្គរ កំពង់ចាមគ្រាន់តែជាភូមិមួយនៅតាមដងទន្លេមេគង្គ ក្នុងខេត្តបាជ័យ ដែលមានទីតាំងនៅម្តុំប្រាសាទនគរ បាជ័យ ដែលបានកសាងក្នុងរជ្ជកាលព្រះបាទជ័យវរ័ន្មទី ៧ ។ ក្នុង គ្រានោះ កំពង់ចាមចែកជា ២តំបន់ គឺតំបន់ព្រៃស្រោងនៅខ្ពង់រាប ដែលលាតសន្ធឹងពីទិសនិរតីដល់ទិសឧត្តរ និងតំបន់វាលរាបដែលពោរពេញដោយព្រៃរនាម ស្ទឹង បឹងបួរ នៅទិសខាងកើតតាមដងទន្លេមេគង្គ ។ តាមឯកសារមហាបុរសខ្មែរ នៅក្នុង គ.ស ១២២៥ ព្រះបាទសម្តេចព្រះ**ឱង្កា** បានដឹកនាំពលរេហ៍ពីមហានគរមកទត ទន្លេធំ និងពុំឃើញមានមនុស្សរស់នៅក្នុងកំផែងប្រាសាទនគរបា ជ័យបានការដោយខ្លាចនូវឫទ្ធិបារមីរបស់ព្រះរាជអយ្យកោដែល សន្ថិតនៅទីនោះ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យកសាងនូវវត្តចំនួនពីរ មួយនៅខាងក្នុង និងមួយទៀតនៅខាងក្រៅប្រាសាទ និងបានផរ ប្រគេនចំពោះព្រះ**នាគសេន** គង់ចាំព្រះវស្សានៅវត្តទាំងពីរនេះ ។ ក្នុងឯកសារដដែលនេះបានរំលេចផងដែរ ក្នុងរជ្ជកាលព្រះបាទ **លំពង់រាជា** (គ.ស ១៣៤៦-១៣៥១ ) ព្រះអគ្គមហេសី របស់ព្រះ**សិរីសុគន្ធចក្រ**ដែលត្រូវជាបុត្ររបស់ព្រះ**និព្វានបទ** និងត្រូវជាបងរួមអយ្យកោ(បងជីដូនមួយ)របស់ព្រះរាជា បានដង្ហែរនូវព្រះអដ្ឋិព្រះស្វាមីមកបញ្ចុះនៅនគរបាជ័យបានការដែលជាស្រុកកំណើតរបស់ ព្រះអង្គ

និងចាត់ឲ្យកសាងបដិមាករស្នងរូបមួយ ដែលអ្នកស្រុកនាំគ្នាហៅថាអ្នកតា**សុគន្ធចក្រ**រហូតដល់សព្វថ្ងៃ ។ ក្នុងរជ្ជកាលព្រះបាទ**ព្រះធម្មោរាជា** (គ.ស១៤៧៨-១៥០៤ ) ក្រោយពេលដែលព្រះអង្គសម្រេចបាននូវឯកភាព ដឹកដីពីសង្គ្រាមផ្ទៃក្នុងជាមួយព្រះ**ស្រីសុរិយោទ័យ** និងព្រះ**ស្រីរាជា** ព្រះអង្គបាននាំព្រះរាជវង្សា នុវង្សនិងព្រះរាជបរិពារមកក្រសាលនៅនគរបាជ័យ ទ្រង់បានកោតសរសើរព្រះ**អរត្តពលពាលោ** ដែលមានបុណ្យបារមីជាពន់ ពេកដោយស្តេចបានកសាងរាជវាំងគ្រាន់មកកំសាន្តម្តងៗទេ តែស្តេចបានកសាងពីថ្ម ទាំងប្រាសាទ ទាំងកំផែង មានស្រះស្រង់ រងថ្លាមានទាំងទន្លេសម្រាប់ព្រះស្នំ និងក្រុមបរិពារអុំទូកលេង កំសាន្ត ។ ក្នុងការស្នាក់អាស្រ័យនោះ ព្រះ**រតនៈមាលី** ជាព្រះរាជបុត្រីបានយាងទៅស្រង់ទឹកទន្លេធំនៅទីកំពង់ចាម ដែលមានដុះខ្សាច់ជ្រាលជ្រេល្អ ហើយក៏ត្រូវក្រពើវេទមន្តមកពីព្រែកឆ្លូងបានត្របាក់លេបព្រះនាងយកចេញទៅ នាំឲ្យព្រះអង្គចាត់ពលសេនាតាមចាប់ធ្លាក់រហូតដល់កងមាស និងឡើងទៅតាមចាប់បានរហូតដល់ព្រែកឆ្លូង ជាទីដែលព្រះអង្គបានបូជាព្រះសពរបស់ព្រះនាងនិងកសាងចេតីយ៍តម្កល់ព្រះអដ្ឋិនៅទីនោះ ដែលប្រជាជនហៅ ថា "វត្តសសរមួយរយ" ទល់សព្វថ្ងៃ ។ ព្រឹត្តិការណ៍តាមប្រមាញ់ក្រពើដែលកាចសាហាវនេះ បានផ្តល់ឈ្មោះឲ្យភូមិមួយចំនួននៃស្រុកកងមាស ដូចជា កងតាណឹង រកាអារ ជាដើម ។ ក្នុងសម័យសង្គ្រាមក្នុងស្រុក រវាងហ្លួងព្រះស្តេច**កន** និងព្រះ**ចន្ទរាជា** នៅក្នុង គ.ស ១៥២១ ស្តេច**កន** បានបាក់ទ័ព ដោយបានបរសេះនាំទាហានរួមទាំងអាវុធរត់កាត់មកចុងភូមិកំពង់ចាម ដោយតោងសេះ

ហែលទឹកទៅព្រែកជីកជូនម៉ៅ ។ ការបរិយាយខាងលើនេះ ហាក់ដូចជាប្រាសចាកពីការរៀបរាប់ពីស្ថានភាពភូមិសាស្ត្ររបស់កំពង់ចាមហើយ តែវាជាការឆ្លុះបញ្ចាំងឲ្យបានច្បាស់ពីអត្តសញ្ញាណ នៃពាក្យកំពង់ចាមដែលមានពីយូរលង់មកផង និងថែមទាំងអាចវាយតម្លៃពីស្ថានភាពភូមិសាស្ត្រនៃទឹកដីនេះផង។ ដូចដែលបានបរិយាយពីខាងដើមមកថា *កំពង់ចាម* បានក្លាយជាប៉ុស្តិ៍រដ្ឋបាលរបស់ទេសាភិបាលបារាំងនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៨៩៧ ដោយរួមបញ្ចូលក្នុងនូវការគ្រប់គ្រងខេត្តនៅក្នុងសម័យបុរាណជា ច្រើនដែលក្នុងសម័យនោះ នៅ***ព្រះរាជាណាចក្រកម្ពុជា***ត្រូវបានបារាំងស្នើសុំបង្កើតតែប៉ុស្តិ៍រដ្ឋបាល តែ១១ប៉ុណ្ណោះ គឺ កំពត កំពង់ស្វាយ ពោធិ៍សាត់ និង ក្រចេះ ដែលបានស្នើសុំដោយ លោក **ពីកកេរ**(Geoge Jules Piquet) ក្នុងឆ្នាំ ១៨៨៦ និងក្នុងឆ្នាំ ១៨៩៧ លោក **ឌុយ កុស** បានស្នើបន្ថែម ៦ប៉ុស្តិ៍រដ្ឋបាលទៀត មាន កំពង់ចាម កំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង តាកែវ និងស្វាយរៀង ដោយឡែកភ្នំពេញបានបង្កើតរួចពីមុនមកហើយ។ ការរៀបចំប៉ុស្តិ៍រដ្ឋបាលបារាំងនេះ គឺជាការពង្រឹងឥទ្ធិពលត្រួតត្រារបស់បារាំងនៅ កម្ពុជាលើប្រព័ន្ធរដ្ឋបាលដែលមានក្នុងសមយ័បុរាណ និងឈានទៅកំណែរទម្រង់រដ្ឋបាលសម័យទំនើបមួយ តាមប្រព័ន្ធគ្រប់គ្រងរបស់បារាំង។ ការកសាងបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ទំនាក់ទំនងរវាងប៉ុស្តិ៍រដ្ឋបាលទាំងអស់ ត្រូវបានជម្រុញយ៉ាងខ្លាំងក្លាចាប់ ពីឆ្នាំ ១៩០០មក រហូតដល់ឆ្នាំ១៩១៦ តាមរយៈការប្រើប្រាស់កំណែនពលកម្មប្រជាជននៅគ្រប់ទិសទី ដែលធ្វើឲ្យប្រជាកសិករយើងរ៉ែកពុននូវអម្រែកដ៏សែនធ្ងន់គឺជាប់កំណែនទ័ពទៅច្បាំងនៅទ្វីបអឺរុប

ក្នុងសង្គ្រាមលោកលើកទី១ផង កំណែនពលកម្មផង និង បន្ទុកពន្ធដារគ្រប់មុខផង ញុំាងឲ្យការនិរាសព្រាត់ប្រាស់និងទុរគ្គត ភាពគ្របដណ្តប់លើសង្គមខ្មែរ ដែលទើបតែបានរួចផុតអំពីការ វិនាសសាបសូន្យ ពីការពុះហែកចែកគ្នារបស់ប្រទេសជិតខាង ។ ដើម្បីឲ្យរួចផុតអំពីសំណាញ់ដែកនៃកំណែនទាំងនេះ ប្រជាជន យើងមួយចំនួន ពិសេសយុវវ័យ បានគេចទៅលាក់ខ្លួនក្នុងព្រៃ រហូតដល់ទៅខ្លាចបាក់ស្បាត ដោយគ្រាន់តែឃើញពួកបារាំងពី ចម្ងាយ នាំគ្នាដាក់មេផាយជាស្វ័យប្រវត្តិ។ តាមរាជបញ្ញត្តិ ចុះថ្ងៃទី ១១ កក្កដា ១៩០៣ បារាំងបានជ្រើសរើសពលរដ្ឋខ្មែរឲ្យចូលបម្រើ នៅក្នុងកងអនុសេនាធំចំនួន ២ នៃកងវរសេនាតូចទាហាននាំមុខ (Bataillon des tirailleurs) ។ វាជាការពិត ដែលក្នុងសម័យបុរាណ កម្លាំងទ័ពនៅកម្ពុជា ជាកម្លាំងមិនរៀបរយ ពោលគឺនៅពេលដែល មានតម្រូវការចាំបាច់ក្នុងការធ្វើសង្គ្រាមដណ្តើមអំណាចក្នុងស្រុក និងសង្គ្រាមប្រឆាំងនឹងការឈ្លានពានពីប្រទេសជិតខាង ព្រះរាជា តែងតែចាត់ឲ្យស្តេចត្រាញ់ ឬចៅហ្វាយខេត្តកេណ្ឌប្រជាកសិករ ទៅច្បាំង ដោយពុំមានការហ្វឹកហ្វឺនត្រឹមត្រូវ ដោយប្រើប្រាស់ដាវ លំពែង ធ្នូ ស្នា.. ជាអាវុធគួបផ្សំនឹងអាគមអូមអាមដែលចេះចាំតៗ គ្នា នៅពេលចប់ចម្បាំង អ្នកដែលមានភ័ព្វវាសនារួចរស់ជីវិត បាន វិលត្រឡប់ទៅធ្វើស្រែចំការវិញ ។ កាលដែលបារាំងកសាងកម្លាំង ទ័ពរៀបរយនេះ បារាំងជួបនឹងការលំបាកជាច្រើនដោយអ្នកដែល មានសម្បទាគ្រប់គ្រាន់ បានព្យាយាមគេចវេះពីការជ្រើសរើស និង ពីកំណែន។ ទន្ទឹមគ្នានឹងនោះដែរ កម្លាំងតម្រួតក្នុងស្រុក( Gardes indigènes) ក៏បានជ្រើសរើស និងដាក់ពង្រាយធ្វើសកម្មភាពតាម បណ្តាស្រុក ។

កម្លាំងនេះ បានជួយដល់បេសកកម្មក្នុងការធ្វើឋាន លេខាតាមស្រុក ។ ចាប់ពីឆ្នាំ ១៩០៥ ទៅ គ្រប់ភូមិទាំងអស់មាន ក្នុងចំណុចដៅ ( Repères ) ដែលអាចចងក្រងជាផែនទីទូទៅនៃ ប្រទេសកម្ពុជា ។ ទីចាត់ការភូមិបាលតាមខេត្ត ប្រហែលជាបង្កើត នៅក្រោយពេលនេះបន្តិច ។ ក្នុងឆ្នាំ ១៩០៦ បារាំងបានបង្កើតឲ្យ មានមណ្ឌលសុខាភិបាល (Centre médical ) មួយ ក្នុងមួយប៉ុស្តិ៍ រដ្ឋបាល ដែលដឹកនាំដោយគ្រូពេទ្យបារាំងម្នាក់ និង គិលានុបដ្ឋាក ដែលជ្រើសរើសក្នុងស្រុក ។

ចាប់ពីថ្ងៃទី ២០ មេសា ១៩១១ មក ពលរដ្ឋខ្មែរត្រូវគោរព និងអនុវត្តតាមក្រមព្រហ្មទណ្ឌថ្មី ដែលកសាងឡើងចេញពីច្បាប់ បារាំង គួបផ្សំទៅនឹងសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា ប្រព័ន្ធ តុលាការដែលមានស្រាប់ត្រូវបានពង្រឹង ។ រាជបញ្ញត្តិចុះថ្ងៃទី ១១ មេសា ឆ្នាំ១៩១២ តម្រូវឲ្យម្តាយឪពុកបញ្ជូនកូនប្រុសស្រីឲ្យទៅ សាលារៀន បើពុំនោះសោតត្រូវជាប់ទោសព្រហ្មទណ្ឌ ។ នៅក្នុង ប្រព័ន្ធអប់រំបារាំង បានទទួលស្គាល់សាលាវត្តនៅតាមភូមិជាការ សិក្សាកម្រិតទី១(Enseignement du Premier degré) ការសិក្សា កម្រិតទី២ នៅតាមទីប្រជុំជន ( Enseignement élémentaire ) រីឯការសិក្សាកម្រិតទី៣ នៅតាមប៉ុស្តិ៍រដ្ឋបាល (Enseignement résidentiel ou Enseignement Primaire ) ការសិក្សាបំពេញវិជ្ជា នៅតាមអនុវិទ្យាល័យ ( Enseignement complémentaire) និងការ សិក្សាបច្ចេកទេស(Enseignement.technique) នៅសាលាវិជ្ជាជីវៈ ( Ecole Profestionnel ) ។ អាស្រ័យដោយមានការកំណែទម្រង់ រដ្ឋបាលក្នុងរជ្ជកាលព្រះ**ស៊ីសុវត្ថិ** ប៉ុស្តិ៍រដ្ឋបាលបារាំងបានបង្រួម

ខេត្តចំណុះទាំងឡាយឲ្យប្រែក្លាយជាខេត្តតែមួយ ដោយខេត្តពីបុរាណទាំងនោះបានប្រែក្លាយទៅជាស្រុក និងត្រូវបែងចែកជាឃុំដែលជារដ្ឋបាលថ្នាក់មូលដ្ឋាន។ បណ្ដាខេត្តនៅប៉ែកខាងកើត និងខាងលិចទន្លេមេគង្គ នៃប៉ុស្តិ៍រ៉េស៊ីដង់កំពង់ចាម ត្រូវបានប្រមូលផ្ដុំជាខេត្តកំពង់ចាមនៅឆ្នាំ១៩២០។ ការសិក្សាឋានលេខា និងប្លង់មេសម្រាប់ទីប្រជុំជនកំពង់ចាម បានត្រូវចាប់ផ្ដើមតាំងពីពេលនោះ មករហូតមកដល់ឆ្នាំ ១៩៣០ ។ និវេសនដ្ឋានទេសាភិបាលបារាំង (ផ្ទះខ្មៅ) ដែលជាទីតាំងសាលាខេត្តសព្វថ្ងៃ ត្រូវបានកសាងនៅឆ្នាំ ១៩២៣ជាមួយគ្នានឹងការកសាងការិយាល័យរដ្ឋបាលសាលាខេត្ត ដែលនៅខាងកើតឆៀងខាងត្បូង ដែលបច្ចុប្បន្ននេះគឺជាទីតាំងគណៈកម្មាធិការប្រតិបត្តិខេត្ត។ នៅកាច់ជ្រុងទន្លេអុំ ត្រង់តំបន់សឹករងខេត្តសព្វថ្ងៃ ជាទីចាត់ការរបស់ពេទ្យសត្វ ផ្ទៃដីសល់ពីនោះជាទីតាំងបន្ទាយទាហានជើងក្រហម ដែលស្ថិតក្រោមការត្រួតត្រារបស់បារាំង នៅលើដីកងរាជអាវុធហត្ថ និងទីបញ្ជាការយុទ្ធភូមិភាគសព្វថ្ងៃ ពីមុនគឺជាទីតាំងគុកធំ និងបន្ទាយទាហ៊ានជើងខ្មៅ របស់ខ្មែរដោយមានសាលាកុមារយោធិន (E.T.K) នៅប៉ែកខាង ក្រោយ។ នៅពីក្រោយសាលាខេត្ត គឺជាទីចាត់ការសាធារណៈការដែលមានមេការបារាំងឈ្មោះ **ប្រ៊ីតុង** មានប្រពន្ធជាជនជាតិខ្មែរដែលត្រូវជាប្អូន **សែបបូ** ដែលជាអ្នកទទួលការគ្រប់គ្រងកម្មករនៅខាងក្រោយទីចាត់ការនេះ គឺជាអាគារស្លឹកនៃសាលាបំពេញវិជ្ជាបឹងកុក ។ នៅត្រង់សួនមុខវិទ្យាល័យព្រះសីហនុសព្វថ្ងៃ ពីមុនជាទីតាំងផ្ទះនាយទាហ៊ានបារាំង រួចក្លាយជាសាលាសម្រាប់កូន បារាំង( Petit Lycée ) ដែលបង្រៀនដោយស្ត្រីជនជាតិបារាំងម្នាក់

ឈ្មោះ**ហ្សាកគ្លីន**។ នៅចន្លោះមន្ទីរអភិវឌ្ឍជនបទ និងមន្ទីរផែនការ សព្វថ្ងៃ ពីដើមចែកជាការិយាល័យកីឡា ទីចាត់ការកសិកម្ម ប៉ុស្តិ៍ តម្រួត និងសាលាស្រុកកំពង់សៀម រីឯនៅចំពីមុខជាតំបន់ព្រៃ កំបូតនៃវាលតាដោក ដែលនៅពេលក្រោយមក បារាំងបានសាង សង់ផ្ទះលំហែរមួយ ( Maison d'hôte ) ដែលប្រជាជនហៅថា "ផ្ទះស"។ ឆ្លងដល់ផ្លូវម្ខាងទៀតមានអាគាឃ្លាំងប្រាក់ ដែលនៅចុង សម័យអាណានិគមគ្រប់គ្រងដោយជនជាតិបារាំងឈ្មោះ**ប៊ែរណា ឡាបាត់** (Bernard Labatte) ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការ កសាងអាងហែលទឹក ទីលានវាយកូនបាល់ និងកន្លែងវាយសី និងយកទីតាំងនេះធ្វើជាកន្លែងចេញឆ្នោតវត្ថុក្នុងខេត្ត ។ សំណង់ អាគារនៅជ្រុងខាងមុខទាំងសងខាងរបស់សាលាខេត្ត គឺជាផ្ទះ មុខងាររបស់មន្ត្រីបារាំង និងភូឈ្មួយខេត្ត (អភិបាលរងខេត្ត) នៅ សម័យក្រោយអាណានិគមបារាំង ។ ទីចាត់ការភូមិបាល (Bureau cadstral ) តាំងនៅមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុសព្វថ្ងៃ និងទីចាត់ការ ប្រៃសណីយមានតាំងពីសម័យនោះមក ។ នៅតាមដងផ្លូវមុខសា លាខេត្តប៉ែកខាងស្តាំដៃ មានផ្ទះគ្រូពេទ្យបារាំងត្រង់មន្ទីសុខាភិ បាល និងស្នងការដ្ឋាននគរបាល នៅត្រង់តុលាការដំបូងខេត្ត រីឯ ប៉ែកខាងស្តាំដៃ មានផ្ទះអធិការអប់រំត្រង់សំណង់វិហារកាតូលិក ដែលកំពុងស្ថាបនាសព្វថ្ងៃ ទីចាត់ការអប់រំ សាលាកុមារី ( Ecole des jeumes filles ) ត្រង់សាលាទក្សិណ វិហារកាតូលិកនៅត្រង់ សណ្ឋាគារភ្នំប្រុស និងសាលាដំបូងនៅត្រង់សាខាធនាគារជាតិ ។ នៅក្នុងទីតាំងទីចាត់ការអប់រំ មានសាលាទក្សិណ( Groupe Sud ) និងសាលាឧត្តរ (Groupe Nord) ដែលមានទីតាំងដដែលរហូតមក

ទល់ពេលនេះ ។ តាមផ្លូវភ្លោះបច្ចុប្បន្ន ពីផែនាគមកផ្ទះឯកឧត្តម **ហ៊ុន ណេង** ពីដើមជាអូរដែលចាស់ៗហៅថា " អូររលោច" ដែលតភ្ជាប់ទៅនឹងវាលទំនាបបឹងស្នាយ ។ តំបន់នៅពីមុខសណ្ឋាគារ មេគង្គ គេហៅថា "ជ្រោយមាក់ភ្លឿ" ដែលមានទឹកហូរវិលខ្លាំង ជាតំបន់ដែលត្រូវមានការប្រុងប្រយ័ត្នចំពោះការធ្វើនាវាចរណ៍ ។ នៅតំបន់ដែលលាតសន្ធឹងពីអង្គភាពអគ្គីសនី ទៅផ្លូវជាតិលេខ៧ គេនាំគ្នាហៅថា "ស្វាយជ្រុំ" ដែលប្រមូលផ្តុំនូវលំនៅដ្ឋានរកេតរកូតរបស់អណិកជនវៀតណាមនិងខាងត្បូងផ្លូវគេហៅថាតំបន់ "ត្នោត ជ្រុំ" ។ នៅប៉ែកខាងជើងបឹងស្នាយ ចុះពីក្រោយសាលាជាតិកសិ កម្ម និងសាលាទួលថ្ម គឺជាទីស្មសានសម្រាប់កប់សពបារាំង ចិន ទាជីវ ចិនកន្តាំង និងវៀតណាម ដែលមានអុងកូវៀតណាមមួយនៅម្តុំភោជនីយដ្ឋានសម័យទំនើបសព្វថ្ងៃ ។ នៅមាត់បឹងស្នាយជាតំបន់ព្រៃរនាមដុះលាយឡំនឹងដើមត្រែងខ្ពស់ៗ ដោយកំណត់ជាតំបន់ត្រពាំងក្រាញ់ នៅចុងផ្លូវចុះពីសាលាទួលថ្ម ទៅតំបន់ត្រពាំង វាំង រួចបន្តទៅវាលវង់ប្រណាំងសេះត្រង់ផ្លូវជាតិលេខ៧ថ្មី ចុះទៅ កុមារកំព្រា និងកន្លែងហាត់បាញ់ស៊ីបនៅម្តុំអ្នកតាទួលសង្កែពេល បច្ចុប្បន្ន ។ សូមបញ្ជាក់ថា វាលវង់ប្រណាំងសេះនេះដំណើរការតែក្នុងរដូវប្រាំងតែប៉ុណ្ណោះ ដោយតំបន់នេះត្រូវលិចទឹកក្នុងរដូវ វស្សា រីឯនៅទន្លេអុំក្នុងសម័យនោះវិញ មានការប្រណាំងម្តងម្កាល ហើយទើបតែអភិវឌ្ឍនៅក្នុងសម័យក្រោយៗមកទៀត។ រីឯទីតាំងសាលាមធ្យមសុខាភិបាលបច្ចុប្បន្ន បន្តរហូតដល់ពន្ធនាគារចាស់ពីដើមជាសាលារុក្ខារក្ស ( សាលាមេព្រៃ ) ។

*ផ្សារកំពង់ចាម*ពីដើមស្ថិតនៅត្រង់មន្ទីរវប្បធម៌ខេត្ត គឺជាទីផ្សារមិនរៀបរយតាមដងទន្លេមេគង្គ ដោយទីតាំងសព្វថ្ងៃនៅតែជាបឹងកំផ្លោកនៅឡើយ ។ បារាំងពិតជាបានខំប្រឹងប្រែងរៀបចំទីប្រជុំជនកំពង់ចាមយ៉ាងខ្លាំងក្លាបំផុត តាមប្លង់មេដែលទើបតែបានរៀបចំរួច ដោយព្យាយាមចាក់ដីបំពេញបឹងកំផ្លោក ។ បារាំងបានស្ថាបនាផ្លូវរថភ្លើងមួយពីកំពង់សាឡាងចាស់ មកកាន់តំបន់នេះដើម្បីដឹកដីពីកោះរ៉ៃនៅមុខវត្តដីដុះ មកចាក់បំពេញបឹងលុះត្រាតែ ពេញដោយប្រើប្រាស់កម្លាំងអ្នកទោស។ ពេលក្បាលរថភ្លើងដុតអុសអូសទូរថដឹកដីចេញដំណើរ វាបញ្ចេញស៊ីរ៉ែនឮសូរឆ្វេក ទើបអ្នកស្រុកហៅឈ្មោះផ្លូវនេះថាផ្លូវអាឆ្វេក ដែលសព្វថ្ងៃនេះជាវិថី សុរាម្រឹត ។ នៅពីក្រោយវត្តដីដុះ មានព្រៃកមួយហៅថា "ព្រៃក គ្រលួច" ។ ពីដើមវត្តដីដុះបានកសាងឡើងនៅទីតាំងសាលាដីដុះ ចាស់ក្នុងព.ស ២៣៥៦ គ.ស ១៨១៣ ក្នុងរជ្ជកាលព្រះ **ហរិរក្ស រាមាអង្គដួង** លើផ្ទៃដី ១ ហិកតា ៩១ អារ។ ដោយភិក្ខុ សាមណេរ មានការលំបាកក្នុងការស្រង់ទឹកដោយត្រូវឆ្លងព្រៃក ចុះច្រាំង ចោត កាត់វាលខ្សាច់ទំរាំដល់ទន្លេធំ ទើបនៅឆ្នាំ១៩២១ ព្រះចៅ អធិការវត្ត ព្រះនាម**ប្រាក់** បានស្នើសុំទេសាភិបាលបារាំងរើទីតាំង មកតាំងនៅកន្លែងបច្ចុប្បន្ន ដោយបារាំងបានចេញនូវប្លង់ដីទទួល ស្គាល់នៅឆ្នាំ១៩៣៤ ដោយមានទំហំដីចំនួន ៣ហិកតា ៥៩ អារ ២០សង់ទីយ៉ា ដោយបញ្ជាក់នៅលើគំនូសប្លង់ខាងលិចទល់នឹងផ្លូវ ដើមស្វាយ ( Rue des manguiers ) ខាងត្បូងទល់នឹងផ្លូវលេខ ៣៥ គឺវិថីព្រះសីហនុសព្វថ្ងៃ។ ក្រោយពីព្រះគ្រូព្រះនាម**ប្រាក់** បានទទួលអនិច្ចធម្មទៅ ចៅអធិការវត្តជាបន្តបន្ទាប់មាន ព្រះគ្រូ **សោម** ព្រះគ្រូ

**មាឃ សំ** ( មានងារជាព្រះនាគមុនី ព្រះមេគណខេត្ត ) ព្រះគ្រូ **អោម អ៊ុម** ដែលមានអាចារ្យ**កាន់** និង**អ៊ុងប៉ាងខោល** ជាអ្នកទ្រទ្រង់ ព្រះគ្រូ**គួយ** និងព្រះគ្រូ **ហែម ជួង** នៅក្នុងសម័យ សាធារណរដ្ឋខ្មែរ ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មានព្រះ គ្រូ **ផេង សិទ្ធ** ដែលគង់ក្នុងរយៈពេលខ្លី រួចព្រះសមាធិធម្ម **ស៊ិន ស៊ឹម** ដែលជាព្រះឧបជ្ឈាយ៍ខេត្ត និងបច្ចុប្បន្ន ព្រះគ្រូ **មាស ភន** ។ ចំពោះជនជាតិចាម ពីដើមរស់នៅប្រមូលផ្តុំនៅម្តុំរោងចក្រទឹកកក **សុក ហេង** ដោយមានការចាំបាច់ក្នុងការរៀបចំទីប្រជុំជន និង ដើម្បីធ្វើឲ្យបរិស្ថានដងទន្លេមេគង្គបានល្អប្រសើរជាងមុន នៅក្នុង អំឡុងឆ្នាំ១៩៣៣- ១៩៣៥ បារាំងបានឲ្យអ្នកទាំងនេះរើទីតាំងមក រស់នៅតាមច្រាំងទន្លេ ក្នុងភូមិរកាលើ ក្នុងឃុំសំបួរមាស។ នៅក្នុង សម័យនោះ ជនជាតិចាម មានជម្លោះជាញឹកញាប់ជាមួយអ្នក ស្រុក លើការប្រើប្រាស់ដីជើងទេរ តែជម្លោះបានត្រូវបញ្ចប់ដោយ បារាំងបានដឹកជញ្ជូនដីនេះទៅចាក់បំពេញទីប្រជុំជន ។ ចំណែកឯ នៅតំបន់បឹងកុកវិញ គឺជាតំបន់ព្រៃរនាមដែលត្រូវទឹកលិចក្នុងរដូវ វស្សានិងមានតែផ្លូវថ្មើជើងតែមួយគត់នៅមាត់ទន្លេសម្រាប់ទំនាក់ទំនងរវា ងកំពង់ចាម និងឃុំរអាង នាររដូវប្រាំង ។

ដូចដែលបានរៀបរាប់មកហើយ មុខងារចៅហ្វាយខេត្តខ្មែរ បានត្រូវរៀបចំនៅឆ្នាំ១៩១៥ តែអ្នកទាំងនោះត្រូវស្ថិតនៅក្នុងការ គ្រប់គ្រងរបស់ទេសាភិបាលបារាំងប្រចាំប៉ុស្តិ៍កំពង់ចាម ។ នៅក្នុង រជ្ជកាលព្រះមុនីវង្ស ( ១៩២៧- ១៩៤១ ) មានរាជបញ្ញត្តិមួយ ស្តីពីការរៀបចំគោរម្យងាររបស់ចៅហ្វាយខេត្ត ចៅហ្វាយស្រុក និងមន្ត្រីជំនួយការមួយចំនួននៅក្នុងរាជាណាចក្រកម្ពុជា ដែលក្នុង

សម័យកាលនោះមានត្រឹមតែ ១៤ ខេត្តប៉ុណ្ណោះ គឺ ខេត្តកណ្តាល កំពង់ចាម បាត់ដំបង កំពត ព្រៃវែង កំពង់ឆ្នាំង តាកែវ ស្វាយរៀង កំពង់ធំ សៀមរាប ក្រចេះ កំពង់ស្ពឺ ពោធិ៍សាត់ និង ស្ទឹងត្រែង ។

## **សម្រាប់ខេត្តកំពង់ចាម**

ចៅហ្វាយខេត្ត ឧកញ៉ាមន្ត្រីភក្តីពិជ័យរដ្ឋាមហាបញ្ញាកៈ
ឧត្តមក្រុមពាហុ

ភូឈួយខេត្តទី១ ឫទ្ធីរង្គភក្តី
ភូឈួយខេត្តទី២ ភក្តីរាជឫទ្ធិ
បាឡាត់ខេត្ត រាជាភក្តី

## **សម្រាប់តាមបណ្តាស្រុកក្នុងខេត្ត**

១-ស្រុកកំពង់សៀម គោរម្យងារចៅហ្វាយស្រុក ពិជ័យរដ្ឋា, បាឡាត់ស្រុក ភក្តីមន្ត្រី

២-ស្រុក ព្រៃឈរ គោរម្យងារចៅហ្វាយស្រុក វល្លីវន័ភក្តី

៣-តំបន់ ចំការលើ គោរម្យងារចៅតំបន់ ពិភ័ក្តិអារញ្ញិក

៤-ស្រុក ជើងព្រៃ គោរម្យងារចៅហ្វាយស្រុក ពេជ្រតេជោ , បាឡាត់ស្រុក សេនាតេជោ

៥-ស្រុក កោះសូទិន គោរម្យងារចៅហ្វាយស្រុក ធបិនមន្ត្រី , បាឡាត់ស្រុក សុទិនមន្ត្រី

៦-ស្រុក ត្បូងឃ្មុំ គោរម្យងារចៅហ្វាយស្រុក អរជូន , បាឡាត់ស្រុក, ពិភ័ក្តិអរជូន

៧-តំបន់ ទួលត្រាច គោរម្យងារចៅតំបន់ រដ្ឋវន័ពិភ័ក្តិ

៨-ស្រុក ក្រូចឆ្មា គោរម្យងារចៅហ្វាយស្រុក ភក្តីអរជូន

៩-ស្រុក មេមត់ គោរម្យងារចៅហ្វាយស្រុក អារញ្ញឹកអរជូន
១០-ស្រុក ស្ទឹងត្រង់ គោរម្យងារចៅហ្វាយស្រុក រាជាតេជោ
១១-ស្រុក ស្រីសន្ធរ គោរម្យងារចៅហ្វាយស្រុក បវរសង្គ្រាម
១២- ស្រុក កងមាស គោរម្យងារចៅហ្វាយស្រុក ពិភ័ក្តិមន្ត្រី

ក្នុងសម័យអាណានិគមបារាំង បានត្រួសត្រាយស្ថាបនាផ្លូវតភ្ជាប់ទំនាក់ទំនងតាមបណ្ដាស្រុក និងបានពន្លឿនការកសាងហេដ្ឋារចនាសម្ព័ន្ធនៅទីប្រជុំជនកំពង់ចាម។ លោក **ម៉ង់តូ** ជាទេសាភិបាលបារាំងមួយរូប ដែលបានកសាងប៉មនៅទន្លេបិទក្នុងឆ្នាំ ១៩៣០ និងកសាងផ្សារធំកំពង់ចាមបានរួចរាល់ក្នុងឆ្នាំ ១៩៣៧ ។ ជាបន្តបន្ទាប់ផ្ទះ ល្វែងនានានៅតាមរចនាបទបារាំងនៅជុំវិញផ្សារធំកំពង់ចាម ត្រូវបានកសាងជាមួយនឹងបណ្ដាញផ្លូវ និងលូបង្ហូរ ទឹក ដែលញ៉ាំងឲ្យទីនេះក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយនៅ តាមដងទន្លេមេគង្គ ដែលមានកំពង់ផែមួយនៅមុខសណ្ឋាគារ មេគង្គ និងកំពង់សាឡាងមួយដែលគ្រប់គ្រងដោយបារាំងនៅប៉ែក ឥសានវត្តដីដុះ ។ ម៉ាស៊ីនកិនស្រូវមួយត្រង់ឃ្លាំងកសិកម្មនៅជាប់ សួនវេស្សន្តរ បានចាប់ដំណើរការតាំងពីឆ្នាំ១៩៣៨មក ។ ឱសថ ស្ថាន និងគ្លីនិកព្យាបាលឯកជនដំបូងគេគ្រប់គ្រងដោយជនជាតិ វៀតណាមឈ្មោះ **ង្វៀង យ៉ាងដេ** នៅផ្ទះល្វែងខាងលិចផ្សារធំ។ ស្ថានីយ៍ទឹកស្អាតនៅជិតផ្សារបឹងកុក បានចាប់ផ្ដើមកសាងនៅឆ្នាំ ១៩៣៨ ហើយបានចប់សព្វគ្រប់ដាក់ឲ្យដំណើរការផ្គត់ផ្គង់ទឹកក្នុង ទីប្រជុំជននៅឆ្នាំ ១៩៤២ ជាមួយនិងស្ថានីយ៍មួយទៀតនៅក្រោយ មន្ទីរពេទ្យខេត្ត ដែលកាលពីដើមសម្រាប់តែផ្គត់ផ្គង់តែអាងហែល ទឹកនៅមុខសាលាខេត្តតែប៉ុណ្ណោះ។អនុវិទ្យាល័យព្រះសីហនុបាន

ត្រូវស្លាបនារួចរាល់នៅក្នុងឆ្នាំ១៩៤២ ដែលគ្រប់គ្រងដោយបារាំង មានជាបន្តបន្ទាប់ លោក **ឡាហ្វុង** លោក **ល្វីឡាកុត** ក្រោយមក ទើបគ្រប់គ្រងដោយខ្មែរ មាន លោក **អ៊ុំ ឈាងស៊ុន សារអូន**, លោក **ក្វាន់ ស៊ីផាន់** , លោក **មាស ឌឹម**...។ មេដឹកនាំពួកខ្មែរ ក្រហម មាន **ខៀវ សំផន** , **សាឡុត ស** ( **ប៉ុល ពត** ), **ហ៊ូ នឹម** , **ហ៊ូ យន់** គឺជាសិស្សជំនាន់ទី១ នៃអនុវិទ្យាល័យនេះ មុននឹងទៅបន្ត ការសិក្សានៅទីក្រុងភ្នំពេញ ។ ក្នុងសម័យអាណាព្យាបាលបារាំង អាស្រ័យដោយមានការអភិវឌ្ឍដំណាំកៅស៊ូ លើតំបន់ដីក្រហមដ៏ មានជីជាតិ ជនជាតិវៀតណាមជាច្រើនបានត្រូវបារាំងជួលមកធ្វើ ជាកម្មករ ជាអ្នកបច្ចេកទេស និងខ្លះទៀតបានមកតាំងទីលំនៅ ប្រកបមុខរបររកស៊ីនៅក្នុងទីប្រជុំជន រហូតដល់កើតមាននៅទីស្នួ សាន និងអុងកូ ដែលបានរៀបរាប់ពីទីតាំងរួចមកហើយ ពុំនោះ សោតមានរោងកែលឿងមួយ (រោងល្ខោនវៀតណាម) ស្ថិតនៅមុំ សណ្ឋាគារមនោរម្យបច្ចុប្បន្ន។ ដោយឡែក យើងមានរោងល្ខោន បាសាក់២ នៅមុំគ្លីនិកសម្ភពអ៊ុកវ៉ារង់សព្វថ្ងៃ មួយជាសាខាថៅកែ **បាក់ ស្រេង** និងអ្នកស្រី **អ៊ុន វ៉ាង** មួយទៀតជាសាខាលោក **សាំង សារុន** ដែលរោងចុងក្រោយនេះ ប្រែក្លាយជារោងភាពយន្តកម្ពុជា ក្នុងសម័យសង្គមរាស្ត្រនិយម ។ ការិយាល័យសន្តិសុខ (Bureau de sûreté) ដែលជំនាន់នោះហៅ**ប៊ុយរ៉ូគិញ** នៅចំពីមុខស្នាក់ការ បក្សសង្កាត់បឹងកុក និងស្ថិតនៅក្បែរគ្នានោះដែរ មានការិយាល័យ គយ ។ វត្តជោតនារាម **បឹងកុក** បានកសាងឡើងនៅឆ្នាំ ១៩៥១ រហូតដល់ឆ្នាំ១៩៥៦ អាគារសាលាបាលីមួយខ្នងត្រូវបានកសាង រួចជាស្ថាពរ ដោយលោកឧកញ៉ាវិសេសសម្បត្តិ **ហេង គុជ** លោកថៅកែ

**ដោក ឧច** និងពុទ្ធបរិសទ័ចំណុះជើងវត្ត ក្រោមការផ្តួចផ្តើមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញាណោ** ។

ក្រោយពេលដែលប្រទេសកម្ពុជា បានទទួលឯករាជ្យពេញបរិបូរណ៍នៅថ្ងៃទី ៩ ខែ វិច្ឆិកា ១៩៥៣ បារាំងនៅបន្សល់ទុកអ្នកបច្ចេកទេសខ្លះដើម្បីបន្តនិរន្តរភាពកិច្ចការចាំបាច់មួយចំនួនដូចជា ធនាគារិក **ប៉ែរណា ឡាបាត់** ជាដើម ។ ធនារិកដ៏មានឥទ្ធិពលនេះបានរត់គេចខ្លួនដែលធ្វើឲ្យបាត់ប្រាក់ចំនួន៨០លានរៀល ប្រហាក់ប្រហែលនឹង២លានដុល្លា ដែលធ្វើឲ្យមានការដកហូតមុខដំណែង លោក **ឱប គឹមអាង** ពីអភិបាលខេត្ត និងការរំលាយរដ្ឋាភិបាល របស់លោក **ផូ ព្រឿង** នៅឆ្នាំ ១៩៦១ ។ រដ្ឋបាលខេត្តនៅក្នុងសម័យសង្គមរាស្ត្រនិយមបានរំលេចនូវស្នាដៃជាច្រើន ជាពិសេសចាប់ពីដើមទសវត្ស ៦០មក តាមរយៈការបើកដំណើរការរោងចក្រ តម្បាញ សាកលវិទ្យាល័យកំពង់ចាម កីឡាដ្ឋាន អាគារសិក្សា គ្រប់ភូមិសិក្សា អាគារពិពរ័ណ៍អចិន្ត្រៃយ៍ ផ្លូវ ស្ពាន បណ្តាញ អគ្គីសនី សួនឧទ្យាន...។ល។ ផ្សារធំកំពង់ចាម ត្រូវកែរលំអរដោយរៀបចំជាចំណតរថយន្តនៅពីមុខ អាគារសាធារណៈមួយចំនួនត្រូវបានកសាងឡើង ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃយុគ សម័យ លំនៅដ្ឋានឯកជននានាត្រូវបានលេចជារូបរាងដ៏ស្រស់ ឆើតឆាយជំនួសឲ្យខ្ទមរខេករខាកពីសម័យមុន។ អ្នកមានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភមួយចំនួន បានទទួលគោរម្យងារពីព្រះបរមរាជវាំងជាឧកញ៉ា ក្នុងនោះមាន លោក **អ៊ឹង ខោល** ( អុងប៉ាងខោល ) លោក **ហេង គុជ** លោក **ប៉ុលអាន** លោក **ទាបាក់ ងួនជរ**...។ មធ្យោបាយដឹកជញ្ជូនអ្នកដំណើរជើងគោករវាងកំពង់ចាម និង ភ្នំពេញ

ត្រូវបានប្រមូលម្ដុំភាគច្រើនដោយលោក **ងួន ហាក់** ដែលផ្ទះគាត់ជាអតីតមន្ទីរព័ត៌មាន និងលោក **ប៉ុល អាន** ដែលមានផ្ទះនៅក្រោយវត្តដីដុះ ទន្ទឹមនឹងនោះ សកម្មភាពដឹកជញ្ជូនជើងទឹកក៏មានតួនាទីយ៉ាងសំខាន់បំផុតសម្រាប់អ្នកដំណើរ និងទំនិញកសិ ផល និងឧស្សាហផលគ្រប់ប្រភេទ ។ ស្របនឹងការរីកចម្រើនខាង ដំណាំកៅស៊ូ សន្លឹកថ្នាំជក់ប្រកបដោយគុណភាពខ្ពស់ ក៏ជាសក្ដានុពលសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ខេត្តកំពង់ចាមផងដែរ ។ កម្មន្តសាលថ្នាំជក់កម្ពុជា ( M.K.T ) បានសង់ឃ្លាំងស្ដុកសន្លឹកថ្នាំ ៣ កន្លែងនៅកំពង់ចាម មួយនៅត្រង់ផ្សារចុងថ្នល់សព្វថ្ងៃ មួយនៅត្រង់គល់ស្ពានសព្វថ្ងៃ និង មួយទៀត នៅក្រោយវត្តដីដុះ ។ គួររំលេចផងដែរនូវតួនាទីសាលាកុមារយោធិន្ទខ្មែរ ( E.T.K ) ដែលត្រូវបណ្ដុះបណ្ដាលចំណេះទូទៅផងនិងហ្វឹកហាត់វិជ្ជាយុទ្ធសាស្ត្រ ផងដល់កុមារមួយចំនួន ក្នុងនោះមានទាំងព្រះអង្គម្ចាស់ **នរោត្តម យុវនាថ** បុត្រារបស់សម្ដេចព្រះ**នរោត្តម សីហនុ** ផងដែរ ។ លោក **កុយ មឿន** គឺជាគ្រូបង្រៀនដ៏ម៉ត់ចត់ និងស្វាហាប់ម្នាក់នៅសាលា នេះមានកិត្តិយសទទួលបាននូវគ្រឿងឥស្សរយសអំពីព្រះមហាក្សត្រីយានីព្រះ**កុសមៈនារីរត្ន សិរីវឌ្ឍនា** ។ ព្រះអង្គម្ចាស់ **យុវនាថ** បានរៀបអភិសេកជាមួយនាង **ទា គឹមយីង** ដែលជាកូនស្រីលោក **ទា ឡៃហួ** ដែលជាម្ចាស់បណ្ណាគារមួយនៅកំពង់ចាម ក្នុងអំឡុង ឆ្នាំ ១៩៦៤ ។ *កំពង់ចាម* គឺជាប្រភពនៃការផ្ដត់ផ្ដង់កីឡាករឆ្នើមៗសម្រាប់ប្រទេសកម្ពុជាផងដែរ ក្នុងនោះមាន ៖ កីឡាហែលទឹក កីឡាបាល់ទាត់ កីឡាបាល់ទះ ជាដើម ។ ក្នុងសម័យសង្គមរាស្ត្រ និយម **កំពង់ចាម** មានរោងភាពយន្ត ៣កន្លែង គឺ រោងភាពយន្ត **អេដែន**

របស់លោក **ហេង គុជ** នៅត្រង់សណ្ឋាគារមិត្តភាព រោងភាពយន្ត**លំហែរាត្រី** របស់លោក**អ៊ឹង ថៃម៉ូវ** នៅត្រង់ធនាគារ **ម៉ាយ បេង** និងរោងភាពយន្តកម្ពុជា ជាអតីតរោងល្ខោន **សាំង សារុន** ចាស់ នៅក្បែរក្លីនិកអ៊ុកវ៉ារ៉ង់ ដោយឡែករោងមហោស្រព ព្រះ**សីហមុនី** ត្រូវបានប្រារព្ធពីធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវ ការនៅថ្ងៃទី ២០ កក្កដា ១៩៦៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ ខ្ពស់នៃអង្គសម្តេចឪ ។ សូមរំលឹកឡើងវិញថា ទាំងក្នុងសម័យអា ណាព្យាបាល ទាំងក្នុងសម័យសង្គមរាស្ត្រនិយម ក៏ដូចជាសម័យ របបសាធារណរដ្ឋខ្មែរ *កំពង់ចាម* គឺជាឃុំមួយរបស់ស្រុកកំពង់ សៀម ដែលមានមេឃុំឈ្មោះ **សូ អ៊ិន** មានសក្តិ ៧ហ៊ូពាន់ និងបន្ត មក មានលោក **ឌី នុត** ដែលមានស្មៀន **សេង** ជាជំនួយការ ។

*ទីក្រុងកំពង់ចាម* នៃខេត្ត ដែលប្រកបដោយសក្តានុពល ទាំងធនធានមនុស្ស និងធនធានសេដ្ឋកិច្ចនេះ បានងើបចេញពី របបអាណានិគមនិយមបារាំង ប្រែក្លាយជាមជ្ឈមណ្ឌលដ៏សំខាន់ របស់ប្រទេស នៅក្នុងសម័យសង្គមរាស្ត្រនិយមបានតែ ១៧ ឆ្នាំ ប៉ុណ្ណោះ ទីក្រុងនេះក៏ដូចជាទីក្រុងដ៏ទៃទៀតដែរ ក៏ត្រូវរងនូវការ បំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិល និងដោយរបបប្រល័យពូជ សាសន៍ស្ទើរតែវិនាសសាបសូន្យ ។ ចាប់តាំងពីរដ្ឋប្រហាររបស់ **លន់ នល់** ទម្លាក់សម្តេចព្រះប្រមុខរដ្ឋ នាថ្ងៃ១៨ មិនា ១៩៧០មក សង្គ្រាមបានផ្ទុះឡើង ការអភិវឌ្ឍត្រូវបានបញ្ចប់ ។ សមិទ្ធិផល ដែលបានសម្រេចឡើងក្នុងក្រុង ត្រូវទ្រាំឈររងនិងដួលរលំជាបន្ត បន្ទាប់ដោយគ្រាប់បែកដែលទម្លាក់ពីយន្តហោះគ្រប់ធុន ពីគ្រាប់ កាំភ្លើងធំតូចគ្រប់ប្រភេទ ដែលមហាអំណាចផុតលេខលើសកល លោក

បំពាក់ឲ្យភាគីខ្មែរទាំងសងខាងបំផ្លិចបំផ្លាញគ្នាទៅវិញទៅមកយ៉ាងក្តៅគគុក ។ ជាងនេះទៅទៀត ក្នុងរបបប្រល័យពូជសាសន៍ ទីក្រុងនេះ ត្រូវទទួលរងនូវការបំផ្លិចបំផ្លាញបន្ថែមជាមួយគ្នានឹងការកាប់សម្លាប់យ៉ាងរង្គាល លើប្រជាជនស្លូតត្រង់ជាច្រើននាក់ ធ្វើឲ្យទីក្រុងក្លាយជាទីស្មសានគួរឲ្យព្រឺខ្លាច ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ប្រជាជាតិ និងប្រជាជនកម្ពុជាយើង ពុំត្រឹមតែពុំបានទទួលនូវការអាណិតអាសូរអំពីសំណាក់សហគមន៍អន្តរជាតិប៉ុណ្ណោះទេ គឺថែមទាំងទទួលនូវទណ្ឌកម្មហ៊ុំព័ទ្ធសេដ្ឋកិច្ច និងព្រមទាំងផ្តល់ការគាំទ្រដល់អនុភាពប្រល័យពូជសាសន៍ឲ្យវិលត្រឡប់មកកាន់អំណាចវិញនៅកម្ពុជា ។ យើងពិតជាបានឆ្លងកាត់នូវវិញ្ញាសារដ៏លំបាកបំផុត ខ្វះសព្វខ្វះគ្រប់ តែយើងនៅតែខំប្រឹងប្រវា ដើម្បីរស់ដោយអនុវត្តនូវគោលនយោបាយ ១១ (ខ) របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានដឹកនាំយើងពីបាតដៃ ទទេ ដែលពោរពេញស្នាមរបួស ដោយបានកសាងនូវទឹកដីជាទីស្រឡាញ់របស់យើង ចេញពីគំនរផេះផង់ឲ្យមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ជាមួយគ្នានឹងការប្រមូលផ្តុំកងកម្លាំងការពារទប់ស្កាត់ប្រកបដោយប្រសិទ្ធិភាព នូវរាល់អានុភាពប្រតិកិរិយាដែលប៉ុនប៉ងវិលត្រឡប់មកកាន់អំណាចវិញ។ ជាការពិតណាស់ បើគ្មានគោលនយោបាយឈ្នះ ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** ទេ គឺយើងពិតជាពុំមានឱកាសអភិវឌ្ឍប្រទេសជាតិ និយាយរួម និងទីក្រុងកំពង់ចាមយើង និយាយដោយឡែកឲ្យមានការរីកចម្រើនដូចសព្វថ្ងៃនេះទេ។ សន្តិភាពនិងស្ថេរភាពនយោបាយ គឺជាមូលដ្ឋានគ្រឹះនៃកិច្ចធានានូវការអភិវឌ្ឍ សំដៅផ្តល់នូវវិបុលភាពជូនប្រជាជន

គ្រប់រូបឲ្យរស់នៅក្នុងបរិយាកាសសុខដុមរមនា ដោយព្យាយាម លប់បំបាត់ចោលឲ្យអស់ នូវរាល់ស្នាកស្នាមនៃការបែកបាក់ប្រេះ ឆា និងអពមង្គលដ៏អាម៉ាស់ទាំងឡាយនៃអតីតកាល ។ ពីមុនពួក មហាអំណាច គេបានប្រគល់គ្រាប់បែក គ្រាប់រំសេវគ្រប់ធុនមកឲ្យ យើងបំផ្លាញទឹកដី និងអាយុជីវិតគ្នាអស់រាប់លាននាក់ ឥឡូវពួក គេកំពុងតែប្រើប្រាស់នូវពាក្យប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស យ៉ាងទូលំទូលាយគ្មានព្រំដែន ដែលប្រទេសរបស់ខ្លួនពុំទាន់បាន អនុវត្តបានពេញលេញនៅឡើយទេ មកបំពុលបរិយាកាសនយោ បាយនៅកម្ពុជា ។ យើងត្រូវតែខិតខំនាំគ្នាឈោងចាប់ឲ្យបាននូវ ឱកាសមាសសម្រាប់អភិវឌ្ឍប្រជាជាតិយើង នៅក្នុងកាលៈទេសៈ ដែលប្រទេសជាច្រើន កំពុងទទួលរងនូវអពមង្គលដោយសង្គ្រាម និងការបែកបាក់ ។ ព្រលឹងអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ ក្នុងសង្គ្រាម ក៏ដូចជាក្នុងរបបប្រល័យពូជសាសន៍ ដែលជាបុព្វការី ជនរបស់យើង ជាសាច់ឈាមរបស់យើង ដែលឆ្អឹងពួកគាត់បាន គរច្របូកច្របល់លើគ្នាក្នុងរណ្តៅពិឃាត និងរាត់រាយនៅលើសមរ ភូមិ កំពុងនាំគ្នាឈរបើកភ្នែកសម្លឹងមកលើរូបយើងគ្រប់ៗគ្នាដែល មានភ័ព្វសំណាងខ្ពស់ បានរស់រានមានជីវិតយ៉ាងប្រផឹតប្រផើយពី សង្គ្រាម និងវាលពិឃាត បាននិងកំពុងធ្វើអ្វីខ្លះសម្រាប់អត្ថិភាព និងកិត្យានុភាពរបស់ប្រទេសជាតិមាតុភូមិដ៏កំសត់របស់យើងនេះ ពីព្រោះថា កត្តិយសរបស់មនុស្សត្រង់មនុស្សចេះបង្កើតនូវស្នាដៃ កិត្តិយសរបស់ដីត្រង់ដីចេះបង្កើតនូវផ្លែផ្កា ។

# ស្ថានភាពរបស់ក្រុងកំពង់ចាម

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ *កំពង់ចាម* បានប្រែក្លាយជាទីរួមខេត្ត ដែលបានគ្រប់គ្រងដោយគណៈកម្មាធិការប្រជាជន បដិវត្តន៍ទីរួមខេត្តកំពង់ចាម ដោយផ្តាច់ចេញពីស្រុកកំពង់សៀម ។ កាលណោះទីរួមខេត្តកំពង់ចាម មានតែមួយឃុំប៉ុណ្ណោះគឺ ឃុំ កំពង់ចាម ចែកជា ៩ ភូមិ លាតសន្ធឹងពីត្បូងទៅជើង ចាប់ពីរង្វង់ មូលនាងគង្ហីង ទៅដល់រង្វង់មូលជ័យវ៉ារ្ម័នទី៧សព្វថ្ងៃ និងពីទន្លេមេគង្គទៅដល់បន្ទាយតំបន់សឹករងខេត្ត ។ នៅឆ្នាំ ១៩៨៨ ទឹកដីមួយចំនួននៃស្រុកកំពង់សៀម ត្រូវបានកាត់ចូលក្នុងការគ្រប់គ្រងរបស់ទីរួមខេត្ត មានឃុំសំបួរមាស ភូមិចុងថ្នល់ និងភូមិឡឥដ្ឋ នៃ ឃុំរអាង ដោយបង្កើតបានជា ៤ឃុំ គឺ កំពង់ចាម វាលវង់ សំបួរ មាស និងបឹងកុក រួចក្លាយជាស្រុកកំពង់ចាមក្នុងឆ្នាំ ១៩៩៣ ។

នៅថ្ងៃទី ៦ ខែ កុម្ភៈ ២០០៩ ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត/ក្រុង/ស្រុក/ខណ្ឌ ស្រុកកំពង់ ចាម ត្រូវបានប្រកាសជាផ្លូវការ ជាក្រុងកំពង់ចាម ។

ក្រុងកំពង់ចាម មានចម្ងាយ ១២៤ គីឡូម៉ែត្រប៉ែកឥសានរាជធានីភ្នំពេញ ជាចំណុចប្រសព្វរវាងផ្លូវជាតិលេខ ៧ និងទន្លេ មេគង្គ ។ ក្រុងនេះ មានផ្ទៃក្រឡា ២២,១៥គម² មានព្រំប្រទល់ខាងកើតទល់នឹងស្រុកត្បូងឃ្មុំ ដែលខណ្ឌចែកដោយទន្លេមេគង្គ ខាងលិចទល់នឹងឃុំអំពិល ស្រុកកំពង់សៀម ខាងត្បូងទល់នឹងឃុំកោះរកា ស្រុកកំពង់សៀម និងខាងជើងទល់នឹងឃុំរអាង ស្រុកកំពង់សៀម ។ ក្រុងកំពង់ចាម ចែកចេញជា ៤ សង្កាត់ មាន ៣២

ភូមិ មានប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ ៨.៦៥៦ គ្រួសារ មនុស្សរួម ៤៥.៥២១ នាក់ ក្នុងនោះស្រី ២៣.៣២១ នាក់ ដែល មាន ៖

-ជនជាតិខ្មែរ ៨.១៥២ គ្រួសារ មនុស្សរួម ៤២.២៩១ នាក់ ក្នុង នោះ ស្រី ២១.៦៧៣ នាក់

-ជនជាតិចាម ៤១៥ គ្រួសារ មនុស្សរួម ២.៧៩៨ នាក់ ក្នុង នោះ ស្រី ១.៤៤៥ នាក់ ដែលប្រមូលផ្តុំការរស់នៅក្នុងភូមិរកាលើ និង រកាក្រោម នៃសង្កាត់សំបួរមាស។

-ជនជាតិវៀតណាម ៨៧ គ្រួសារ មនុស្សរួម ៤២៩ នាក់ ក្នុងនោះស្រី ២០២ នាក់ ភាគច្រើនរស់នៅក្នុងសង្កាត់បឹងកុក។

- ជនជាតិចិន ២គ្រួសារ មនុស្សរួមចំនួន ៣នាក់ ក្នុងនោះស្រី ២ នាក់ ។

ប្រជាពលរដ្ឋក្រុងកំពង់ចាមមានមុខរបរ ៣៨,៧០% ជាសេ វាករ , ២៩,៧៥% ជាមន្ត្រីរាជការ, ១២,៩៦% ជាបុគ្គលិកកម្មករ ក្នុងវិស័យឯកជន, ១២,៦៨% ជាកសិករនៅតំបន់ជាយក្រុង, និង ៤,១១%ប្រកបការងារនៅតំបន់ក្រៅក្រុង និង១,៨០% មានមុខរបរ មិនច្បាស់លាស់។ ដង់ស៊ីតេប្រជាពលរដ្ឋមានចំនួន ២.០៥៥នាក់/ ១គ.ម$^{២}$ ។ ផ្អែកតាមស្ថានភាពជាក់ស្តែងនៃភូមិសាស្ត្រ និងសង្គម សាស្ត្រ ក្រុងកំពង់ចាមមានចក្ខុវិស័យអភិវឌ្ឍន៍៤គឺ ៖ ១- ជាទីក្រុង ពាណិជ្ជកម្ម ទេសចរណ៍និងរដ្ឋបាល , ២- ជាទីក្រុងមាត់ទឹក ដែល មានទន្លេមេគង្គជារមណីយដ្ឋានធម្មជាតិ និងជាផ្លូវទឹកដ៏សំខាន់ , ៣- ជាទីក្រុងមានបរិស្ថានរស់នៅល្អ និង ៤-ជាទីក្រុងមានតុល្យ ភាពរវាងការអភិវឌ្ឍន៍ និងការអភិរក្ស និងសមារណកម្មក្នុង តំបន់។

នៅដើមត្រីមាសទី១ ឆ្នាំ ២០១១ តាមរយៈសម្ព័ន្ធភាពជាតិឃុំ/សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ក្រុងកំពង់ចាមបានធ្វើកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ជាមួយនិងទីក្រុងឈីលីវ៉ាក់ ( CHILLIWACK ) ខេត្តប្រ៊ីធីសខូឡុំបៀរ ( British Columbia ) នៃប្រទេសកាណាដា ដោយផ្តោតលើការអភិវឌ្ឍលើវិស័យទេសចរណ៍ និងទទួលបាននូវជ័យលាភីរំដួល ២ទងក្នុងយុទ្ធនាការប្រឡងប្រណាំងទីក្រុងស្អាតនាឆ្នាំ ២០១៥ ។



***កំពង់ចាម*** គឺជាទីក្រុងដែលមានស្ពានឆ្លងកាត់ទន្លេមេគង្គដំបូងគេបំផុត គឺស្ពានគីហ្ស៊ុយណា ( KIZUNA) ដែលជាជំនួយដ៏សប្បុរសរបស់ប្រទេសជប៉ុន ។ ស្ពានប្រវែង ១.៣៦០ ម៉ែត្រ និងកំណាត់ផ្លូវជាតិលេខ ៧ ថ្មី ប្រវែង ២.៥០០ ម៉ែត្រនេះ បានចាប់ផ្តើមកសាងក្នុងខែតុលា ឆ្នាំ ១៩៩៧ ក្នុងអាណត្តិ ឯ.ឧ **ហ៊ុន ណេង** ជាអភិបាលខេត្ត ដែលចំណាយថវិកាជំនួយប្រទេសជប៉ុនចំនួន ៧៩.៦៨០.០០០ដុល្លា និងថវិកាបដិភាគរបស់រដ្ឋាភិបាលចំនួន ៤.០៥៧.៦៦៩.៤១២ រៀល ប្រហាក់ប្រហែលនឹង ១.៤៧៥.៥១៦ ដុល្លា សម្រាប់ទូទាត់ជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់លើ ការស្ថាបនាផ្លូវ

១៣៦ គ្រួសារ មាន ១៤៣ ក្បាលដី និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់លើការស្ថាបនាស្ពាន ៤២ គ្រួសារ មាន ៤៦ក្បាលដី ។ សមិទ្ធិផលដ៏មហាសាលនេះ បានត្រូវសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នោះគឺជាកាលានុវត្តភាពនៃការផ្លាស់ប្តូរមុខមាត់ទីក្រុងកំពង់ចាម នៅក្នុងសហសវត្សថ្មី ។

# ព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១៣



*( ក្បួនដង្ហែរស្តេច **មាឃ** ក្នុងព្រះរាជពិធីច្រត់ព្រះន័ង្គល ក្នុងខេត្តកំពង់ចាម )*

ឆ្នាំ២០១៣ គឺជាកាលប្បវត្តិដ៏សំខាន់ក្នុងព្រះរាជាណាចក្រ កម្ពុជា ដែលព្រឹត្តិការណ៍សំខាន់ៗ មាន ៖ ព្រះរាជពិធីបូជាព្រះបរមសពព្រះបរមរតនកោដ្ឋនៅដើមខែកុម្ភៈ និងការបោះឆ្នោតជាសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៅថ្ងៃទី២៨ សីហា។ ដោយឡែក សម្រាប់ខេត្តកំពង់ចាម មានព្រឹត្តិការណ៍ធំៗ ៣ គឺ ការចូលនិវត្តន៍របស់ឯ.ឧ **ហ៊ុនណេង** និងការចូលកាន់មុខដំណែងជាអភិបាលខេត្តរបស់ឯ.ឧ **លន់ លឹមថៃ** នៅថ្ងៃទី ១៣ ឧសភា ព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅថ្ងៃទី ២៨ ឧសភា និងដំណឹងនៃការបំបែកខេត្តកំពងចាមជាពីរ ។ ពីមុនមកព្រះរាជពិធីច្រត់ព្រះន័ង្គល ដែលជាព្រះរាជពិធីទ្វាទសមាសនៃព្រះរាជាណាចក្រកម្ពុជា ស្ទើរតែជាទូទៅតែងប្រារព្ធនៅវាលព្រះមេរុក្នុងរាជធានីភ្នំពេញ ។ ចាប់

ពីឆ្នាំ២០១៣ ទៅ ដោយមានការយល់ព្រមពីព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានតម្រូវឲ្យមានការរៀបចំពិធីនេះនៅតាមបណ្ដាខេត្ត ក្នុងនោះសម្រេចជ្រើសរើសយកខេត្តកំពង់ចាម ដែលមានប្រជាពលរដ្ឋច្រើន និងមានសក្ដានុពលខាងដំណាំកសិកម្ម និងដំណាំកសិឧស្សាហកម្ម ជាខេត្តដំបូងគេបំផុតក្នុងការប្រារព្ធពិធីនេះ ។ ទីលានបាល់ទាត់ ជាទីតាំងដែលសក្តិសមបំផុតក្នុងការរៀបចំជាទីព្រះស្រែ ទោះបីទីតាំងនេះ មួយចំណែកត្រូវបាននឹងកំពុងរៀបចំជាមជ្ឈមណ្ឌលកីឡាហែលទឹកដែលមានគំនរថ្មធំៗគរ និងខ្ពស់ប្រៀបបាននឹងកូនភ្នំក៏ដោយ ។ អាស្រ័យដោយមានការចង្អុរណែនាំពីគណៈកម្មាធិការរៀបចំពិធីបុណ្យជាតិ និងអន្តរជាតិ ជាពិសេសពីក្រសួងព្រះបរមរាជវាំងដែលដឹកនាំដោយសម្ដេចជហ្វាវាំង **គង់ សំអុល** ព្រមទាំងមានការត្រួតពិនិត្យជាប់ជាប្រចាំរបស់ឯកឧត្តមអភិបាលខេត្ត អភិបាលរងខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ និងសិស្សានុសិស្សនៅគ្រប់គ្រឹះស្ថានមធ្យមសិក្សាក្នុងក្រុង ត្រូវបានចូលរួមការសំអាតទីតាំងប្រារព្ធពិធី និងគោលដៅសំខាន់ៗនៅក្នុងទីប្រជុំជន ព្រមទាំងពង្រឹងនូវកិច្ចការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ទាំងមុនពេលប្រារព្ធពិធី និងពេលប្រារព្ធពិធី ។ ព្រះពន្លាជ័យដ៏ស្រស់ត្រកាល និងធំល្វឹងល្វើយ មានការតុបតែងដោយក្បូរក្បាច់ រចនា និងភ្លើងពណ៌ដ៏ភ្លឺរន្ទាល ព្រមទាំងរោងសម្រាប់ព្រាហ្មណ៍ ធ្វើហោមពិធី ៥កន្លែងជុំវិញព្រះស្រែ ត្រូវបានតម្លើងដោយមត់ចត់ពីក្រុមជាងព្រះបរមរាជវាំង ។ ស្គង់ពិពណ៌ដ៏វែង លាតសន្ធឹងតាមរបងការដ្ឋានមជ្ឈមណ្ឌលកីឡាហែលទឹក និងបត់មកកាន់ក្លោង ទ្វាជ័យ

បានត្រូវបណ្តាមន្ទីរអង្គភាពជុំវិញខេត្ត ស្រុក/ក្រុងទាំង១៧ និងក្រុមហ៊ុនឯកជនដាក់តាំងនូវសមិទ្ធផល និងផលិតផលរបស់ខ្លួនគួរជាទីទាក់ទាញ ។ គោឧសភរាជ ត្រូវបានបុគ្គលិកព្រះបរមរាជវាំងយកមករក្សាទុកក្នុងវិទ្យាល័យព្រះសីហនុ និងធ្វើការហ្វឹកហាត់សាកល្បងជាច្រើនលើកដោយឯកឧត្តម**លន់ លឹមថៃ** ទទួលកិត្តិយសជាស្តេច**មាឃ** និងលោកជំទាវ **ស្រ៊ុន ណាង** ជាភរិយាគាត់ទទួលកិត្តិយសជា **មេ ហួ** ។ នៅតាមរបងកីឡដ្ឋានមានលំអរដោយទង់ជាតិ និងទង់ព្រះបរមរាជវាំង ដែលប្រទាក់ក្រឡាដោយទង់ខ្សែទៅកាន់វាលព្រះស្រែ ។ នៅរសៀលថ្ងៃទី ២៧ ឧសភាមានឃ្មុំមួយសំបុកទៅទុំលើកំពូលទង់ព្រះបរមរាជវាំង ដែលនៅជាប់នឹងទ្វារជ័យ និងពុំមាននរណាម្នាក់ហ៊ានប៉ះពាល់លើវាឡើយនៅពេលនោះខ្ញុំមានការបារម្ភជាខ្លាំង ដោយខ្លាចវាផ្អើលនៅពេលដែលកងកិត្តិយសធ្វើវន្ទនកិច្ចថ្វាយព្រះមហាក្សត្រ និងក្បួនដង្ហែរស្តេច**មាឃ** ។ នៅព្រឹកថ្ងៃទី ២៨ ឧសភា ក្រោយពីភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ បានមកជួបជុំគ្នាលើព្រះពន្លាជ័យ និងមន្ត្រីរាជការសិស្សានុសិស្ស ព្រមទាំងប្រជាពលរដ្ឋ បានមកឈរត្រៀបត្រាក្នុងកន្លែងប្រារព្ធពិធីរួចហើយ ព្រះករុណាព្រះនរោត្តម**សីហ មុនី** ទ្រង់យាងតាមព្រះរាជទីនាំងរថយន្ត រួចទ្រង់យាងចុះនៅមុខទ្វារជ័យដោយទទួលនូវបដិសណ្ឋារកិច្ច ដោយស្នូរជ័យឃោសន៍យ៉ាងគឹកកងពីមហាជន និងការថ្វាយវន្ទនកិច្ចពីកងកិត្តិយស រួចព្រះអង្គយាងកាត់វាលព្រះស្រែមកគង់ប្រថាប់ក្នុងព្រះពន្លាជ័យ ។ ក្បួនដង្ហែរស្តេច**មាឃ** និង**មេហួ** ដែលដឹកមុខដោយអ្នកកាន់ទង់ឯកនិងក្រុមភ្លេងពិណពាទ្យ និងអ្នកកាន់គ្រឿងរណ្តាប់តាមប្រពៃណី

ជាច្រើននាក់ អមសងខាងដោយអ្នកកាន់ទង់ជ័យ ទង់ក្ដោប ចាមរ និងកូតាន បានចេញដំណើរពីចំណុចមុខក្លោងទ្វារវិទ្យាល័យព្រះសីហនុតម្រង់មកកាន់សាលាជាតិកសិកម្ម រួចបត់ទៅតាមផ្លូវជាតិ លេខ៧ មកកាន់ទ្វារជ័យ រួចស្ដេច**មាឃ** និង**មេហួ** បានចុះពីគ្រែ ស្នែង ហើយធ្វើដំណើរមកក្រាបថ្វាយបង្គំព្រះមហាក្សត្រនៅព្រះ ពន្លាជ័យ ។ បន្ទាប់ពីព្រះមហាថេរៈបានសូត្រធ្យាយជ័យន្តោ និងពិធី គោរពទង់ជាតិ ហើយលោកអាចារ្យអធិបតីក៏បានធ្វើការប្រកាស ដល់ទេវតា និងគុណបុណ្យវត្ថុសក្ដិសិទ្ធិទាំងអស់ឲ្យមកជួយធ្វើការ ឧបត្ថម្ភគាំពារវប្បមង្គលនេះប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និង ឲ្យភ្លៀងធ្លាក់ពេញបរិបូណ៌ក្នុងព្រះរាជាណាចក្រកម្ពុជា ជម្រុញឲ្យ ដំណាំគ្រប់ប្រភេទលូតលាស់បានល្អទៅតាមរដូវកាលនីមួយៗ ។ បន្ទាប់ពីបានទទួលចីមពីព្រះមហាក្សត្រ ស្ដេច **មាឃ** និង **មេ ហួ** បានចេញទៅថ្វាយបង្គំទេវរូបព្រះចន្ទីនៅរោងទិសនិរតី ដោយក្រុម បាគូផ្លុំស័ង្ខ ៣បទ ទើបចាប់ចេញដំណើរច្រត់ព្រះន័ង្គល ៣ ជុំវាល ព្រះស្រែដែលកំដរដោយសម្លេងតន្ត្រីត្រៃទ័ព និងភ្លេងពិណពាទ្យដ៏ពិរោះរងំគួរជាទីចាប់ចិត្តជិតក្នុងអារម្មណ៍អ្នកចូលរួមទាំងឡាយ ។

លុះក្បួនច្រត់ព្រះន័ង្គលគម្រប់ ៣ជុំហើយ ក្បួនបានឈប់ នៅក្បែររោងទិសបូណ៌ ភ្នាក់ងារនាំមុខក្បួនបានដោះគោឧសភរាជ ចេញពីនឹម បន្ទាប់មកព្រាហ្មណ៍ព្រះរាជគ្រូបានសូត្រពាក្យអធិដ្ឋាន ផ្សងគោឧសភរាជឲ្យស៊ីអាហារ ៧ មុខ ដែលតំកល់នៅកណ្ដាល វាលព្រះស្រែចំពីមុខរោងព្រះពន្លាជ័យ ។ គោស៊ីតែពោតមួយមុខ ប៉ុណ្ណោះ ព្រាហ្មណ៍អធិបតីបានប្រកាសនិងទស្សន៍ទាយថា ផលិត ផលពោតបានល្អប្រសើរក្នុងឆ្នាំនេះ ។ បន្ទាប់ពីស្ដេច **មាឃ** និង **មេហួ**

បានថ្វាយបង្គំទេវរូបព្រះ**កច្ចាយនៈ**នៅទិសបូណ៌ ដោយទទួលនូវទឹកមន្តពីព្រះរាជគ្រូ និងសម្លេងស័ង្ខពីក្រុមបាគូ រួចក៏បានធ្វើដំណើរកាត់វាលព្រះស្រែ មកក្រាបថ្វាយបង្គំព្រះករុណាព្រះមហាក្សត្រនៅព្រះពន្លាជ័យ និងអមព្រះអង្គក្នុងការចែកនូវព្រះរាជអំណោយដល់កសិករ ដែលមានសំលៀកបំពាក់តាមបែបខ្មែរ បុរាណ។ បន្ទាប់មកព្រះមហាក្សត្រអមព្រះរាជដំណើរដោយស្តេច **មាឃ** និង**មេហួ** ភៀវកិត្តិយសជាតិ និងអន្តរជាតិ បានយាងមកទស្សនាពិពរ័ណ៌សមិទ្ធិផល និងផលិតផលនៅតាមស្តង់របស់មន្ទីរអង្គភាពជុំវិញខេត្ត ស្រុក ក្រុង និងក្រុមហ៊ុនឯកជន ក្នុងព្រះរាជហឫទ័យនិង ហឫទ័យស្ញើចសរសើរចំពោះការរីកចម្រើនលើគ្រប់ វិស័យដែលមន្ត្រីរាជការនិងប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាម ធ្វើឲ្យសម្រេចបានក្នុងរយៈកាលកន្លងមកក្នុងបរិយាកាសដែលប្រទេសជាតិមាតុភូមិមានសុខសន្តិភាពពេញលេញ ដែលជាលទ្ធលដ៏វិសេសវិសាលនៃនយោបាយឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់ លើត្បូងទ្រង់យាងនិវត្តន៍ទៅកាន់រាជធានីភ្នំពេញវិញ នៅម៉ោង ១២.៣០ តាមព្រះទីនាំងរថយន្ត ។

ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល នាថ្ងៃ ២៨ ឧសភា ២០១៣ បានទាក់ទាញយើងទាំងអស់គ្នា ឲ្យឃើញច្បាស់នូវយុគសម័យដ៏រុងរឿងរបស់ប្រជាជាតិយើងនាអតីតកាល ដែលប្រកាន់ជាប់នូវប្រពៃណី ជំនឿសាសនារបស់ខ្លួន ដែលមានក្បួនខ្នាតត្រឹម ត្រូវស័ក្តិសមជាមហាប្រទេសមួយប្រកបដោយវប្បធម៌សំបូរបែបក្នុងសាកលលោក ។ ដូចដែលបានរៀបរាប់មកហើយ ឃុំដែលទុំ

លើកំពូលទង់ព្រះបរមរាជវាំងនៅអមទ្វារជ័យពុំមានការភ្ញាក់ផ្អើល អ្វីឡើយនូវសម្លេងទ្រហ៊ឹងអឺងកងនៃសម្លេងត្រែទំព ដែលថ្វាយវន្ទនកិច្ចចំពោះព្រះមហាក្សត្រ និងក្បួនដង្ហែរស្ដេច**មាឃ** ព្រមទាំងចរាចរណ៍យ៉ាងណែនណាន់តាន់តាប់របស់មហាជន ។ នៅពេលដែលក្បួនច្រត់ព្រះនង្គ័លបានមួយជុំវាលព្រះស្រែ ឃុំនេះបានហើរចេញជាពីរហ្វូងតាមទិសពីរផ្សេងគ្នា ។ ក្នុងអារម្មណ៍របស់ខ្ញុំផ្ទាល់ចាត់ទុកទិដ្ឋភាពនេះ ជាអម្ពូតហេតុមួយ ពីព្រោះក្រោយពិធីវប្បមង្គលនេះបានតែប៉ុន្មានខែប៉ុណ្ណោះ ខេត្តកំពង់ចាមត្រូវបានបំបែកដោយបង្កើតជាខេត្តថ្មីមួយទៀត គឺខេត្តត្បូងឃ្មុំ ដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤។ តាមការពិតនិន្នាការនៃការបង្កើតខេត្តត្បូងឃ្មុំនេះ មានតាំងពីឆ្នាំ១៩៩៩មក ម្ល៉េះ អាស្រ័យដោយខេត្តកំពង់ចាម មានប្រជាជនជិតពីរលាននាក់ច្រើនជាងខេត្តនានាក្នុងប្រទេសកម្ពុជា ។ ដើម្បីជម្រុញនូវការអភិ វឌ្ឍន៍និងការបម្រើនូវសេវារដ្ឋបាល ក៏ដូចជាសេវាសាធារណៈឲ្យកាន់តែទូលំទូលាយ និងកាន់តែជិតស្និទ្ធិថែមទៀត ចាំបាច់បំផុតត្រូវតែបង្កើតខេត្តត្បូងឃ្មុំ ដោយកាត់ចេញស្រុក ក្រុង៧ នៅត្រើយខាងកើតទន្លេមេគង្គចេញពីខេត្តកំពង់ចាម។ ជម្រើសចាំបាច់ដែលរដ្ឋបាលខេត្តកំពង់ចាមត្រូវពុះពារធ្វើឲ្យសម្រេច គឺ ការទាក់ទាញនូវវិនិយោគិនមកបណ្ដាក់ទុនរកស៊ីក្នុងផ្នែកឧស្សាហកម្ម សំដៅបង្កើតការងារជូនប្រជាជន គួបផ្សំនឹងវិស័យកសិកម្មដែលមាន ស្រាប់ដើម្បីលើកកម្ពស់ជីវភាពរស់នៅឲ្យកាន់តែល្អប្រសើរបន្ថែម ទៀត ។



*( ស្តេច **មាឃ** និង **មេហ្គ** ថ្វាយបង្គំព្រះមហាក្សត្រ )*



(ព្រះមហាក្សត្រយាងទតស្តង់ពិព័ណ៌របស់ក្រុងកំពង់ចាម)

# កំពង់ចាមនិមិត្តរូបនៃឥស្សរភាព

ទោះបីជាខេត្តកំពង់ចាម ទើបតែបានផ្លាស់ប្តូរទ្រង់ទ្រាយក្នុងរយៈពេលថ្មីៗនេះក៏ដោយ ទឹកដីនេះបានបន្សល់ទុកនូវស្នាមអនុស្សាវរីយ៍ដ៏វិសេសវិសាល ដែលបានចារិកក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា នោះគឺជាមូលដ្ឋានដ៏សំខាន់ចំពោះការកសាងកម្លាំងដើម្បីតស៊ូរំដោះជាតិ ឲ្យផុតពីនឹមត្រួតត្រារបស់បរទេស ក៏ដូចជាការសង្គ្រោះជាតិឲ្យរួចផុតពីការរលាយសាបសូន្យក្នុងរបបប្រល័យពូជសាសន៍ ។ ជាការពិតណាស់ ខេត្តនៅប៉ែកខាងកើតនៃប្រទេសកម្ពុជាមួយនេះ បានទទួលអំណោយផលសេដ្ឋកិច្ចពីទន្លេមេគង្គ និងតំបន់ខ្ពង់រាបមានប្រជាជនរស់នៅច្រើន និងមានភូមិសាស្ត្រអនុគ្រោះក្នុងការកសាង និងការពារកម្លាំង។ ប្រវត្តិសាស្ត្របានបង្ហាញឲ្យយើងគ្រប់គ្នាបានដឹងថា ព្រះបាទ**ជ័យវរ្ម័ន ទី២** បានជ្រើសរើសយកឥន្ទ្របុរៈក្នុងទឹកដីកំពង់ចាម ធ្វើជាមូលដ្ឋាននៃការតស៊ូរំដោះជាតិពីការត្រួតត្រានៃរាជវង្ស **សៃលេន្ទ្រៈ** នៃនគរជ្វា ដោយព្រះអង្គបានប្រកាសជោគជ័យលើបច្ចាមិត្រ និងប្រកាសនូវលទ្ធិទេវរាជនៅលើកំពូលភ្នំ **មហេន្ទ្របព៌ត** ( ភ្នំគូលែន ) ក្នុងឆ្នាំ ៨០២ ដែលជាការចាប់ផ្តើមនូវយុគសម័យអង្គរដ៏រុងរឿង ។

ព្រះ**សុរិយោវង្ស** និងព្រះ**ចៅពញាយ៉ាត** សុទ្ធតែបានមកកសាងកម្លាំងទ័ពនៅខេត្តបាសាន ( ស្រីសន្ធរ ) ដើម្បីវាយរំដោះទីក្រុងអង្គរពីពួកសៀមឲ្យរត់ខ្ចាត់ខ្ចាយ រីឯព្រះ **រាមាជើងព្រៃ** ក៏បានប្រើប្រាស់កម្លាំងនេះដែរ ក្នុងការវាយបណ្តេញពួកសៀមចេញពីបន្ទាយលង្វែក ។ ***កំពង់ចាម*** គឺជាភូមិសាស្ត្រនយោបាយ និងយោ

ធាដ៏សំខាន់ក្នុងសង្គ្រាមក្នុងស្រុកសម័យដែលប្រទេសកម្ពុជាចែកតំបន់ត្រួតត្រាបី ដែលគ្រប់គ្រងដោយព្រះ**ធម្មោ រាជា** ព្រះ**សុរិ យោទ័យ** និងព្រះ**ស្រី រាជា**, សង្គ្រាមរវាងព្រះ**ស្រីសុគន្ធបទ** និង ហ្លួងព្រះ**ស្តេចកន** និងរវាងហ្លួងព្រះ**ស្តេចកន** និងព្រះ**ចន្ទរាជា** ។ *កំពង់ចាម* គឺជាមូលដ្ឋានដ៏រឹងមាំនៃចលនាតស៊ូប្រឆាំងនឹងអាណា និគមនិយមបារាំង និងចក្រពត្តិនិយមអាមេរិក និងជាទឹកដីដែលបានផ្តល់កំណើតដល់ឥស្សរជនជាច្រើននាក់គ្រប់កាលសម័យ ក្នុងនោះនាយករដ្ឋមន្ត្រីដែលមានដើមកំណើតនៅខេត្តកំពង់ចាម មាន ៖ លោក **អ៊ុំ ឈាងស៊ុន** លោក **អ៊ិន តាំ** លោក **ស៊ឹម វ៉ា** លោក **ហង្ស ធុនហាក់** និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។ គឺពិតជាទីមោទនភាពក្រៃលែងសម្រាប់ខេត្តកំពង់ចាម ដែលកុលបុត្រដ៏ឆ្នើមរបស់ខ្លួនមានសម្តេចតេជោ **ហ៊ុន សែន** សម្តេចចក្រី **ហេង សំរិន** និង សម្តេចធម្មពោធិសាល **ជា ស៊ីម** បានរួមសហប្រតិបត្តិការគ្នាយ៉ាងជិតស្និទ្ធប្រមូលនូវកម្លាំងអ្នកស្នេហាជាតិគ្រប់ទិសទី បង្កើតអង្គការរណសិរ្សសាមគ្គីសង្គ្រោះជាតិ កម្ពុជា ធ្វើការប្រយុទ្ធតស៊ូយ៉ាងប្តូរផ្តាច់ប្រឆាំងនិងរបបប្រល័យពូជសាន៍ឲ្យដួលរលំ នៅថ្ងៃ ៧ មករា ១៩៧៩ ដែលយើងទាំងអស់គ្នាចាត់ទុកជាថ្ងៃកំណើតទីពីរមិនអាចប្រកែកបានក្នុងជីវិតយើងម្នាក់ៗ ។ គឺឥស្សរជនដ៏ឆ្នើមទាំងបីនាក់នេះហើយ ដែលបានដឹកនាំយើងចេញពីស្ថាននរកអវចីយ៍នៃរបបប្រល័យពូជសាសន៍ និងដឹកនាំយើង ឲ្យជំនះពុះពារនូវរាល់ឧបស័គ្គតូចធំរាប់មិនអស់ ក្នុងការកសាងនូវសង្គមជាតិ សង្គមគ្រួសារឲ្យមានការរីកចម្រើនជាបន្តបន្ទាប់ រហូតដល់ប្រទេសជាតិមាតុភូមិយើង បានទទួល

នូវឯកភាពជាតិ ឯកភាពទឹកដី មានសុខសន្តិភាពពេញលេញ ដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍប្រកបដោយចិរភាព និង ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងបេសកកម្មរក្សាសន្តិភាព តាមបណ្តាប្រទេសនានា ក្រោមឆ័ត្រអង្គការសហប្រជាជាតិថែម ទៀតផង។ យើងទាំងអស់គ្នាត្រូវនាំគ្នាថែរក្សានូវសន្តិភាព និង ស្ថេរភាពនយោបាយ ឲ្យស្ថិតនៅជានិច្ចនិរន្តរ៍នៅលើមាតុភូមិជាទី ស្នេហានៃយើង ដោយនាំគ្នាប្រឹងប្រែងទប់ស្កាត់នូវរាល់សកម្ម ភាពអកុសលទាំងឡាយ ដែលអាចលេបត្របាក់នូវឥស្សរភាព របស់ប្រជាជាតិខ្មែរយើង។

# អ្នកដឹកនាំខ្មែរក្រហម ចូលរៀនជា
# សិស្សជំនាន់ទី ១ នៅវិទ្យាល័យព្រះសីហនុ (១៩៤២)



ប៉ុលពត ស្លាប់ក្នុងឆ្នាំ១៩៩៨



ខៀវ សំផន កំពុងតែត្រូវជំនុំជម្រះដោយ
សាលាកាត់ក្តីខ្មែរក្រហម



ហ៊ូ នឹម ត្រូវបានកំចាត់ចោល
ដោយប៉ុលពតក្នុងឆ្នាំ ១៩៧៧




ហ៊ូ យន់ ត្រូវបានកំចាត់ចោល
ដោយប៉ុលពតក្នុង ឆ្នាំ ១៩៧៥

# ឥស្សរជនជាន់ខ្ពស់នៃប្រទេសកម្ពុជា
# ដែលមានស្រុកកំណើតក្នុងខេត្តកំពង់ចាម



សម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន**

នាយករដ្ឋមន្ត្រី

អនុប្រធានគណបក្សប្រជាជនកម្ពុជា



សម្តេចអគ្គមហាពញាចក្រី

**ហេង សំរិន**

ប្រធានរដ្ឋសភា

ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា



**អ៊ុម ឈាងស៊ុន**

នាយករដ្ឋមន្ត្រី ១៩៥១



**ស៊ីម វ៉ា**

នាយករដ្ឋមន្ត្រី ឆ្នាំ១៩៥៨



**ហង្ស ធុនហាក់**

នាយករដ្ឋមន្ត្រី១៩៧២



**អ៊ិន តាំ**

នាយករដ្ឋមន្ត្រី ១៩៧៣

# កម្រងរូបភាពអនុស្សាវរីយខេត្តកំពង់ចាម



ផ្សារធំកំពង់ចាម  ចុងទស្សវត្ស ៦០



ផ្លូវមុខសាលាខេត្តកំពង់ចាម  ចុងទសវត្ស ៦០



ផ្លូវភ្លោះក្នុងខេត្តកំពង់ចាម ចុងទសវត្សរ៍ ៦០



សាកលវិទ្យាល័យភូមិន្ទកំពង់ចាម ចាប់ដំណើរការឆ្នាំ ១៩៦៥ មាន ៣ មហាវិទ្យាល័យ ៖ ១.មហាវិទ្យាល័យ មេកានិច, ២.មហាវិទ្យាល័យកសិកម្មប្រទេសក្តៅ និង មហាវិទ្យាល័យ វិទ្យាសាស្ត្ររូបនិយម - គណិតសាស្ត្រ មានលោក **គាត ឈន់** ជាសាកលវិទ្យាធិការ



សម្តេចឪយាងចេញពីសាលាខេត្តកំពង់ចាម យាងចូលរួមជាព្រះរាជាធិបតីភាព ក្នុងពិធីសម្ពោធ រោងមហោស្រព **ព្រះសីហមុនី**




ទិដ្ឋភាពនៃពិធីសម្ពោធសាលមហោស្រព **ព្រះសីហមុនី** ថ្ងៃ ២០ កក្កដា ១៩៦៨




កីឡដ្ឋាន នរិន្ទ្រពង្ស ចុងទសវត្ស ៦០



កងកម្លាំងប្រដាប់អាវុធ និងប្រជាជនកម្ពុជា ចូលរួមភារកិច្ចការពារ
និងកសាងមាតុភូមិ ក្រោយថ្ងៃជ័យជំនះ ៧ មករា ១៩៧៩



លោក **ហ៊ុន ណេង** និងសហការី រួមជាមួយប្រជាជនចូលរួមរាប់បាត្រ
ឧទិសកុសលជូនវិញ្ញាណក្ខ័ន្ធជនរងគ្រោះ ក្នុងរបបប្រល័យពូជសាសន៍



សិស្សានុសិស្សវិទ្យាល័យព្រះសីហនុ បានធ្វើពលកម្មសម្អាតទីធ្លាសាលា



ប្រជាជនក្នុងក្រុងកំពង់ចាម ចូលរួមពលកម្មស្ថាបនាផ្លូវ



សម្តេចឪយាងសម្ពោធសាលាបច្ចេកទេសកសិកម្មមិត្តភាពកម្ពុជា **ហុង គ្រី ១០.១២.១៩៩១**



សម្តេចឪយាងសម្ពោធផ្សារបឹងកុក **០៥.០៤.១៩៩៦**



ព្រះករុណាព្រះ**នរោត្តម សីហមុនី** យាងចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ
ខេត្តកំពង់ចាម ឆ្នាំ ២០០៤



សត្វឃ្មុំទំលើកំពូលទង់ព្រះបរមរាជវាំង នៅអមក្លោងទ្វាធំ ក្នុងព្រះរាជពិធី
ច្រត់ព្រះនង្គ័ល **២៧,២៨. ឧសភា ២០១៣**


ផែនទីរដ្ឋបាល ខេត្តកំពង់ចាម
សញ្ញាសំគាល់
សាលាស្រុក
ផ្លូវ ចាក់កៅស៊ូ
ផ្លូវ គ្រួសក្រហម ឬ ក្រាលថ្ម
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ខេត្តកំពង់ធំ
ខេត្តក្រចេះ
ខេត្តត្បូងឃ្មុំ
ខេត្តកំពង់ឆ្នាំង
ខេត្តកណ្តាល
ខេត្តព្រៃវែង
ប្រទេសវៀតណាម
N
S
E
W
0
10
20
Kilometers

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម
នាយកដ្ឋាននគរូបនីយកម្ម

# ផែនទីបណ្តាញផ្លូវ ទីក្រុងកំពង់ចាម ឆ្នាំ២០១០

## The Road Network of Kampong Cham City, 2010



# ចក្ខុវិស័យនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍ក្រុងកំពង់ចាម



# ឯកសារពិគ្រោះ

- ឯកសារមហាបុរសខ្មែរ របស់លោក **អេង សុត** បោះផ្សាយដោយអគារវប្បធម៌ ១៩៩១
- ប្រវត្តិសាស្ត្រខ្មែរ របស់ លោក **ត្រឹង ងា** បោះផ្សាយនៅឆ្នាំ ១៩៧៣
- ប្រវត្តិសាស្ត្រខ្មែរ របស់ លោក **រស់ ចន្ទ្រាបុត្រ** បោះផ្សាយ នៅឆ្នាំ ១៩៩៧
- សធារណរដ្ឋខ្មែរ របស់ លោក **រស់ ចន្ទ្រាបុត្រ**
- ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា របស់លោក **មីហេយេវ** (អង្គការបោះពុម្ព ប្រូហ្គ្រេស មូស្គូ ១៩៨៥ )
- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា របស់លោក **អាដេម៉ារ ឡឺក្លែរ** ១៩១៣
- Cambodge et Cambodgiens . Paul Collard . Paris 1925
- ចរឹតខ្មែរ របស់លោក **ប៊ុណ្ណ ចាន់ម៉ុល** ១៩៧៣
- ស្រុកខ្មែរ ការវិវត្តន៍ចលនានយោបាយ របស់លោក **សាគូ សាមុត** ប៉ារីស ឆ្នាំ ២000
- ប្រវត្តិសាស្ត្រកម្ពុជា និង វរជនខ្មែរ របស់លោក **សាគូ សាមុត** ឆ្នាំ២០១៣
- ស្វែងយល់ពីរដ្ឋាភិបាលកម្ពុជានីមួយៗក្នុងរយៈពេល ៦ទស វត្សរ៍ចុងក្រោយរបស់លោក **ពុយ គា** ២០០៦
- នាយករដ្ឋមន្ត្រីខ្មែរ ៣៦ រូប ជានរណា? របស់លោក **ឆាយ សុផល** ២០១៤
- ប្រវត្តិសាស្ត្រខ្មែរ របស់លោក **ដេវិឌ ឆាណ្ឌលរ័**

- សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រី ប្រសូតចេញមកពីត្រកូលកសិកររបស់ក្រុមស្រាវជ្រាវ មាន លោក **ឆយ យីហ៊ាង**..... ២០០៧
- កំរងស្នាដៃ ឯកឧត្តម **ហ៊ុន ណេង** ២៦ ឆ្នាំ ក្នុងការអភិវឌ្ឍន៍ ដោយមន្ត្រីសាលាខេត្តកំពង់ចាម ២០០៦
- Liste des Résidents Supérieurs Français au Cambodge
- Mixted Medicines . Sokhieng Au
- ព្រះរាជពិធីទ្វាទសមាស ភាគ២ ១៩៥១
- កម្រងលិខិតរដ្ឋបាលសម្រាប់ការងារការិយាល័យ និងវិធីដោះស្រាយវិវាទដីធ្លី របស់ ឯកឧត្តម **ប៉ុល លឹម** ២០០០
- រឿងតាព្រហ្មនៅវត្តនគរបាជ័យ តាមសេចក្តីរាយការណ៍ របស់លោក **លី ធាមតេង** នៅពុទ្ធសាសនបណ្ឌិត ស្រាវ ជ្រាវដោយមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ចាម ឆ្នាំ២០០៥
- សៀវភៅកម្ពុជសុរិយា.....
- អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា សង្គមរាស្ត្រនិយម ឆ្នាំ ( ១៩៥៥- ១៩៦៩ )
- របាយការណ៍បូកសរុបប្រចាំឆ្នាំ ២០១៣ របស់សាលាក្រុងកំពង់ចាម

## សូមគោរពថ្លែងអំណរគុណ

## ចំពោះព្រះតេជគុណ ឯកឧត្តម អស់លោក
## ដែលមានព្រះនាម និងនាម ដូចខាងក្រោមនេះ
## ដែលបានផ្តល់នូវព័ត៌មានជុំវិញការស្រាវជ្រាវនេះ

១-ព្រះនាគមុនី **អន ធានអាន** ព្រះមេគណខេត្ត និងជាចៅអធិការវត្តសុទស្សនារាមជ្រោយថ្ម។

២-ព្រះគ្រូ **មាស ភន** ចៅអធិការវត្តបទុមរតនារាមដីដុះ

៣-ព្រះគ្រូ **ខាន់ ខាត់** ចៅអធិការវត្តជោតនារាមបឹងកុក

៤-ឯកឧត្តម **ប៉ុង យ៉េន** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

៥-ឯកឧត្តម **អ៊ុក រ៉ុង** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**

៦-ឯកឧត្តម **ខែក សំអុន** សមាជិកក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ

៧-ឯកឧត្តម **ម៉ៅ ឈួន** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

៨-ឯកឧត្តម **ហៃ ងួនលី** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

៩-លោកជំទាវ **ខុង ស៊ុនអេង** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

១០-លោកជំទាវ **លន់ សូមានី** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

១១-ឯកឧត្តម **ម៉ៅ ណៃត** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

១២-ឯកឧត្តម **ឆាយ គឹមសុន** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម

១៣-លោកឧត្តមសេនីយត្រី **ឈី សារឿង** នាយទាហានយុទ្ធភូមិភាគ២

១៤-លោក **ខ្ញង អួន** ចៅសង្កាត់បឹងកុក

១៥-លោក **កុយ គុន** មេភូមិ១៥ សង្កាត់កំពង់ចាម

១៦-លោក **ស៊ាង ឡុងហេង** អតីតមេឃុំសំបួរមាស ប្រជាជនភូមិនាងគង្ហីង សង្កាត់សំបួរមាស

១៧-លោក **តូច ខេង** ប្រជាជនសង្កាត់វាលវង់

១៨-លោក **ព្រាប សុម៉ាឡា**ប្រធានអង្គភាពរដ្ឋាករទឹកកំពង់ចាម

១៩-លោក **គីម គឹមអ៊ាង** អតីតនាយកវិទ្យាល័យ ព្រះសីហនុ

២០-លោក **គីម សំពិសាល** មន្ត្រីសាលាក្រុងកំពង់ចាម ដែលបានជួយបញ្ចូលរូបភាព និងកែសម្រួលទម្រង់អត្ថបទ ។